# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយអភិវឌ្ឍន៍វិស័យ
# ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ - ២០២៥

*«តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផល*
*ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម»*

**រាជធានីភ្នំពេញ, ខែមីនា ឆ្នាំ ២០១៥**

# មាតិកា


*ខ្លឹមសារសង្ខេបប្រតិបត្តិ* i-v

**១) - សេចក្តីផ្តើម** ១

*១-១) - ភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម* ១

*១-២) - បរិការណ៍សំខាន់ៗនៃមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា* ៣

**២) - ស្ថានភាពឧស្សាហកម្មនៅកម្ពុជា** ៥

*២-១) - ទិដ្ឋភាពរួមនៃរចនាសម្ព័ន្ធឧស្សាហកម្ម* ៥

*២-២) - បញ្ហាប្រឈមគន្លឹះៗ នៃការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា* ៩

**៣) - ចក្ខុវិស័យ** ១៥

**៤) - គោលបំណង និងគោលដៅ** ១៦

**៥) - ក្របខណ្ឌយុទ្ធសាស្ត្រ** ១៨

*៥-១) - យុទ្ធសាស្ត្រគន្លឹះនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម* ១៨

*៥-២) - វិសាលភាព និង វិស័យអាទិភាព* ១៩

*៥- ៣) - អភិក្រមនៃការអនុវត្ត* ២១

**៦) - វិធានការគោលនយោបាយ និងផែនការសកម្មភាព** ២២

*៦-១) - ការជំរុញការទាក់ទាញវិនិយោគ* ២២

*៦-២) - ការពង្រីក និង ទំនើបកម្មសហគ្រាសធុនតូច និងមធ្យម* ២៦

*៦- ៣) - ការកែលម្អបរិស្ថាននិយ័តកម្ម* ២៨

*៦-៤) - ការសម្របសម្រួលគោលនយោបាយគាំទ្រ* ៣១

**៧) - យន្តការដឹកនាំ, សម្របសម្រួល និង អនុវត្តគោលនយោបាយ** ៣៧

*៧-១) - ការពង្រឹងតួនាទីនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* ៣៨

*៧-២) - ការកែសម្រួលមុខងារ និងពង្រឹងសមត្ថភាពគណៈកម្មាធិការវិនិយោគកម្ពុជា* ៣៩

*៧- ៣) - ការតម្រង់ទិសមុខងារគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា* ៤១

*៧-៤) - ការពង្រឹងយន្តការពិគ្រោះយោបល់ជាមួយវិស័យឯកជន* ៤១

*៧-៥) - ការតាមដាន- ត្រួតពិនិត្យការអនុវត្តគោលនយោបាយ* ៤២

**៨) - ការគ្រប់គ្រងហានិភ័យសំខាន់ៗ** ៤២

**៩) - សេចក្តីសន្និដ្ឋាន** ៤៤

# ខ្លឹមសារសង្ខេបប្រតិបត្តិ

**1.** ឈរលើទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ ២០៣០ ជាពិសេស ***«យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣»*** រាជរដ្ឋាភិបាលបានរៀបចំ និង ដាក់ចេញនូវ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ដើម្បីជាមគ្គុទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ។

**2.** ការរៀបចំ និងដាក់ចេញនូវគោលនយោបាយនេះឡើង គូសបញ្ជាក់អំពីភាពចាំបាច់ និងភាពបន្ទាន់ក្នុងការបង្កើតនូវ***«យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី»*** ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក រួមមានៈ *ទី១)-* ភាពអំណោយផលនៃកត្តាភូមិសាស្ត្រនយោបាយសម្រាប់ការតភ្ជាប់សេដ្ឋកិច្ច និងឧស្សាហកម្មកម្ពុជា ទៅនឹងតំបន់ ពិសេសក្នុងក្របខណ្ឌនៃការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសេរីភាវូបនីយកម្មសេដ្ឋកិច្ចតំបន់; *ទី២)-* តួនាទីនៃវិស័យឧស្សាហកម្មក្នុងការបង្កើតនូវកំណើន និងការងារថ្មី នៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចបើកចំហរ, កត្តាផលលាភប្រជាសាស្ត្រ និងការប្រែប្រួលរចនាសម្ព័ន្ធសំខាន់ៗ ដែលអំណោយផលចំពោះការរីកលូតលាស់នៃវិស័យឧស្សាហកម្ម; *ទី៣)-*តួនាទីនៃវិស័យឧស្សាហកម្ម ជាឧបករណ៍គោលនយោបាយសម្រាប់ពង្រឹងការតភ្ជាប់រវាងវិស័យជន្ទល់សេដ្ឋកិច្ចសំខាន់ៗ ដូចជា វិស័យកសិកម្ម និងសេវាកម្ម ដែលនឹងរួមចំណែកដល់ការលើកកម្ពស់កំណើនសេដ្ឋកិច្ចបន្ថែមទៀត និង *ទី៤)-* សារៈសំខាន់នៃវិស័យឧស្សាហកម្ម ជាការដ្ឋាននៃការកែទម្រង់រចនាសម្ព័ន្ធ និងស្ថាប័នគ្រប់គ្រងសេដ្ឋកិច្ចជាតិ សំដៅលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចសម្រាប់រយៈពេលវែង និង បញ្ចៀសបាននូវ ***«អន្ទាក់ប្រទេសមានចំណូលមធ្យម»*** ។

**3.** ស្ថានភាពឧស្សាហកម្មកម្ពុជាមានសភាពទន់ខ្សោយ ឆ្លុះបញ្ចាំងអំពីរចនាសម្ព័ន្ធផលិតកម្មសាមញ្ញ និងតូចចង្អៀត ដែលប្រមូលផ្តុំជុំវិញផលិតកម្មសម្លៀកបំពាក់ និង ការកែច្នៃអាហារ ហើយមូលដ្ឋានផលិតភាគច្រើនមានលក្ខណៈគ្រួសារ និង មិនទាន់មានសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ។ ចំណុចសំខាន់ៗនៃឧស្សាហកម្មកម្ពុជា រួមមាន មូលដ្ឋានឧស្សាហកម្មមិនសូវសំបូរបែប, រចនាសម្ព័ន្ធឧស្សាហកម្មប្រហោងកណ្តាល និងក្រៅផ្លូវការ, សហគ្រិនភាពនៅទន់ខ្សោយ និង ប្រមូលផ្តុំតែនៅទីក្រុង ព្រមទាំង តម្លៃបន្ថែមទាប និងបច្ចេកវិទ្យាទន់ខ្សោយ ដែលក្នុងនោះចំនួនសហគ្រាសមីក្រូមានច្រើនជាង ៩៧ % ប៉ុន្តែផ្តល់ការងារបានតែ ៣០% និងមានផលរបបសរុប តែ ១២%, សហគ្រាសធុនធំមានតែ ០,៦ % ប៉ុន្តែផ្តល់ការងារបាន ៦៣% និងមានផលរបបសរុប

៧៦ % ហើយសហគ្រាសមិនផ្លូវការមានច្រើនលើសលប់ ។ សហគ្រិនភាពនៅទន់ខ្សោយ និងប្រមូលផ្តុំតែនៅទីក្រុង ក្នុងនោះ សហគ្រាសជាង ៤២ % ទើបបង្កើតចាប់តាំងពីឆ្នាំ ២០០៨ មក, សហគ្រាសកម្មន្តសាលធុនធំជាង ៦៣ % ជាការវិនិយោគពីបរទេស និងភាគច្រើនបម្រើឱ្យគោលដៅនាំចេញ, សហគ្រាសកម្មន្តសាលធុនធំ ៦៨ % មានមូលដ្ឋាននៅរាជធានីភ្នំពេញ និង ១៣ % នៅខេត្តកណ្តាល ។

**4.** ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ប្រឈមនឹងបញ្ហាគន្លឹះៗ ចំនួនប្រាំ គឺៈ *ទី១)*-កង្វះភាពជាអ្នកដឹកនាំ, ការសម្របសម្រួល និង ការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពក្នុងគ្រប់កម្រិត ពិសេស ការគាំទ្រសំខាន់ៗ ពាក់ព័ន្ធនឹងបញ្ហាផ្គត់ផ្គង់អគ្គិសនី, ហេដ្ឋារចនាសម្ព័ន្ធ និងឡូជិស្ទីក ធនធានមនុស្ស និងជំនាញ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត; *ទី២)*-ការអភិវឌ្ឍមូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញ ដែលជាអាទិភាពសំខាន់ ដើម្បីប្រែក្លាយកម្លាំងពលកម្មឱ្យមានជំនាញ និងមានសមត្ថភាពឈោងចាប់យកបច្ចេកទេស និងបច្ចេកវិទ្យាខ្ពស់; *ទី៣)*-ការរៀបចំហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនៅមិនទាន់គ្រប់គ្រាន់ ពិសេស កង្វះការសម្រប-សម្រួលក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ការផ្គត់ផ្គង់អគ្គិសនី, ទឹកស្អាត, បណ្តាញផ្លូវគមនា-គមន៍, លូបញ្ចេញកាកសំណល់ និង ការផ្តល់សេវាសាធារណៈឱ្យបានគ្រប់គ្រាន់; *ទី៤)*- ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅមានកម្រិត ដែលជាឧបសគ្គដល់ការផ្តល់ហិរញ្ញប្បទានគម្រោងឧស្សាហកម្ម ទាំងយន្តការហិរញ្ញប្បទានសាធារណៈ និងឯកជន និង*ទី៥)*-បញ្ហាទីផ្សារការងារ និងទំនាក់ទំនងឧស្សាហកម្ម ដែលជាគន្លឹះធានាស្ថិរភាពទីផ្សារការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ក៏ដូចជា ការលើកកម្ពស់ផលិតភាព និងជីវភាពរបស់ពលករ ។

**5.** ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែ និង ធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែចង្វាក់តម្លៃសកល, សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និង ការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡាទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និង ការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក, ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង ។ ការសម្រេចនូវចក្ខុវិស័យនេះ នឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ, ការទ្រទ្រង់ និង លើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន, ការបង្កើតការងារ, ការបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច និង ការបង្កើនប្រាក់ចំណូលសមរម្យជូនប្រជាជនកម្ពុជា ។

**6.** ដើម្បីសម្រេចចក្ខុវិស័យខាងលើ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** រាជរដ្ឋាភិបាលកំណត់នូវគោលដៅចំនួនបីៈ *ទី១)*-បង្កើនចំណែកនៃវិស័យឧស្សាហកម្មក្នុង ផសស ឱ្យបានដល់ ៣០% នៅឆ្នាំ ២០២៥ (២៤,១% នៃផសស នៅឆ្នាំ ២០១៣) ដែលវិស័យកម្មន្តសាលត្រូវកើនឡើងពី ១៥,៥% នៃផសស នៅឆ្នាំ ២០១៣ ទៅដល់ ២០% នៅឆ្នាំ ២០២៥; *ទី២)*-ជំរុញពិពិធកម្មមុខទំនិញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល

មិនមែនជាវាយនភ័ណ្ឌឱ្យបាន ១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ ២០២៥ ទន្ទឹមនឹងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន ១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ ២០២៥ និង *ទី៣)* - កំណត់គោលដៅនៅឆ្នាំ ២០២៥ ឱ្យសហគ្រាសធុនតូចចំនួន ៨០% និងសហគ្រាសធុនមធ្យមចំនួន ៩៥% ត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូចចំនួន៥០% និងសហគ្រាសធុនមធ្យមចំនួន ៧០% មានបញ្ជីការគណនេយ្យ និងតារាងតុល្យការត្រឹមត្រូវ ។

**7.** ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលដៅខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះបួន គឺៈ *ទី១)* - កៀរគរ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគឯកជនក្នុងស្រុក ដោយផ្តោតលើឧស្សាហកម្មធំៗ, ការអភិវឌ្ឍ/ពង្រីកទីផ្សារ និង ការអភិវឌ្ឍ/ផ្ទេរបច្ចេកវិទ្យា; *ទី២)* - អភិវឌ្ឍ និងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម (ពង្រីក និងពង្រឹងមូលដ្ឋានឧស្សាហកម្មកម្មន្តសាល, ធ្វើទំនើបកម្ម និងចុះបញ្ជីសហគ្រាសជាផ្លូវការ, អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា និង ការតភ្ជាប់ឧស្សាហកម្ម); *ទី៣)* - កែលម្អបរិស្ថាននិយ័តកម្មដើម្បីពង្រឹងភាពប្រកួតប្រជែង (បរិយាកាសវិនិយោគ និង កិច្ចសម្រួលពាណិជ្ជកម្ម, ការផ្តល់ព័ត៌មានទីផ្សារ និង ការកាត់បន្ថយចំណាយចម្លងការ) និង *ទី៤)* - សម្របសម្រួលគោលនយោបាយគាំទ្រ (ការអភិវឌ្ឍធនធានមនុស្ស/បណ្តុះបណ្តាលជំនាញ, ការកែលម្អទំនាក់ទំនងឧស្សាហកម្ម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា ប្រព័ន្ធដឹកជញ្ជូន/ឡូជីស្ទីក និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍, ការផ្គត់ផ្គង់អគ្គិសនី/ទឹកស្អាត និង សេវាសាធារណៈ/សេវាសង្គមកិច្ច/សេវាហិរញ្ញវត្ថុ ។

**8.** អភិក្រមសំខាន់នៃ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** គឺការជំរុញការអភិវឌ្ឍវិស័យកម្មន្តសាល និងឧស្សាហកម្មកែច្នៃកសិផល តាមរយៈការធ្វើសមាហរណកម្មទៅនឹងខ្សែចង្វាក់ផលិតកម្មតំបន់ និងពិភពលោក; ការតម្រង់ទិសការអភិវឌ្ឍតំបន់ឧស្សាហកម្ម ដើម្បីធានានូវភាពប្រមូលផ្តុំ, ការតភ្ជាប់សេដ្ឋកិច្ច និង ការប្រកួតប្រជែង; ការអភិវឌ្ឍរបៀងសេដ្ឋកិច្ច, ការធ្វើវិចារណកម្មយន្តការតំបន់សេដ្ឋកិច្ចពិសេស និង ការអភិវឌ្ឍសួនឧស្សាហកម្ម និងកន្សោមឧស្សាហកម្ម ។ វិសាលភាព និងអាទិភាពសំខាន់ៗ រួមមានៈ *ទី១)* - ឧស្សាហកម្ម ឬ កម្មន្តសាលថ្មីៗ ដែលមានចរិតជាការបើកច្រកចូលទីផ្សារ, ផ្តល់តម្លៃបន្ថែមខ្ពស់, មានភាពច្នៃប្រឌិត និងភាព-ប្រកួតប្រជែងខ្ពស់; *ទី២)* - សហគ្រាសធុនតូច និងមធ្យមក្នុងគ្រប់វិស័យ; *ទី៣)* - ផលិតកម្មកសិឧស្សាហកម្មដែលបម្រើឱ្យការនាំចេញ និង ទីផ្សារក្នុងស្រុក; *ទី៤)* - ប្រភេទឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម, ទេសចរណ៍ និងកាត់ដេរ ព្រមទាំងឧស្សាហកម្មបម្រើឱ្យខ្សែចង្វាក់ផលិតកម្មតំបន់ ដែលជាឧស្សាហកម្មតភ្ជាប់ទៅទីផ្សារ ឬ ខ្សែចង្វាក់តម្លៃសកល; និង *ទី៥)* - ប្រភេទឧស្សាហកម្មបម្រើឱ្យខ្សែចង្វាក់ផលិតកម្មតំបន់ និង មានចរិតយុទ្ធសាស្ត្រសម្រាប់ពេលអនាគត ។

**9.** នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រខាងលើនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការគោលនយោបាយ និង ផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា ដោយមានកំណត់ច្បាស់អំពីស្ថាប័ននាំមុខ និង

ស្ថាប័នទទួលខុសត្រូវអនុវត្ត ដូចមានចែងលម្អិតនៅក្នុងឧបសម្ព័ន្ធ«ឃ» ។ វិធានការគោលនយោបាយ និង ផែនការសកម្មភាពទាំងនេះ រួមមានៈ *ទី១)*-ជំរុញការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ដែលផ្តោតសំខាន់លើការកែលម្អបរិយាកាសវិនិយោគ និង ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងការរៀបចំតំបន់ឧស្សាហកម្ម; *ទី២)*-ពង្រីក និង ទំនើបកម្មសហគ្រាសធុនតូច និងមធ្យម ដែលផ្តោតលើការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត, ការចុះបញ្ជី និង ការកាន់បញ្ជីគណនេយ្យ និង ការជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម; *ទី៣)*-កែលម្អបរិស្ថាននិយ័តកម្ម ដែលផ្តោតលើវិធានការសម្រួលពាណិជ្ជកម្ម និង ជំរុញការនាំចេញ, ការពង្រឹងបទដ្ឋានឧស្សាហកម្ម និង កម្មសិទ្ធឧស្សាហកម្ម, ការសម្រួលការបំពេញកាតព្វកិច្ចពន្ធដារ និង ការរៀបចំទីផ្សារពលកម្ម និង ទំនាក់ទំនងឧស្សាហកម្ម និង *ទី៤)*-សម្របសម្រួលគោលនយោបាយគាំទ្រ ដែលផ្តោតលើការបណ្តុះបណ្តាលជំនាញ និង ធនធានមនុស្ស, ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ការកសាងហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និង វិធានការផ្នែកហិរញ្ញប្បទាន ។

**10.** បន្ថែមលើវិធានការគោលនយោបាយ និង ផែនការសកម្មភាពខាងលើ រាជរដ្ឋាភិបាលដាក់ចេញ នូវ **វិធានការជាក់ស្តែងគន្លឹះបួនយ៉ាង** ឱ្យសម្រេចបាននៅមុនដំណាច់ឆ្នាំ ២០១៨ ដែលជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ពិសេសគឺសម្រាប់ការលើកកម្ពស់ភាពប្រកួតប្រជែង និងភាពទាក់ទាញរបស់កម្ពុជា ។ វិធានការទាំងនេះ រួមមានៈ *ទី១)*-បញ្ចុះថ្លៃផ្គត់ផ្គង់អគ្គិសនី សម្រាប់តំបន់ឧស្សាហកម្មគោលដៅ រួមទាំង ពង្រីកវិសាលភាពគ្របដណ្តប់ និង លើកកម្ពស់ភាពទុកចិត្តក្នុងការផ្គត់ផ្គង់ចរន្ត; *ទី២)*-រៀបចំ និង អនុវត្តផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកពហុមធ្យោបាយ; *ទី៣)*- ពង្រឹង និងអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និង ការបណ្តុះបណ្តាលជំនាញ និង *ទី៤)*-អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ។

**11.** សម្រាប់ការអនុវត្ត រាជរដ្ឋាភិបាលនឹងដើរតួនាទីជាយុទ្ធសាស្ត្រវិទូ, ជាអ្នកសម្របសម្រួល, ជាអ្នកគាំទ្រ និងជាអ្នកផ្តួចផ្តើមគំនិត ប្រកបដោយសុច្ចរិតភាព និង ការទទួលខុសត្រូវខ្ពស់ ដោយរៀបចំនូវយន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** តាមរយៈការកែទម្រង់ស៊ីជម្រៅនូវ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ដោយផ្តល់សិទ្ធអំណាចពេញលេញ និង បំពាក់មុខងារចាំបាច់ជូនស្ថាប័ននេះ សម្រាប់ការសម្រេចចិត្តផ្នែកគោលនយោបាយ, ការរៀបចំ និង អនុវត្តផែនការ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមចំពោះមុខ ។ ការកែទម្រង់នេះរួមបញ្ចូលនូវ : *ទី១)*- ការពង្រឹងតួនាទីដឹកនាំគោលនយោបាយរបស់ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ក្នុងការចង្អុលទិស, អនុម័ត និង តាមដានសមិទ្ធកម្មនៃការអនុវត្តផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដោយសម្របសម្រួលជាមួយ «គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» និង «គណៈកម្មាធិការដឹកនាំការអភិវឌ្ឍវិស័យឯកជន» ព្រមទាំងស្ថាប័នជំនាញពាក់ព័ន្ធ ព្រមទាំងការបង្កើត***«ក្រុមប្រឹក្សា***

***ផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា»***; *ទី២)*- ការកែសម្រួលមុខងារ និងការពង្រឹងសមត្ថ-ភាព ***«គណៈកម្មាធិការវិនិយោគកម្ពុជា»*** ដោយបំពាក់បន្ថែមនូវមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម; *ទី៣)*- ការតម្រង់ទិសមុខងារគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម ក្នុងក្របខណ្ឌនៃការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងផែនការវិនិយោគសាធារណៈ និង*ទី៤)*- ការពង្រឹង និងតម្រង់ទិសយន្តការ ***«វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន»*** ដើម្បីផ្សព្វផ្សាយ និង លើកទឹកចិត្តការចូលរួមពីវិស័យឯកជន ។

**12.** ជាចុងក្រោយ ដើម្បីធានានូវវឌ្ឍនភាពជាប្រចាំ និងប្រសិទ្ធភាពនៃ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** រាជរដ្ឋាភិបាលបង្កើតនូវយន្តការតាមដាន និងត្រួតពិនិត្យ ដោយប្រគល់ភារកិច្ចជូន***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ឱ្យរៀបចំ និងសម្របសម្រួលៈ *ទី១)*-ប្រព័ន្ធរាយការណ៍ប្រចាំត្រីមាស និង ប្រចាំឆ្នាំ ពិសេសរបាយការណ៍ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី រៀងរាល់ ៣ ខែម្តង ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និង បញ្ហាប្រឈមព្រមទាំងសម្រេចលើវិធានការចាំបាច់ត្រូវអនុវត្តបន្ទាន់; *ទី២)*-យន្តការដោះស្រាយវិវាទឧស្សាហកម្ម; *ទី៣)*-ការត្រួតពិនិត្យវាយតម្លៃអំពីវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តវិធានការជាក់ស្តែងគន្លឹះបួនយ៉ាងនៃ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ត្រឹមដំណាច់ឆ្នាំ ២០១៨ និង ការត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិក្នុងទ្រង់ទ្រាយធំ និងទូលំទូលាយ នៅឆ្នាំ ២០២០ ដើម្បីជាមូលដ្ឋានកែតម្រូវ និងតម្រង់ទិសសម្រាប់ការអនុវត្តជំហានបន្ទាប់។

# គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ - ២០២៥

***«តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផល ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម»***

## ១) - សេចក្តីផ្តើម

### *១-១) - ភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម*

ទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ ២០៣០ និង ***«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣»*** បានចង្អុលបង្ហាញពីការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ដែលកំពុងឈានទៅសម្រេចឋានៈប្រទេសមានកម្រិតចំណូលមធ្យម និង បានចាត់ទុកវិស័យឧស្សាហកម្មជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានរៀបចំ និង ដាក់ចេញនូវ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ដើម្បីជាមគ្គុទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ។ ម៉្យាងទៀត គោលនយោបាយនេះនឹងក្លាយជា ***«យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី»*** ដែលផ្តោតជាសំខាន់លើការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ស្របតាមនិន្នាការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងការវិវត្តន៍នៃនិម្មាបនកម្មសេដ្ឋកិច្ចពិភពលោក និងតំបន់ ក៏ដូចជាការប្រើប្រាស់សក្តានុពលធនធានសរុបជាតិឱ្យអស់លទ្ធភាព ។

ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់ រួមទាំង ទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានគូសបញ្ជាក់ច្បាស់អំពីកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ។ ជាក់ស្តែង ក្នុងក្របខណ្ឌសមាហរណកម្ម និង សេរីភាវូបនីកម្មសេដ្ឋកិច្ចតំបន់ ពិសេស ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) កម្ពុជានឹងសម្រេចនូវការតភ្ជាប់ទាំងផ្នែករូបវ័ន្ត និង ស្ថាប័ន រួមទាំង សមាហរណកម្មទូលំទូលាយលើគ្រប់វិស័យ ដែលនឹងរួមចំណែកដល់ការបើកច្រកទីផ្សារថ្មីៗ ការទាក់ទាញទុនវិនិយោគ និង ការផ្ទេរបច្ចេកវិទ្យាមកកម្ពុជា ។ ក្នុងន័យនេះ វិស័យពាណិជ្ជកម្ម និង ឧស្សាហកម្មកម្ពុជា នឹងទទួលប្រយោជន៍ពីសាកលភាវូបនីយកម្មជារួម ពិសេស ការវិនិយោគពីប្រទេសចិន កូរ៉េ និងជប៉ុន ក៏ដូចជា ពីសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ដែលកំពុងស្វះស្វែងរកឱកាសពាណិជ្ជកម្ម និងវិនិយោគ នៅក្នុងទីផ្សារលូតលាស់ថ្មីដូចជាកម្ពុជា ។ ជារួម ល្បឿននៃការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា នឹងត្រូវកំណត់ដោយកត្តាសក្យានុម័តសំខាន់ៗបី គឺៈ ***«ការប្រែប្រួលរចនាសម្ព័ន្ធថ្លៃក្នុងតំបន់»*** រួមទាំងកម្រៃប្រាក់ឈ្នួលផងដែរ, ***«និន្នាការតភ្ជាប់ឧស្សាហកម្មតំបន់»*** ដែលកម្ពុជាស្ថិតលើទីតាំងភូមិសាស្ត្រអំណោយផល រវាងតំបន់ឧស្សាហកម្មសក្តានុពលទីក្រុងបាងកក និង ហូជីមិញ ក៏ដូចជា នៅជិតសេដ្ឋកិច្ចអាស៊ីធំៗ រួមមាន ចិន ជប៉ុន និងកូរ៉េ, និង***«និន្នាការរក្សាស្ថិរភាពនៃខ្សែចង្វាក់ផ្គត់ផ្គង់»*** ចំពោះមុខហានិភ័យដែលបណ្តាលមកពីកត្តាភូមិសាស្ត្រនយោបាយ គ្រោះមហន្តរាយធម្មជាតិ ជម្លោះការងារ និងភាពរំខានផ្សេងៗ ។

ស្ថានភាពអំណោយផលដោយសារការបើកចំហសេដ្ឋកិច្ច និង រចនាសម្ព័ន្ធសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរប្រកបដោយជីវភាព រួមទាំង កត្តាផលលាភប្រជាសាស្ត្រ និង សក្តានុពលសំខាន់ៗផ្សេងទៀត បានផ្តល់នូវលក្ខខណ្ឌចាំបាច់គ្រប់គ្រាន់ សម្រាប់ការអភិវឌ្ឍ និង ទំនើបកម្មវិស័យឧស្សាហកម្មកម្ពុជា ។ ក្នុងន័យនេះ ការដាក់ឱ្យអនុវត្តនូវ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** របស់រាជរដ្ឋាភិបាល នឹងក្លាយជាបន្លាស់ប្តូរវិធាននៃល្បែងដ៏សំខាន់ក្នុងន័យជំរុញសន្ទុះ និង រក្សាចីរភាពនៃកំណើនសេដ្ឋកិច្ច, ការបង្កើតការងារ និង ការលើកស្ទួយជីវភាពប្រជាជនដោយប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលជាតិសំខាន់ៗ ដូចជា ប្រភពកម្លាំងពលកម្មវ័យក្មេង មានការបណ្តុះ-បណ្តាលបានល្អ និង ប្រកបដោយចំណេះដឹងខ្ពង់ខ្ពស់, សក្តានុពលដែលកើតចេញពីសមិទ្ធផលនៃការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គម ពិសេស វិស័យដឹកជញ្ជូន និង ថាមពល, កាលានុវត្តភាពពាក់ព័ន្ធនឹងនិន្នាការនគរូបនីយកម្ម និង ការរីកលូតលាស់នៃស្រទាប់ប្រជាជនថ្នាក់កណ្តាលដែលមានកម្រិតប្រាក់ចំណូលខ្ពស់, ក៏ដូចជា ភាពជឿនលឿន និង ទំនើបកម្មក្នុងវិស័យកសិកម្ម និង វិស័យសេវាគាំទ្រផ្សេងទៀត ព្រមទាំង ***«ឧត្តមភាពនៃការអភិវឌ្ឍឈានក្រោយគេ»*** ។ ជាមួយគ្នានេះ សម្ពាធនៃការកើនឡើងប្រាក់ឈ្នួលបានតម្រូវឱ្យឧស្សាហកម្មកម្មន្តសាលបច្ចុប្បន្ន ដូចជា វិស័យកាត់ដេរជាដើម ខិតខំប្រឹងប្រែងបង្កើនផលិតភាពរបស់ខ្លួន ដើម្បីរក្សាភាពប្រកួតប្រជែងនៅក្នុងខ្សែចង្វាក់តម្លៃសកល ដែលកត្តានេះនឹងជំរុញឱ្យកម្ពុជាចាំបាច់ត្រូវធ្វើពិពិធកម្មវិស័យឧស្សាហកម្មឱ្យបានឆាប់រហ័ស ដើម្បីកាត់បន្ថយសម្ពាធនៃការកើនឡើងប្រាក់ឈ្នួលឱ្យប្រព្រឹត្តទៅជាជំហានៗ ប្រកបដោយសុខដុមភាព និង ធានាបាននូវការបង្កើតការងារប្រកបដោយគុណភាព និង មាននិរន្តរភាព ។

ការអភិវឌ្ឍវិស័យឧស្សាហកម្ម គឺជាឧបករណ៍គោលនយោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការតភ្ជាប់រវាងវិស័យសេដ្ឋកិច្ចសំខាន់ៗ ដែលជា***«ឃ្នាស់»***ជំរុញកំណើន និង ការងារបន្ថែមក្នុងវិស័យកសិកម្ម ទេសចរណ៍ និង សេវាកម្ម ។ ឧស្សាហកម្មនឹងរួមចំណែករំដោះអតិរេកពលកម្មពីវិស័យកសិកម្ម ដែលធ្វើឱ្យផលិតភាពសរុបកើនឡើង និង មានចំណូលខ្ពស់ជាងមុន ។ ចំណូលដែលទទួលបានពីវិស័យឧស្សាហកម្ម នឹងត្រូវយកទៅចំណាយលើម្ហូបអាហារ និង សម្ភារៈផ្សេងៗ ដែលនឹងទាញឱ្យមានកំណើនផ្នែកផលិតកម្មឧស្សាហកម្ម និង សេវាកម្មបន្ថែមទៀត ។ ម៉្យាងទៀត វិស័យឧស្សាហកម្មរួមចំណែកសំខាន់ដល់ការបង្កើតការងារ, ការបង្កើនប្រាក់ចំណូល និង ការលើកកម្ពស់ផលិតភាព តាមរយៈការវិនិយោគ និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ រួមទាំង ការបង្កើតការងារក្នុងវិស័យគាំទ្រដ៏ទៃទៀតនៅក្នុងគ្រប់ខ្សែចង្វាក់តម្លៃ ចាប់តាំងពីការផលិត និង ការផ្គត់ផ្គង់វត្ថុធាតុដើម, សេវាកម្មដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យហិរញ្ញវត្ថុ និង បណ្តុះបណ្តាលជំនាញ ជាដើម។

ដោយឡែកសម្រាប់គោលដៅរយៈពេលវែង ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលតម្រូវឱ្យមានការកែទម្រង់ស៊ីជម្រៅផ្នែករចនាសម្ព័ន្ធ និង ស្ថាប័ន គួបផ្សំនឹងការវិនិយោគលើធនធានមនុស្ស និង ហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យា និង នវានុវត្តន៍ផងដែរ នឹងបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ពង្រីង

សក្តានុពលកំណើនថ្មីៗ និង លើកកម្ពស់ភាពប្រកួតប្រជែង ដែលជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍក្នុងដំណាក់កាលបន្ទាប់ ដោយបញ្ចៀសនូវ***«អន្ទាក់ប្រទេសមានចំណូលមធ្យម»*** ។ ជាមួយគ្នានេះ កត្តាប្រជាសាស្ត្រ និងភូមិសាស្ត្រនយោបាយ បានបង្កើតនូវកាលានុវត្តដ៏កម្របំផុត សម្រាប់ការបោះជំហានលើខ្នង់រាបថ្មីមួយទៀតនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពិសេស ការកសាងមូលដ្ឋានឧស្សាហកម្មរឹងមាំ ដែលនឹងប្រែក្លាយកម្ពុជាទៅជាប្រទេសមានកម្រិតចំណូលមធ្យមក្នុងរយៈពេលដ៏ខ្លីខាងមុខ ។ ក្នុងបរិការណ៍ប្រកួតប្រជែងតំបន់កាន់តែតឹងតែងឡើង កម្ពុជានឹងចាត់វិធានការឱ្យបានឆាប់បំផុត ដើម្បីចាប់យក ***«ឱកាសមាស»*** នេះ តាមរយៈការអនុវត្តគោលនយោបាយបុរេសកម្ម និង មានភាពបត់បែនគ្រប់គ្រាន់ ។ បើមិនដូច្នេះទេ កម្ពុជាអាចនឹងបាត់បង់ឱកាសដ៏កម្របែបនេះ សម្រាប់ការធ្វើពិពិធកម្មកំណើនសេដ្ឋកិច្ច, ការលើកកម្ពស់ផលិតភាព និងភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការកសាងខឿនសេដ្ឋកិច្ចជាតិឱ្យរឹងមាំ និង មានការរីកចម្រើនរុងរឿង ។

ជាការសន្និដ្ឋាន ការរៀបចំ និង ដាក់ចេញនូវ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** នេះឡើង គួសបញ្ជាក់អំពីភាពចាំបាច់ និង ភាពបន្ទាន់ក្នុងការបង្កើតនូវ «យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី» ដែលឆ្លើយតបទៅនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និង សភាពការណ៍នៃសេដ្ឋកិច្ចតំបន់និងពិភពលោក ដែលកំពុងវិវត្តឥតឈប់ឈរ និង ឆាប់រហ័ស ។ តាមរយៈគោលនយោបាយនេះ រាជរដ្ឋាភិបាលនឹងមានលទ្ធភាពកៀរគរប្រភពធនធាន និង កម្លាំងសរុបជាតិ ដើម្បីបន្តជំរុញកំណើន និង អភិវឌ្ឍមូលដ្ឋានសេដ្ឋកិច្ចជាតិ សំដៅលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ, កិត្យានុភាពជាតិ និង ភាពរុងរឿងថ្កុំថ្កើង ក្នុងបរិការណ៍នៃការប្រកួតប្រជែងជាសកល និង ភាពជាម្ចាស់លើជោគវាសនាប្រទេសជាតិ ។

### ***១-២)-បរិការណ៍សំខាន់ៗ នៃមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា***

រាជរដ្ឋាភិបាលចាត់ទុកវិស័យឧស្សាហកម្ម ជាអាទិភាពសំខាន់នៃយុទ្ធសាស្ត្រកំណើន សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច, ការប្រែប្រួលរចនាសម្ព័ន្ធស៊ីជម្រៅ និង ភាពប្រកួតប្រជែងប្រសើរឡើង ។ ប្រការនេះនឹងជំរុញឱ្យរចនា-សម្ព័ន្ធសេដ្ឋកិច្ចមានវិសាលភាពទូលាយ ដែលពឹងផ្អែកសំខាន់លើវិស័យកម្មន្តសាល គាំទ្រដោយកសិកម្មទំនើប និងសេវាកម្មមានតម្លៃបន្ថែមខ្ពស់ ពិសេស ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ, វិស័យឡូជីស្ទីក និង បច្ចេកវិទ្យាទំនើប ។ ការប្រែប្រួលរចនាសម្ព័ន្ធបែបនេះ នឹងធានាបាននូវចីរភាព និង ភាពរឹងមាំនៃសេដ្ឋកិច្ចជាតិ ជាមួយគ្នានឹងការពង្រឹងតួនាទីអន្តរការីកម្មនៃវិស័យហិរញ្ញវត្ថុ, ទំនើបកម្មនៃប្រព័ន្ធឡូជីស្ទីក និង ការបែងចែកទំនិញ, ការឈោងចាប់បច្ចេកទេស និងបច្ចេកវិទ្យា ក៏ដូចជា ការលើកកម្ពស់អភិបាលកិច្ច និង សមត្ថភាពរបស់ស្ថាប័នរដ្ឋ ក្នុងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច ។

ចាប់តាំងពីឆ្នាំ ១៩៩៣ មកម្ល៉េះ វិស័យឧស្សាហកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ដែលវិភាគទានរបស់វិស័យនេះ ចំពោះ ផសស បានកើនឡើងជាបន្តបន្ទាប់ពី ១២,៦% រហូតដល់ខ្ពស់បំផុត ២៦,២% នៅឆ្នាំ ២០០៦ ។ ប៉ុន្តែក្រោយមក វិស័យឧស្សាហកម្មបានចាប់ផ្តើមថមថយជាបន្តបន្ទាប់ និង ស្ថិតក្នុងសភាពទ្រឹង

ក្នុងរង្វង់ ២៧% ដោយសារការប្រែប្រួលរបបពាណិជ្ជកម្មអន្តរជាតិ និង វិបត្តិសេដ្ឋកិច្ចសកល ។ បើគិតត្រឹមឆ្នាំ ២០១៣ វិស័យឧស្សាហកម្មបានរួមចំណែកដល់ ផសស ប្រមាណ ២៤% ជាមួយនឹងកំណើនមធ្យមប្រចាំឆ្នាំក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយ (១៩៩៨-២០១៣) ប្រហែល ១២,៤% ធៀបនឹង ៤,៧% សម្រាប់វិស័យកសិកម្ម និង ៨,៥% សម្រាប់វិស័យសេវាកម្ម ពោលគឺជាវិស័យដែលមានកំណើនខ្ពស់ជាងគេបំផុត ។

វិស័យឧស្សាហកម្មជាមូលដ្ឋានសំខាន់នៃការបង្កើតការងារ ។ នៅឆ្នាំ ១៩៩៣ មានពលករប្រមាណជា ៧២% ប្រកបមុខរបរក្នុងវិស័យកសិកម្ម និង ប្រហែល ៥% ប៉ុណ្ណោះមានមុខរបរក្នុងវិស័យឧស្សាហកម្ម ។ តាមជំរឿនឆ្នាំ ២០០៨ ចំនួនការងារក្នុងវិស័យឧស្សាហកម្មបានកើនដល់ជិត ៦០ម៉ឺន កន្លែង ឬ ស្មើនឹង ៨,៦% នៃចំនួនការងារសរុប ប៉ុន្តែតាមការអង្កេតសេដ្ឋកិច្ច- សង្គមឆ្នាំ ២០១២ ចំនួនការងារក្នុងវិស័យនេះកើនទៅដល់ ១,៤ លានកន្លែង ឬ ស្មើនឹង ១៨,៦% នៃចំនួនការងារសរុប ។ គួរកត់សម្គាល់ថា ចំនួនការងារក្នុងវិស័យឧស្សាហកម្មប្រែប្រួលតាមរដូវកាល ដែលតាមការអង្កេតកម្លាំងពលកម្មនៅរដូវប្រាំងឆ្នាំ ២០១២ បានកើនឡើងរហូតដល់ ១,៨ លានកន្លែង ឬ ស្មើនឹង ២៥,២% នៃចំនួនការងារសរុប ។

កំណើនសេដ្ឋកិច្ចបច្ចុប្បន្ននៅពឹងអាស្រ័យតិចតួចលើការវិនិយោគនៅឡើយ ដែលជាប្រការបញ្ជាក់ថានៅមានលំហនៃការវិនិយោគច្រើនបន្ថែមទៀត ។ ការវិភាគលើវិភាគទានចំពោះ ផសស និង ផ្អែកលើមូលដ្ឋានចំណាយបង្ហាញឱ្យឃើញថា ប្រភពកំណើនជាង ៧០% នៃ ផសស ពឹងផ្អែកលើចំណាយឯកជន, ២៧% ទទួលបានពីការវិនិយោគ, ហើយ ១២%ទៀត ទទួលបានពីចំណាយសាធារណៈរបស់រាជរដ្ឋាភិបាលនិងអង្គការផ្សេងៗ និងសល់ពីនេះ គឺជាការនាំចេញសុទ្ធ ។ បើតាមស្តង់ដារប្រទេសកំពុងអភិវឌ្ឍន៍ ការវិនិយោគត្រូវមានកម្រិតខ្ពស់ពី ៣០% ទៅ ៤០% ឬ អាចខ្ពស់ជាងនេះ ដើម្បីអាចជំរុញសេដ្ឋកិច្ចឱ្យហក់ឡើងខ្ពស់ដល់កម្រិតអភិវឌ្ឍន៍ថ្មី ។ បច្ចុប្បន្ន បើគិតជាជន្ទល់នៃកំណើន កម្ពុជាពឹងផ្អែកសំខាន់លើវិស័យកាត់ដេរ, ទេសចរណ៍, សំណង់ និង វិស័យស្រូវអង្ករ ដែលប្រការនេះ ចង្អុលបង្ហាញអំពីភាពចាំបាច់ត្រូវវិនិយោគច្រើនបន្ថែមទៀត ដើម្បីបង្កើតជន្ទល់កំណើនសេដ្ឋកិច្ចថ្មីៗ ។

ជាមួយគ្នានេះ កំណើនសេដ្ឋកិច្ចក្នុងវិស័យសំខាន់ៗ នៅពឹងអាស្រ័យលើបរិយាកាសខាងក្រៅជាចម្បង ដោយគោលនយោបាយសេដ្ឋកិច្ចមាននិន្នាការប្រតិបត្តិខ្ជាប់ខ្ជួនតាមគោលការណ៍ទីផ្សារ ។ ជាទូទៅ វិស័យដែលជាជន្ទល់សេដ្ឋកិច្ចសំខាន់ៗ ត្រូវបានកំណត់ដោយសកម្មភាពផ្នែកពាណិជ្ជកម្មក្រៅប្រទេស ឧទាហរណ៍ វិស័យកាត់ដេររីកលូតលាស់ឆ្លើយតបនឹងប្រព័ន្ធកូតារបស់សហរដ្ឋអាមេរិក និង សហគមន៍អឺរ៉ុប, វិស័យនាំចេញអង្ករីកចម្រើនក្នុងសន្ទុះថ្មី ដែលពឹងផ្អែកសំខាន់លើកម្មវិធីពាណិជ្ជកម្មរបស់សហគមន៍អឺរ៉ុប និង វិស័យទេសចរណ៍រីកលូតលាស់អាស្រ័យលើមរតកវប្បធម៌ និង ធម្មជាតិ ផ្សារភ្ជាប់នឹងកំណើនប្រាក់ចំណូលទូទៅ ។ កាលានុវត្តភាពទាំងនោះបានជំរុញឱ្យកម្ពុជាខិតខំប្រឹងប្រែងបង្កើតមូលដ្ឋានគ្រឹះសេដ្ឋកិច្ច ដែលចាំបាច់សម្រាប់ការធ្វើទំនើបនីយកម្មនៃវិស័យឧស្សាហកម្មនៅកម្ពុជា ហើយកាលានុវត្តថ្មីៗដែលកំពុងលេចឡើង ក៏ជាឱកាសសម្រាប់កម្ពុជាបន្តជំរុញការអភិវឌ្ឍឧស្សាហកម្មរបស់ខ្លួនឱ្យរីកចម្រើនមួយកម្រិតថែមទៀត ។

ក្នុងន័យនេះ វិស័យឧស្សាហកម្មនឹងដើរតួនាទីសំខាន់សាជាថ្មីក្នុងយុទ្ធសាស្ត្រកំណើន ជាកម្លាំងចលករក្នុងការទ្រទ្រង់កំណើនរយៈពេលមធ្យមទៅវែង, ជាវិស័យសក្តានុពលសម្រាប់បង្កើតការងារ ពិសេសសម្រាប់យុវជន, និង ជាជន្ទល់កំណើនសេដ្ឋកិច្ចថ្មី ដែលនឹងស្រូបការវិនិយោគបន្ថែម ក្រៅពីវិស័យកសិកម្ម និង ទេសចរណ៍ ។ ដើម្បីអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ឱ្យទទួលបានជោគជ័យ រាជរដ្ឋាភិបាលនឹងខិតខំទ្រទ្រង់ផងក្នុងការអភិវឌ្ឍធនធានមនុស្ស, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និង ការអភិវឌ្ឍ/ការផ្ទេរ/ការប្រើប្រាស់បច្ចេកវិទ្យា, ក៏ដូចជា ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចចំណេះដឹង និង ការកែទម្រង់រចនាសម្ព័ន្ធស្ថាប័នចាំបាច់ ។

## ២) - ស្ថានភាពឧស្សាហកម្មនៅកម្ពុជា

### *២-១) - ទិដ្ឋភាពរួមនៃរចនាសម្ព័ន្ធឧស្សាហកម្ម*

ស្ថានភាពឧស្សាហកម្មកម្ពុជានៅមានសភាពទន់ខ្សោយ ដែលឆ្លុះបញ្ចាំងអំពីរចនាសម្ព័ន្ធផលិតកម្មសាមញ្ញ និង តូចចង្អៀត ព្រមទាំងប្រមូលផ្តុំជុំវិញផលិតកម្មសម្លៀកបំពាក់ និង ការកែច្នៃអាហារ ហើយមូលដ្ឋានផលិតភាគច្រើនមានលក្ខណៈគ្រួសារ ដែលសហគ្រិនភាព និង ការប្រើប្រាស់បច្ចេកវិទ្យាមានកម្រិតទាប ដោយមិនទាន់មានសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ។ ជាមួយគ្នានេះ ឧស្សាហកម្មកម្ពុជាមានលក្ខណៈសម្បត្តិសំខាន់ៗមួយចំនួន ដូចជា មូលដ្ឋានឧស្សាហកម្មមិនសូវសំបូរបែប, រចនាសម្ព័ន្ធឧស្សាហកម្មប្រហោងកណ្តាល និងក្រៅផ្លូវការ, សហគ្រិនភាពនៅទន់ខ្សោយ និងប្រមូលផ្តុំតែនៅទីក្រុង និង តម្លៃបន្ថែមទាប និងបច្ចេកវិទ្យាទន់ខ្សោយ ។

*<u>ក- មូលដ្ឋានឧស្សាហកម្មមិនសូវសំបូរបែប</u>*

ផ្អែកតាម ផសស នៅក្នុងវិស័យឧស្សាហកម្ម មានសកម្មភាពបីសំខាន់ គឺ ការផលិតសម្លៀកបំពាក់, សំណង់ និង ការផលិតម្ហូបអាហារ/ភេសជ្ជៈ ។ វិស័យដ៏ទៃផ្សេងទៀតមិនទាន់រីកលូតលាស់គួរឱ្យកត់សម្គាល់នៅឡើយ ចំណែកតួនាទីសេដ្ឋកិច្ចនៃវិស័យកែច្នៃឈើ ក្រដាស និង ការបោះពុម្ព មាននិន្នាការធ្លាក់ចុះ ។ វិស័យកាត់ដេរដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យឧស្សាហកម្ម ដែលមានចំណែកស្មើនឹង ៨,២ % នៅឆ្នាំ ១៩៩៣ បានកើនឡើងរហូតដល់ ៥១,៨% នៅឆ្នាំ ២០០៤ ដែលជាឆ្នាំមានកំណើនខ្ពស់បំផុត ។ ក្រោយមក វិស័យនេះបានធ្លាក់ចុះបន្តិច ដែលនៅឆ្នាំ ២០១៣ ចំណែកនៃវិស័យនេះមានទំហំ ៤២,៤ % នៃ ផសស វិស័យឧស្សាហកម្ម ។ វិស័យសំណង់ដែលមានចំណែកប្រមាណ ៣០% នៃឧស្សាហកម្ម នៅឆ្នាំ ១៩៩៣ បានធ្លាក់ចុះទាបបំផុតក្នុងឆ្នាំ ១៩៩៨ ដែលមានទំហំ ២០,២ % ប៉ុន្តែមាន កំណើនឡើងវិញជាបន្តបន្ទាប់នៅឆ្នាំ ២០១៣ ដែលចំណែកវិស័យនេះមានទំហំ ៣០,១ % ។ ដោយឡែកវិស័យផលិតកម្មម្ហូបអាហារ និង គ្រឿងបរិភោគ បានថយចុះជាបន្តបន្ទាប់ពីប្រមាណ ៣២,៧ % នៅឆ្នាំ ១៩៩៣ មកត្រឹម រង្វង់ ១០ % នៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ។

ជារួម សហគ្រាសកម្ពុជាស្ថិតនៅជាការលក់រាយ និង សេវាភោជនីយដ្ឋាន ។ ក្នុងចំណោមសហគ្រាសសរុបប្រមាណ ៥១ ម៉ឺនកន្លែង, សហគ្រាសកម្មន្តសាលមានប្រមាណតែ ៧ ម៉ឺនកន្លែង ឬ ១៤% ក្នុងនោះ ៤៥% ជាប្រភេទសហគ្រាសកែច្នៃចំណីអាហារ និងភេសជ្ជៈ ហើយ ៣៥% ជាសហគ្រាសវាយនភ័ណ្ឌ និង កាត់ដេរសម្លៀក

បំពាក់ ។ គួរកត់សម្គាល់ថា សហគ្រាសឧស្សាហកម្មធុនធំប្រមាណ ៨០% ស្ថិតក្នុងវិស័យវាយនភ័ណ្ឌ, កាត់ដេរសម្លៀកបំពាក់ និងផលិតកម្មស្បែកជើង ។ រចនាសម្ព័ន្ធឧស្សាហកម្មកម្មន្តសាលបែបនេះ ស្ថិតក្នុងកម្រិតអភិវឌ្ឍន៍ទាប ដោយសារផលិតកម្មវាយនភ័ណ្ឌ កាត់ដេរសម្លៀកបំពាក់ និង ការផលិតចំណីអាហារ ជាទូទៅមានតម្លៃបន្ថែមទាប និង ប្រព័ន្ធផលិតកម្មមិនសូវស្មុគស្មាញ ។ ផលិតកម្មសម្ភារៈសំណង់, សម្ភារៈអេឡិចត្រូនិច, គ្រឿងម៉ាស៊ីន និង គ្រឿងចក្រ, ផលិតផលគីមី, ការផ្គុំដំឡើងម៉ូតូ រថយន្ត សម្ភារៈប្លាស្ទិក និង ឧបករណ៍បរិក្ខារប្រើប្រាស់ផ្សេងទៀត ក៏នៅមានកម្រិតទាបនៅឡើយ ហើយការផលិតទៀតសោតគឺគ្រាន់តែជំនួសការនាំចូលបន្តិចបន្តួចប៉ុណ្ណោះ ។ ដោយឡែកក្នុងទិដ្ឋភាពបែងចែកកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម, មានកម្មករប្រមាណ ៥០% បម្រើការងារក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ និង ការផលិតស្បែកជើង, ប្រមាណ ២៥% នៅក្នុងវិស័យសំណង់, ជិត ១០% នៅក្នុងវិស័យកែច្នៃម្ហូបអាហារ និង ភេសជ្ជៈ ហើយប្រមាណ ១៣% ផ្សេងទៀត នៅក្នុងវិស័យកម្មន្តសាលផ្សេងៗ (អង្កេតសេដ្ឋកិច្ច- សង្គមឆ្នាំ ២០០៧-២០១២) ។ រចនាសម្ព័ន្ធបែងចែកកម្លាំងពលកម្មនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងរចនាសម្ព័ន្ធតម្លៃបន្ថែម ។

ផ្អែកលើរចនាសម្ព័ន្ធនៃការនាំចេញ, ក្នុងរយៈពេលពីឆ្នាំ២០០០-២០០៨ ទំនិញសម្លៀកបំពាក់ និងស្បែកជើងនាំចេញមានទំហំ ៧៥,៦% និងការនាំចេញឈើ/ផលិតផលឈើមានទំហំ ២៧% នៃការនាំចេញសរុប ។ ប៉ុន្តែចាប់ពីឆ្នាំ ២០០៩-២០១៣ ការនាំចេញឈើ និង ផលិតផលកែច្នៃពីឈើមានកំណើនខ្លាំង ហើយជាចំណែក បានកើនឡើងជាមធ្យមប្រចាំឆ្នាំជាង ៣០%, ចំណែកវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង បានធ្លាក់ចុះ មកត្រឹម ៥៨%។ មុខទំនិញបីប្រភេទ រួមមាន កសិផល, កៅស៊ូ និង មធ្យោបាយដឹកជញ្ជូន ក៏មានចំណែកខ្ពស់ក្នុងការនាំចេញ ។ ជាក់ស្តែង ការនាំចេញកសិផល ពិសេស ស្រូវ/អង្ករ បានកើនឡើងដល់ ៤,៣៦% នៃការនាំចេញ ឆ្នាំ ២០១៣ ។ លើសពីនេះ ក៏មានការចាប់ផ្តើមលេចឡើងនូវការនាំចេញផ្នែកកម្មន្តសាលធុនស្រាល រួមមាន ទោចក្រយាន, ខ្សែភ្លើង, ម៉ូទ័រអេឡិចត្រូនិច, សៀគ្វី, គ្រឿងទូរទស្សន៍, សម្ភារៈក្មេងលេង, សង្ហារឹម, វ៉ីស័រ និងគ្រឿងខ្មៅ ជាដើម។

សរុបមក វិស័យកម្មន្តសាលមានលក្ខណៈប្រមូលផ្តុំមិនសូវសម្បូរបែប ដែលឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈសមាមាត្រនៃសហគ្រាសឧស្សាហកម្មធៀបនឹងចំនួនសហគ្រាសសរុប, វិភាគទានតម្លៃបន្ថែមនៅក្នុង ផសស និង មុខទំនិញបម្រើការនាំចេញ ។ វិស័យកម្មន្តសាលកម្ពុជា រួមមាន វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ព្រមទាំង ការផលិតម្ហូបអាហារ/ភេសជ្ជៈ ក្នុងនោះ វិស័យសំណង់មានការរីកចម្រើនគួរឱ្យចាប់អារម្មណ៍ ។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងជំរុញកំណើនក្នុងរយៈពេលមធ្យម នឹងត្រូវផ្តោតសំខាន់លើការពង្រីកមូលដ្ឋានផលិតកម្ម និង ការធ្វើពិពិធកម្មមុខទំនិញឧស្សាហកម្មបម្រើការនាំចេញ ។

*ខ- រចនាសម្ព័ន្ធឧស្សាហកម្មប្រហោងកណ្តាល និង ក្រៅផ្លូវការ*

ក្នុងវិស័យឧស្សាហកម្ម សហគ្រាសធុនមីក្រូមានចំនួនជិត ៩៧,៣%, ធុនតូច និង មធ្យមមានជាង ២,២% និងធុនធំ ០,៦% ។ ក្នុងចំណោមសហគ្រាសទាំងនេះ ចំនួនសហគ្រាសកម្មន្តសាលមានដល់ទៅ ៩១,៧% ។

បើគិតក្នុងបរិការណ៍នៃកម្លាំងពលកម្មវិញ សហគ្រាសធុនធំស្រូបយកកម្លាំងពលកម្ម ៦៣,៣% ធុនមីក្រូ ស្រូបយក ២៩,៣% និង សហគ្រាសធុនតូចនិងមធ្យមស្រូបយក ៧,៤% ។ ប៉ុន្តែក្នុងន័យផលរបរវិញ សហគ្រាសធុនធំបង្កើតផលរបរបានរហូតដល់ ៧៦% ចំណែកសហគ្រាសធុនមីក្រូបង្កើតផលរបរបានតែ ១២% គឺស្មើគ្នានឹងសហគ្រាសធុនតូច និងមធ្យម ។

**តារាងទី ១ : សហគ្រាសកម្មន្តសាលនៅកម្ពុជាបែងចែកតាមទំហំ**

| | ធុនមីក្រូ (១-១០ន) | ធុនតូច (១១-៥០ន) | ធុនមធ្យម (៥១-១០០ន) | ធុនធំ (១០០ន+) |
|---|---|---|---|---|
| ចំនួនសហគ្រាស | 69,851 | 5,861 | 530 | 609 |
| ***-ភាគរយសរុប*** | ***97.3%*** | ***1.9%*** | ***0.2%*** | ***0.6%*** |
| ចំនួនកម្លាំងពលកម្ម | 162,335 | 28,706 | 11,949 | 350,260 |
| ***-ភាគរយសរុប*** | ***29.3%*** | ***5.2%*** | ***2.2%*** | ***63.3%*** |
| ផលរបរសរុប (លានដុល្លារ) | 396 | 300 | 94.4 | 2,500 |
| ***-ភាគរយសរុប*** | ***12.0%*** | ***9.1%*** | ***2.9%*** | ***76.0%*** |

*ប្រភព: ជំរឿនសហគ្រាស (២០១១)*

រចនាសម្ព័ន្ធឧស្សាហកម្មខាងលើ មានភាពផុយស្រួយ ដោយសារការពឹងអាស្រ័យខ្លាំងពេកលើសហគ្រាសធុនធំ ។ ករណីបាត់បង់រោងចក្រធំៗ មួយ ឬ ពីរ អាចនឹងប៉ះពាល់ដោយផ្ទាល់ដល់ស្ថានភាពទីផ្សារការងារ និងកំណើនសេដ្ឋកិច្ចជាតិ។ រចនាសម្ព័ន្ធឧស្សាហកម្មបែបនេះ ក៏ងាយនឹងបាត់បង់ភាពប្រកួតប្រជែងផងដែរ ដោយសារគ្មានការគាំទ្រពីសហគ្រាសធុនតូចនិងមធ្យម ប្រសិនបើបាត់បង់លក្ខខណ្ឌអំណោយផលផ្នែកពាណិជ្ជកម្ម ឬ ការប្រែប្រួលរចនាសម្ព័ន្ធថ្លៃដើម ។

ក្នុងចំណោមសហគ្រាសធុនមីក្រូទាំងអស់ ៩៨,៦៤ % មិនបានចុះបញ្ជីផ្លូវការ, ប៉ុន្តែអត្រាមិនចុះបញ្ជីនេះធ្លាក់ចុះតាមទំហំនៃសហគ្រាស ។ សម្រាប់សហគ្រាសធុនតូច មាន ៦២,៨៣% មិនចុះបញ្ជីផ្លូវការ ២៨,៥៧% សម្រាប់ធុនមធ្យម និង មានតែ ៧,០៤% ប៉ុណ្ណោះសម្រាប់សហគ្រាសធុនធំ ។ ម្យ៉ាងទៀត សហគ្រាសដែលមានបញ្ជីគណនេយ្យ នៅមានតិចតួច ដោយក្នុងនោះសហគ្រាសធុនមីក្រូមានតែ ០,០២%, សហគ្រាសធុនតូចមាន ៣,៨៩ %, សហគ្រាសមធ្យមមានតែ ២៤,១១% និងសហគ្រាសធុនធំ ៦៦,១៩% ។ អវត្តមាននៃបញ្ជីគណនេយ្យជាឧបសគ្គសំខាន់រារាំងសហគ្រាសមិនអាចទទួលបានឥណទាន សម្រាប់ពង្រីកសកម្មភាព ឬ ប្រើប្រាស់បច្ចេកទេសថ្មី ។ ម្យ៉ាងវិញទៀត ការគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះសកម្មភាពរបស់សហគ្រាសទាំងនោះ អាចធ្វើទៅបានដ៏រាបណាសហគ្រាសនោះបានចុះបញ្ជីជាផ្លូវការ និង បានរក្សាបញ្ជីកាគណនេយ្យច្បាស់លាស់ សម្រាប់ជាមូលដ្ឋានវាយតម្លៃ ។

*គ- សហគ្រិនភាពនៅទន់ខ្សោយ និង ប្រមូលផ្តុំតែនៅទីក្រុង*

សហគ្រិនភាព ឆ្លុះបញ្ចាំងតាមរយៈភាពក្មេងខ្ចី និង កម្រិតកម្មសិទ្ធិលើសហគ្រាស ។ ជិតពាក់កណ្តាលសហគ្រាសទាំងអស់ (៤២%) ដែលកំពុងដំណើរការនៅកម្ពុជាទើបបានបង្កើតឡើងចាប់ពីឆ្នាំ ២០០៨ ។ បើគិតចាប់តាំងពីឆ្នាំ ២០០៣ វិញ មានសហគ្រាសរហូតដល់ ៦៨,៣៩% ដែលទើបបង្កើត ហើយស្ថានភាពដូចគ្នានេះក៏មាននៅតាមអនុវិស័យឧស្សាហកម្មនីមួយៗ ។

ក្នុងចំណោមសហគ្រាសទាំងអស់ដែលបានជំរឿន មានសហគ្រាសធុនធំជិត ៦៣% និង សហគ្រាសធុនមធ្យម ៣៧,១៤% ជាការវិនិយោគបរទេស ។ ដោយឡែក កម្ពុជាជាម្ចាស់កម្មសិទ្ធិលើសហគ្រាសធុនមីក្រូ និង ធុនតូច ដែលមានរហូតដល់ ៩៩% និង ៩៤%។ យោងតាមទិន្នន័យការអង្កេតបរិយាកាសវិនិយោគនៅកម្ពុជា (ឆ្នាំ ២០០៣ និង ២០០៧) ក្នុងចំណោមក្រុមហ៊ុននាំចេញចំនួន ១៦៤ កន្លែង មានដល់ទៅ ៩៣% បានចាប់ផ្តើមធ្វើការនាំចេញនៅឆ្នាំដំបូងនៃការបង្កើតក្រុមហ៊ុន ដែលឆ្លុះបញ្ចាំងពីការវិនិយោគដើម្បីចូលក្នុងទីផ្សារអន្តរជាតិ និង រចនាសម្ព័ន្ធនៃឧស្សាហកម្មដាច់ពីគ្នា រវាងការនាំចេញ និងផលិតកម្មគាំទ្រទីផ្សារក្នុងស្រុក ។ ប្រការនេះក៏ឆ្លុះបញ្ចាំងពីនិន្នាការស្របគ្នា ដែលនៅពេលការនាំចេញកើនឡើងខ្ពស់ ការនាំចូលក៏កើនឡើងខ្ពស់ផងដែរ ។ ជាលទ្ធផលក្នុងវិស័យកាត់ដេរដែលបានអភិវឌ្ឍជិត ២០ ឆ្នាំ ប៉ុន្តែសហគ្រិនកម្ពុជាមានចំនួនតិចតួចនៅឡើយ ទោះបីវិស័យនេះត្រូវបានចាត់ទុកថាមានការប្រកួតប្រជែងខ្ពស់ ហើយខ្សែចង្វាក់តម្លៃ និង ខ្សែចង្វាក់ផលិតកម្មមានលក្ខណៈសាមញ្ញក្តី នៅឆាកតំបន់ និងអន្តរជាតិ ។

លើសពីនេះ សហគ្រាសកម្មន្តសាលកម្ពុជាមានលក្ខណៈប្រមូលផ្តុំ ។ យោងតាមជំរឿនសហគ្រាស (២០១១) សហគ្រាសកម្មន្តសាលធុនធំប្រមាណ ៦៨% មានទីតាំងនៅរាជធានីភ្នំពេញ និង ១៣% នៅខេត្តកណ្តាល ។ ដោយឡែក នៅខេត្តកំពង់ចាម កំពង់ស្ពឺ ព្រះសីហនុ និង ស្វាយរៀង កំពុងក្លាយជាទីតាំងសម្រាប់សហគ្រាសធុនធំ ដែលមានសហគ្រាសកម្មន្តសាលធុនធំប្រមាណ ១២% ។ ការប្រមូលផ្តុំមានការធ្លាក់ចុះទៅតាមទំហំសហគ្រាស ជាពិសេសសហគ្រាសធុនមីក្រូរាយប៉ាយសឹងគ្រប់កន្លែង និងគ្រប់ខេត្តទៅតាមដង់ស៊ីតេប្រជាជន។ ដោយឡែកសហគ្រាសធុនតូច និង មធ្យម ប្រមូលផ្តុំនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និង កំពង់ចាម ។ ការប្រមូលផ្តុំនេះកើតឡើង ដោយសារមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បណ្តាញអគ្គិសនី និង សេវាសាធារណៈដែលបម្រើឱ្យផលិតកម្ម និង ការនាំចេញ ។ ប៉ុន្តែ ឧស្សាហកម្មមិនត្រូវរាយប៉ាយគ្រប់ទីកន្លែងពេកទេ ដែលធ្វើឱ្យបាត់បង់ឥទ្ធិពលសំយោគ ក៏ដូចជាការគាំទ្រ និង បំពេញគ្នាទៅវិញទៅមក ក្នុងចំណោមសហគ្រាសទាំងនោះ ។ ក្នុងន័យនេះ ការជំរុញការបង្កើតតំបន់ប្រមូលផ្តុំឧស្សាហកម្ម នៅតាមបណ្តាខេត្តមួយចំនួន ក្រៅពីទីក្រុងភ្នំពេញ ត្រូវយកចិត្តទុកដាក់ ។ ជាងនេះទៀត ការធ្វើវិមជ្ឈការសេវាសាធារណៈឱ្យទៅដល់មូលដ្ឋានផលិតកម្ម ដើម្បីសម្របសម្រួល និង ផ្តល់ការគាំទ្រដល់ប្រតិបត្តិការវិនិយោគ ជាការងារគាំទ្រចាំបាច់ ។

*ឃ- តម្លៃបន្ថែមទាប និង បច្ចេកវិទ្យាទន់ខ្សោយ*

ឧស្សាហកម្មកម្ពុជា នៅមានលក្ខណៈសាមញ្ញដោយគ្រាន់តែជាការទទួលផលពីកម្លាំងពលកម្មប៉ុណ្ណោះ ពីព្រោះផ្តោតតែលើខ្សែចង្វាក់ផលិតកម្មណាមួយដែលប្រើប្រាស់កម្លាំងពលកម្មច្រើន និងការងារមិនសូវស្មុគ្រស្មាញ ។ ឧទាហរណ៍ ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ រោងចក្រភាគច្រើនប្រមាណ ៦០% ស្ថិតក្នុងខ្សែចង្វាក់ផលិតកម្ម កាត់- ដេរ- តម្រឹម (CMT) ហើយមានរោងចក្រប្រមាណតែ ១ ក្នុងចំណោម ៤ ដែលបន្តការងាររហូតដល់ខ្សែ-ចង្វាក់ផលិតកម្មប៉ាក់- បោក- វេច ខ្ចប់ និង នាំចេញជាផលិតផលសម្រេច ។ កម្ពុជាមិនទាន់អាចត្បាញក្រណាត់ ឬ ហូតអំបោះនៅឡើយ ដោយសារខ្សែចង្វាក់ផលិតកម្មបែបនេះ ត្រូវការការផ្គត់ផ្គង់អគ្គិសនីទៀងទាត់អាចទុកចិត្តបាន និងមានតម្លៃទាប ដែលជាហេតុនាំឱ្យវិស័យកាត់ដេរត្រូវនាំចូលវត្ថុធាតុដើមពីបណ្តាប្រទេសផ្សេងទៀតនៅអាស៊ី ។ ប្រការនេះ នៅមិនទាន់គិតដល់ការផលិតសម្ភារៈវេចខ្ចប់ ដែលទើបចាប់ផ្តើមមានការវិនិយោគជាបណ្តើរៗ ។ នៅក្នុងអនុវិស័យដ៏ទៃផ្សេងទៀត ក៏មានលក្ខណៈស្រដៀងគ្នានេះដែរ ខ្សែចង្វាក់ផលិតកម្មមានត្រឹមតែ កាត់- ដេរ-បិទ- ផ្គុំ តែប៉ុណ្ណោះ ។ ចំពោះរោងចក្រផ្គុំដំឡើងវិញ មានការងារត្រឹមដាក់ផ្គុំផ្នែកផ្សេងៗដែលមានស្រាប់ដំឡើង និង រឹតមួលខ្ចៅ ។ ការងារទាំងនេះ ពុំមានលក្ខណៈស្មុគ្រស្មាញ និង បង្កើតតម្លៃបន្ថែមតិចតួច ។

ចំណែកសហគ្រាសក្នុងស្រុកវិញ ភាគច្រើនផ្តោតលើការកែច្នៃចំណីអាហារ និង ផលិតផលពាក់កណ្តាល-សម្រេច ដែលជាទូទៅប្រើប្រាស់បច្ចេកទេសកម្រិតទាប ។ ឧទាហរណ៍ ក្នុងវិស័យកែច្នៃអង្ករ មុនពេលដែលមានវត្តមាន ***«គោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករឆ្នាំ ២០១០»*** កម្ពុជាមានរោងម៉ាស៊ីនកិនស្រូវខ្នាតអន្តរជាតិតិចតួចប៉ុណ្ណោះ ។ ដូចគ្នានេះ វិស័យកម្មន្តសាលផ្សេងទៀត កំពុងប្រើប្រាស់បច្ចេកទេសចាស់ៗ និងមានផលិតភាពទាបដែលកម្រិតលទ្ធភាពប្រកួតប្រជែង ដូចជា ការផលិតឥដ្ឋ ក្បឿង ឬ ឆ្នាំង ប្រើប្រាស់បច្ចេកទេសអន់ថយ និង ពុំមានការអភិវឌ្ឍមុខទំនិញឱ្យសម្បូរបែប ជារួម កត្តាផលិតភាពទាប គឺជាមូលហេតុចម្បងធ្វើឱ្យវិស័យកម្មន្តសាលភាគច្រើនបម្រើឱ្យតែការប្រើប្រាស់ក្នុងស្រុកបន្តិចបន្តួច និង មានតម្លៃបន្ថែមទាប ។

### ***២-២)- បញ្ហាប្រឈមគន្លឹះៗ នៃការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា***

*ក)- ភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព*

ការអភិវឌ្ឍវិស័យឧស្សាហកម្ម តម្រូវឱ្យមានការសម្របសម្រួលខ្ពស់ ក្នុងគ្រប់ទិដ្ឋភាព និង គ្រប់កម្រិត រួមទាំងផ្នែកគោលនយោបាយ ស្ថាប័ន និយ័តកម្ម និង ការគ្រប់គ្រង, ផ្នែកហេដ្ឋារចនាសម្ព័ន្ធ, សេវាហិរញ្ញវត្ថុ បច្ចេកទេស និងបច្ចេកវិទ្យា ក៏ដូចជា ការចូលរួមពីវិស័យឯកជន ដែលត្រូវឆ្លើយឆ្លង និង ប្រទាក់ក្រឡាគ្នា ដើម្បីផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធភាពដល់សកម្មភាពឧស្សាហកម្មជាក់ស្តែង ។ ជាមួយគ្នានេះ ការធានាបាននូវការសម្របសម្រួលល្អ នឹងរួមចំណែកធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ, បង្កើនទំនុកចិត្តក្នុងចំណោមវិនិយោគិន និងលើកស្ទួយកិត្តិនាមរបស់ប្រទេស ជាគោលដៅវិនិយោគសំខាន់នៅក្នុងតំបន់ ។

កន្លងមក កម្ពុជាពុំទាន់មានគោលនយោបាយ, យុទ្ធសាស្ត្រ និង ទិសដៅច្បាស់លាស់ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅឡើយ ។ ការអភិវឌ្ឍវិស័យនេះ ចំណុះលើលក្ខខណ្ឌទីផ្សារជាសំខាន់ និង ផ្តោតលើទិដ្ឋភាពទូទៅ គ្រប់ទីកន្លែង និង គ្រប់តំបន់ទូទាំងប្រទេស ។ ដោយហេតុនេះ ការអភិវឌ្ឍអាចមានលក្ខណៈដាច់ដោយដុំៗ ឬ ប្រមូលផ្តុំខ្លាំងពេកលើវិស័យ ឬ តំបន់ណាមួយ ដែលនាំឱ្យមានភាពមិនឆ្លើយឆ្លងគ្នារវាងសក្តានុពលវិនិយោគ, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ការផ្តល់សេវាសាធារណៈ និង ការផ្គត់ផ្គង់កម្លាំងពលកម្ម ជាដើម ។ ក្នុងន័យនេះ កន្លែងដែលវិនិយោគិនយល់ថាមានសក្តានុពលសម្រាប់ឧស្សាហកម្ម រាជរដ្ឋាភិបាលត្រូវជំរុញការវិនិយោគសាធារណៈឱ្យគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាសាធារណៈដែលចាំបាច់សម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម ក៏ដូចជាការរៀបចំជីវភាពរស់នៅរបស់ពលករ ។ ការសម្របសម្រួល ដើម្បីប្រមូលផ្តុំធាតុផ្សំទាំងអស់បញ្ចូលគ្នា គឺជាប្រការចាំបាច់ ដើម្បីបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ការចាប់កំណើត និង ការរីកលូតលាស់នៃវិស័យឧស្សាហកម្ម ។

ក្នុងក្របខណ្ឌនិយ័តកម្ម ការគ្រប់គ្រងឧស្សាហកម្ម និង វិនិយោគ, ប្រព័ន្ធពន្ធដារ, របបពាណិជ្ជកម្ម និង ការដឹកជញ្ជូន ព្រមទាំងរបបនិយ័តកម្មពាក់ព័ន្ធផ្សេងទៀត ចាំបាច់ត្រូវសម្របសម្រួល និង រៀបចំឱ្យស៊ីចង្វាក់គ្នា ។ កន្លងមក ការសម្របសម្រួលក្នុងចំណោមនិយ័តករផ្សេងៗ ពុំទាន់មានដំណើរការបានល្អ និងពេលខ្លះមានគោលដៅផ្សេងថែមទៀត ។ ជាក់ស្តែង ដូចជា ប្រព័ន្ធពន្ធដារផ្តោតខ្លាំងពេកលើការប្រមូលចំណូល, ប្រព័ន្ធពាណិជ្ជកម្មផ្តោតលើការបើកចំហទីផ្សារ, ក្របខណ្ឌប្រកួតប្រជែងមានលក្ខណៈមិនច្បាស់លាស់, គោលនយោបាយដឹកជញ្ជូនមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយ ជាដើម ។ល។ ការសម្របសម្រួលមិនបានល្អបែបនេះ នាំឱ្យមានការលំបាកដល់ការកំណត់ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** និង ជាឧបសគ្គដល់ការប្រមូលផ្តុំធនធានឱ្យបានគ្រប់គ្រាន់ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍវិស័យនេះ ។

ការសម្របសម្រួលផ្នែកព័ត៌មានច្បាស់លាស់ និង បើកទូលាយ មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដើម្បីធានាការសម្រេចចិត្តត្រឹមត្រូវក្នុងការវិនិយោគ ។ ការផ្តល់ព័ត៌មានមិនច្បាស់លាស់ធ្វើឱ្យការវិនិយោគមានការខ្វះខាត និង បាត់បង់ឱកាស ។ ក្នុងស្ថានភាពបែបនេះ ចាំបាច់ត្រូវបង្កើតឱ្យមានយន្តការច្បាស់លាស់ក្នុងការទទួលបាននូវព័ត៌មាន ដែលអាចកាត់បន្ថយចំណាយក្នុងការស្វែងរកព័ត៌មានវិនិយោគ និង បើកលទ្ធភាពឱ្យមានការចូលរួមបានទូលំទូលាយ ដែលនឹងជួយគាំទ្រឱ្យការអភិវឌ្ឍឧស្សាហកម្មប្រព្រឹត្តទៅដោយរលូន មានការប្រកួតប្រជែង និងមាននិរន្តរភាព ។ ការផ្តល់នូវព័ត៌មានទូលាយសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ក៏រួមចំណែកដល់ការបង្កើតនូវគំនិតថ្មីៗបន្ថែមទៀតសម្រាប់ការរៀបចំស្ថាប័ន, ការតាក់តែងគោលនយោបាយយុទ្ធសាស្ត្រ និង ក្របខណ្ឌនិយ័តកម្មផងដែរ ។

ទោះបីបរិយាកាសវិនិយោគ និង ធុរៈកិច្ចល្អជាលក្ខខណ្ឌចាំបាច់យ៉ាងណាក្តី តួនាទីរបស់រដ្ឋនឹងរឹតតែសំខាន់ក្នុងការតម្រង់ទិស ដឹកនាំ សម្របសម្រួល និង គាំទ្រដល់វិស័យឯកជន ។ ការអភិវឌ្ឍវិស័យឧស្សាហកម្មទាមទារ

ការដឹកនាំ និង ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ដែលត្រូវមានស្ថាប័ននាំមុខ, សកម្ម និង ប្រកបដោយវិជ្ជាជីវៈខ្ពស់ ដើម្បីធានាកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគំនិតផ្តួចផ្តើមនានា ក៏ដូចជាវិធានការគោលនយោបាយឱ្យទទួលបានជោគជ័យ ។ ការដឹកនាំ និងការសម្របសម្រួលបែបនេះ មានទាំងក្នុងស្ថាប័នរដ្ឋ, ស្ថាប័នឯកជន និង សហគមន៍ ដែលអាចផ្តួចផ្តើមឱ្យមានការចូលរួមសស្រាក់សស្រាំ តាមតួនាទីរៀងៗខ្លួន និង មានការទទួលខុសត្រូវខ្ពស់ ដើម្បីជំរុញការងារទៅមុខប្រកបដោយប្រសិទ្ធភាព ។ ដូច្នេះ ចំណុចសំខាន់ គឺការរៀបចំពង្រឹងស្ថាប័នរដ្ឋឱ្យមានការទទួលខុសត្រូវច្បាស់លាស់ និង ការរៀបចំចងក្រងឧស្សាហករជាយន្តការការងារសម្រាប់ការផ្លាស់ប្តូរព័ត៌មាន, ការតស៊ូមតិ និង កិច្ចសហប្រតិបត្តិការដើម្បីធានាផលប្រយោជន៍រួម ក៏ដូចជា ការផ្សព្វផ្សាយដល់សហគមន៍ធុរជនជាតិនិងអន្តរជាតិ ឱ្យចូលរួមសកម្មក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ។

លើសពីនេះ សម្រាប់វិស័យឧស្សាហកម្មអាទិភាព ក៏កម្ពុជានៅមិនទាន់មានស្ថាប័នសម្របសម្រួល ដើម្បីដឹកនាំ និងពញ្ញាក់ស្មារតី ឱ្យស្ថាប័នទទួលខុសត្រូវយកចិត្តទុកដាក់អំពីវឌ្ឍនភាព ពិសេស ដោះស្រាយនូវកង្វល់ទាំងឡាយដែលកើតឡើងជាក់ស្តែងនៅក្នុងប្រតិបត្តិការ ។ ជាបទពិសោធន៍ ស្ថាប័នភាគច្រើនរុញការទទួលខុសត្រូវឱ្យគ្នាទៅវិញទៅមក ដោយព្យាយាមគេចចេញពីបញ្ហា ដោយបណ្តោយឱ្យបញ្ហាងាយស្រួលក្លាយជាស្មុគ្រស្មាញ ។ ក្នុងន័យនេះ ស្ថាប័នសម្របសម្រួលត្រូវមានសមត្ថភាពផ្តល់ការគាំទ្រ ដូចជា ជំនួយបច្ចេកទេស, ការបណ្តុះបណ្តាល និង ការវិនិយោគចាំបាច់សម្រាប់សកម្មភាពជាក់លាក់ណាមួយ ប្រសិនបើពិនិត្យឃើញថា ស្ថាប័នទទួលបន្ទុកពុំអាចអនុវត្តបាន ព្រមទាំងត្រូវមានយន្តការត្រួតពិនិត្យ ដើម្បីដាក់សម្ពាធឱ្យស្ថាប័នទទួលខុសត្រូវចាត់វិធានការដោះស្រាយ និង កែតម្រូវ ។

*__ខ)- មូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេស និង ជំនាញ__*

ការបង្កើតម៉ាស់ និងភាពចម្រុះចាំបាច់នៃកម្មករជំនាញ, អ្នកបច្ចេកទេស, វិស្វករ និង អ្នកវិទ្យាសាស្ត្រ គឺជាកត្តាមិនអាចខ្វះបាន ក្នុងការជំរុញការអភិវឌ្ឍវិស័យកម្មន្តសាល ។ ការបណ្តុះបណ្តាលកម្មករជំនាញ, អ្នកបច្ចេក-ទេស និង វិស្វករ តិចតួចពេក នឹងដាក់កំហិតលើសមត្ថភាពស្រូប, ប្រើប្រាស់ និង អភិវឌ្ឍបច្ចេកទេស/បច្ចេកវិទ្យាទំនើបក្នុងវិស័យឧស្សាហកម្ម ដោយសារត្រូវពឹងផ្អែកលើអ្នកជំនាញពីខាងក្រៅដែលត្រូវចំណាយខ្ពស់ ។ ប្រការនេះគឺជាឧបសគ្គសំខាន់មួយចំពោះសមត្ថភាពប្រកួតប្រជែងនៃឧស្សាហកម្មកម្ពុជា ដែលចាំបាច់ត្រូវមានគោលនយោ-បាយអភិវឌ្ឍន៍ធនធានមនុស្ស និង ការវិនិយោគសមស្រប ។

ជារួម ការបណ្តុះបណ្តាលជំនាញនៅមិនទាន់គ្រប់គ្រាន់នៅឡើយសម្រាប់បម្រើឱ្យវិស័យឧស្សាហកម្ម ហើយប្រការនេះក៏ធ្វើឱ្យផលិតភាពនៅទាបផងដែរ ។ កម្លាំងពលកម្មកម្ពុជាភាគច្រើនស្ថិតក្នុងវិស័យកសិកម្ម ឬ សេវាកម្ម ហើយការប្រែក្លាយកម្លាំងពលកម្មទាំងនេះទៅបម្រើឱ្យវិស័យឧស្សាហកម្ម ទាមទារនូវការផ្លាស់ប្តូរសំខាន់មួយក្នុងទីផ្សារពលកម្ម រួមទាំង របៀបរបបនៃការជ្រើសរើសពលករ, ការបណ្តុះបណ្តាលជំនាញ, ការបណ្តុះទម្លាប់ និង វិន័យការងារ ព្រមទាំងការរំពឹងទុកអំពីតម្រូវការនៃវិស័យនេះផងដែរ ។ នៅពេលដែលកម្រិតសិក្សាមូលដ្ឋានរបស់

ពលករទាប ការបណ្តុះបណ្តាលត្រូវការពេលវេលា និងការអត់ធ្មត់ច្រើន ។ ដូច្នេះ ការពង្រឹងយន្តការជ្រើសរើសកម្លាំងពលកម្មផ្លូវការ ដោយមានការបណ្តុះបណ្តាលច្បាស់លាស់ ចាំបាច់ត្រូវតែពង្រឹង ដើម្បីជៀសវាងការប្រើប្រាស់ក្រៅផ្លូវការដែលដាក់កម្មករឱ្យក្លាយជាចំណាប់របស់សហជីព ទាំងគុណស្រ័យ និងបំណុល ។ ក្នុងន័យនេះ ប្រព័ន្ធនិយ័តកម្មនៃការជ្រើសរើស និងប្រើប្រាស់កម្លាំងពលកម្ម ចាំបាច់ត្រូវកែលម្អឱ្យបានល្អប្រសើរ ។

អត្រាបោះបង់ការសិក្សានៅមានកម្រិតខ្ពស់ ដែលជំរុញឱ្យកម្ពុជាអាចស្លាក់ជាប់ក្នុងឧស្សាហកម្មអតិពលកម្ម និង មានផលិតភាពទាប ។ ក្នុងទិដ្ឋភាពនៃការកសាងមូលដ្ឋានបច្ចេកទេស ការសិក្សាគួរត្រូវបញ្ចប់យ៉ាងហោចណាស់នៅថ្នាក់ទី ៩ ដើម្បីមានគ្រឹះរឹងមាំសម្រាប់ឈោងចាប់យកបច្ចេសទេស ដែលអាចជំរុញការស្រូបយក និងការកសាងបច្ចេកវិទ្យា ។ ក្នុងទិដ្ឋភាពនៃផលិតភាព ការអប់រំទាបពេកគឺជាការខាតបង់ផ្នែកផលិតភាពក្នុងរយៈពេលវែង ហើយកម្មករគ្មានលទ្ធភាពក្នុងការឈោងចាប់ជំនាញថ្មី ហើយសុខចិត្តទទួលយកការងារដែលមានកម្រៃទាប ។ ក្នុងន័យនេះ គោលនយោបាយត្រូវបើកឱកាសទូលាយជូនពលករ ក្នុងការរៀនសូត្របន្ត និង ឈោងចាប់ជំនាញថ្មី ។

បរិយាកាសសង្គម ដែលផ្តល់តម្លៃលើបច្ចេកវិទ្យា/វិទ្យាសាស្ត្រ នៅមិនទាន់ផុសផុលនៅឡើយ ដែលប្រការនេះក៏ជាបញ្ហាសម្រាប់ជំរុញទឹកចិត្តឱ្យយុវជនមានមោទនភាព និង តម្រង់ទិសឱ្យពួកគេចាប់យកវិទ្យាសាស្ត្របច្ចេកទេស និងបច្ចេកវិទ្យា ។ ការរៀបចំឱ្យមានទីតាំងផ្សេងៗ ដែលអនុញ្ញាតឱ្យយុវជនអាចស្វែងយល់ និង មានអន្តរសកម្មជាមួយវិទ្យាសាស្ត្រ ក៏អាចបង្កើត និង បង្កើនចំណាប់អារម្មណ៍របស់យុវជន ក្នុងគោលដៅប្រើប្រាស់ចម្ងល់, ញ៉ាំងឱ្យពួកគេស្រាវយកវិទ្យាសាស្ត្រយកមកដោះស្រាយចំណោទជីវិត និង រិះរកគំនិតថ្មីៗ សម្រាប់បំពេញតម្រូវការអនាគតរបស់ពួកគេ ។

កម្ពុជានៅមិនទាន់បានយកចិត្តទុកដាក់លើកកម្ពស់ការអភិវឌ្ឍឱ្យបានសកម្ម និង ខ្លាំងក្លា លើវិស័យមាត្រា-សាស្ត្រ និង ស្តង់ដារ ដែលវិស័យនេះមានតួនាទីសំខាន់ ក្នុងការគាំទ្រដល់កិច្ចដំណើរការខ្សែចង្វាក់ផលិតកម្មរបស់រោងចក្រ, សហគ្រាស, សិប្បកម្ម ឱ្យបានរលូន និង ប្រកបដោយការជឿជាក់ ។ ជាមួយគ្នានេះ វិស័យទាំងពីរជួយធ្វើឱ្យតម្លៃបន្ថែមផលិតផលកើនឡើងតាមរយៈការកាត់បន្ថយថ្លៃដើម, ការធ្វើឱ្យមានជំនឿ និង ទំនុកចិត្តលើទីផ្សារទាំងបរិមាណ, តម្លៃ, គុណភាព និង សុវត្ថិភាពផលិតផល ។ ការលើកកម្ពស់ការអភិវឌ្ឍវិស័យមាត្រាសាស្ត្រ និង ស្តង់ដាឱ្យបានសមស្រប គឺជាកត្តាសំខាន់ សម្រាប់ទាក់ទាញអ្នកវិនិយោគដើម្បីអភិវឌ្ឍឧស្សាហកម្ម ។

*គ)- ការតភ្ជាប់: ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និង ការសម្របសម្រួល*

ទោះបីមានការខិតខំប្រឹងប្រែងជាខ្លាំងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈកាល ២០ ឆ្នាំ កន្លងមក ហេដ្ឋារចនាសម្ព័ន្ធទាំងនោះនៅតែមិនទាន់គ្រប់គ្រាន់ ពិសេស ក្នុងដំណើរឆ្ពោះទៅដំណាក់កាលថ្មីនៃការអភិវឌ្ឍ ។ កន្លងមក ការជំរុញការនាំចេញអង្ករមួយលានតោន បានឆ្លុះបញ្ចាំងឱ្យឃើញនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែម ដើម្បីធានាបាននូវខ្សែចង្វាក់ផ្គត់ផ្គង់ដែលអាចទុកចិត្តបាន និង ទាន់ពេលវេលា ។ បណ្តាញផ្លូវជាតិសំខាន់ៗ សម្រាប់ជំរុញការនាំចេញ ទទួលរងនូវភាពកកស្ទះ ដែលនាំទៅដល់ការពន្យាពេលដឹកជញ្ជូន និង ដាក់បន្ទុកកាន់តែខ្លាំងលើ

ផ្លូវក្នុងទំហំបច្ចុប្បន្ន ។ ដូច្នេះ ការជំរុញការអភិវឌ្ឍឧស្សាហកម្ម និង ការនាំចេញបន្ថែម បង្កើតឡើងនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ពិសេសនៅតាមតំបន់ដែលជាទិសដៅនៃការអភិវឌ្ឍឧស្សាហកម្ម និង ការដឹកជញ្ជូនតាមមាត់ច្រកនាំចេញ ដែលគូសបញ្ជាក់អំពីភាពចាំបាច់នៃការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីកមួយឱ្យមានប្រសិទ្ធភាពខ្ពស់ ។

បញ្ហាប្រឈមដ៏សំខាន់ក្នុងការអភិវឌ្ឍឧស្សាហកម្ម គឺកង្វះការផ្គត់ផ្គង់អគ្គិសនីមួយមានស្ថិរភាព និង ក្នុងថ្លៃប្រកួតប្រជែង ។ កន្លងមក រាជរដ្ឋាភិបាលបានខិតខំជំរុញការវិនិយោគលើវិស័យអគ្គិសនី ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ ។ ការប៉ាន់ស្មានពីតម្រូវការអគ្គិសនីអាចនឹងកើនឡើងពី ១៤២- ១៩២ មេហ្គាវ៉ាត់ ជាមធ្យមក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ ២០២៥ ។ នៅឆ្នាំ ២០១២ សមត្ថភាពផ្គត់ផ្គង់អគ្គិសនីកម្ពុជាមាន ៨២៥ មេហ្គាវ៉ាត់ ហើយប្រសិនបើគម្រោងអគ្គិសនីទាំងឡាយបញ្ចប់តាមការគ្រោងទុក លទ្ធភាពផ្គត់ផ្គង់អាចនឹងសម្រេចបាន ១,៨៦៦ មេហ្គាវ៉ាត់ ក្នុងឆ្នាំ ២០១៥ និង ឈានទៅបង្កើនការផ្គត់ផ្គង់ដល់ ២,៥០០ មេហ្គាវ៉ាត់ នៅឆ្នាំ ២០២០ ។ ការជំរុញការវិនិយោគបន្ថែមលើការផ្គត់ផ្គង់ចរន្តអគ្គិសនី គឺជាការចាំបាច់ដើម្បីធានាបាននូវស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី ។ ទោះបីការផ្គត់ផ្គង់ជាភារកិច្ចចាំបាច់ត្រូវធ្វើបន្ទាន់ ដើម្បីជំរុញវិស័យកម្មន្តសាល តែការបញ្ចុះថ្លៃអគ្គិសនីឱ្យបានទាប និងមានលក្ខណៈប្រកួតប្រជែង ក៏ជាអាទិភាពសំខាន់ផងដែរ ព្រោះថាថ្លៃអគ្គិសនីបច្ចុប្បន្ននៅខ្ពស់ជាងបណ្តាប្រទេសជិតខាង ។

ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដូចជា ទឹកស្អាត និង ប្រព័ន្ធបង្ហូរទឹកស្អុយ ត្រូវគិតគូរឡើងវិញក្នុងទំហំថ្មី ។ ការប៉ាន់ស្មានពីតម្រូវការទឹកអាចកើនឡើងក្នុងមួយឆ្នាំពី ១០,០០០ ម៣/ថ្ងៃ ទៅដល់ ១៤,០០០ ម៣/ថ្ងៃ ហើយក្នុងឆ្នាំ ២០២០ អាចតម្រូវការសរុបនឹងកើនដល់ប្រមាណ១៤ម៉ឺន ម៣/ថ្ងៃ។ ជាមួយគ្នានេះ ការបង្ហូរទឹកស្អុយអាចនឹងទាមទារសមត្ថភាពប្រហែលជា ១២ម៉ឺន ម៣/ថ្ងៃ ។ គួរកត់សម្គាល់ថា នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខ្លះ នៅខ្វះខាតប្រព័ន្ធទឹកស្អាត និង ប្រព័ន្ធបង្ហូរទឹកចេញនៅឡើយ ។ ក្នុងន័យនេះ ការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងនេះ ទាមទារឱ្យមានការគិតគូរ និង ត្រៀមលក្ខណៈជាមុន ពិសេសនៅតាមតំបន់គោលដៅឧស្សាហកម្ម ។

ទីតាំងសម្រាប់ការបង្កើតរោងចក្រកម្មន្តសាល មានសារៈសំខាន់ណាស់ ។ តាមការប៉ាន់ស្មាន តម្រូវការទីតាំងសម្រាប់រោងចក្រអាចនឹងកើនឡើងប្រមាណជា ២៤០ ហត ទៅ ២៥០ ហត ក្នុងមួយឆ្នាំ ។ គិតដល់ឆ្នាំ ២០២០ តម្រូវការផ្ទៃដីសម្រាប់ទីតាំងរោងចក្រអាចកើនដល់ ៣៤០០ ហត ទៅ ៤៥០០ ហត ។ ក្នុងពេលបច្ចុប្បន្ន តំបន់សេដ្ឋកិច្ចពិសេស ២២ កន្លែង សរុបទាំងអស់មានផ្ទៃដី ៩០០០ ហត ក្នុងនោះមាន ២៨០ ហត ដែលកំពុងដំណើរការ។ ដូចនេះហើយ ការរៀបចំជំរុញការប្រើប្រាស់តំបន់សេដ្ឋកិច្ចទាំងនោះ ពិសេស ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន អគ្គិសនី ទឹកស្អាត ជាដើម គឺជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ ។

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសង្គម ដើម្បីបំពេញឱ្យផលិតកម្ម ជាការចាំបាច់ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម ។ ជាទូទៅ ហេដ្ឋារចនាសម្ព័ន្ធ រួមមាន ការអភិវឌ្ឍលំនៅដ្ឋាន, សាលារៀន, មន្ទីរពេទ្យ និង សេវាដឹកជញ្ជូនសាធារណៈ មិនបានគិតគូរជាកញ្ចប់ជាមួយនឹងទីតាំងសហគ្រាស ឬ រោងចក្រឡើយ ។ ប្រការ

នេះធ្វើឱ្យមានការលំបាកក្នុងការធ្វើដំណើររបស់កម្មករ ហើយការស្វែងរកដំណោះស្រាយឯកជន ក៏បង្កឱ្យមានអសុវត្ថិភាព និងមានហានិភ័យខ្ពស់ ដែលប៉ះពាល់ដល់ផលិតភាព ។ ការស្នាក់នៅរបស់កម្មករមានលក្ខណៈបណ្ដោះអាសន្ន និងនៅឆ្ងាយពីសេវាសាធារណៈ ទាំងការអប់រំ, សុខាភិបាល និងសេវាសង្គមកិច្ចដ៏ទៃផ្សេងទៀត ដែលធ្វើឱ្យកម្មករងាកទៅរកសេវាឯកជន ដែលមិនសូវមានគុណភាព និង ត្រូវចំណាយច្រើន ។ ប្រការនេះតម្រូវឱ្យមានការគិតគូរអំពីដំណោះស្រាយរយៈពេលវែង ដើម្បីអាចបន្ថយចំណាយលើជីវភាពរបស់កម្មករ ក៏ដូចជាធានាបាននូវសុវត្ថិភាព និង លើកកម្ពស់គុណភាពជីវិត ពិសេស រក្សាប្រាក់បៀវត្សពិតឱ្យមានកំណើនជាប្រចាំ ។

*<u>ឃ)- ស្ថានភាពទីផ្សារហិរញ្ញវត្ថុ (ហិរញ្ញប្បទាន)</u>*

ការអភិវឌ្ឍវិស័យធនាគារ រួមទាំង វិស័យមីក្រូហិរញ្ញវត្ថុមានសន្ទុះខ្លាំង ក្នុងរយៈពេលមួយទសវត្សចុងក្រោយ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ប៉ុន្តែនៅមិនទាន់ឆ្លើយតបបានទៅនឹងតម្រូវការទុនវិនិយោគនៅឡើយ ។ បើពិនិត្យលើការចាក់ឫសហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ច (Financial Deepening) គឺនៅមានកម្រិតទាបនៅឡើយធៀបនឹងប្រទេសដ៏ទៃផ្សេងទៀត ។ ដូច្នេះ ការពង្រឹងប្រព័ន្ធធនាគារមានសារៈសំខាន់ក្នុងការជំរុញការប្រតិបត្តិការហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ច ។ ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគមិនសូវសំបូរបែប ជាពិសេសទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ធំៗ ។ កាលបើគ្មានយន្តការផ្តល់ហិរិញ្ញប្បទានទន់ភ្លន់ នោះគម្រោងវិនិយោគពិបាកនឹងលេចចេញជារូបរាងណាស់ ។ បទពិសោធន៍ក្នុង ***«គោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ»*** បង្ហាញថា មូលនិធិសម្រាប់អភិវឌ្ឍន៏វិស័យកសិកម្មបាន ដើរតួនាទីគន្លឹះក្នុងការកែប្រែស្ថានភាពនៃឧស្សាហកម្មទាំងមូល ដោយពីមុនរោងម៉ាស៊ីនកិនស្រូវពិបាកខ្ចី មកអាចទទួលបានកម្ចីក្នុងទំហំ និង លក្ខខណ្ឌសមស្រប ។ យន្តការហិរញ្ញប្បទានចំពោះសកម្មភាពជាក់លាក់គួរត្រូវបង្កើតឡើង ទើបអាចជាឃ្នាស់ជំរុញឱ្យមានសកម្មភាពទាំងនោះ ។ យន្តការហិរញ្ញប្បទាននេះចាំបាច់ត្រូវរៀបចំឡើង ស្របពេលនឹងការពង្រឹងយន្តការសន្សំក្នុងស្រុក ដូចជាវិស័យធានារ៉ាប់រង និង ប្រាក់សោធននិវត្តន៍ ដើម្បីធានាថា មានប្រភពឥណទានដែលមានការប្រាក់ទាបសមរម្យ ។ ក្នុងន័យនេះ ការប្រមូលផ្តុំការសន្សំឯកជនទាំងអស់ចូលក្នុងប្រព័ន្ធតែមួយ នឹងបង្កើតជម្រើសច្រើនសម្រាប់ផ្តល់ហិរញ្ញប្បទានដល់គម្រោងឧស្សាហកម្ម ។

ទីផ្សារមូលបត្រ ក៏ជាជម្រើសមួយល្អសម្រាប់ការកៀរគរទុនវិនិយោគ ពិសេសជាយន្តការហិរញ្ញប្បទានសម្រាប់អភិវឌ្ឍគម្រោងអាជីវកម្មរយៈពេលវែងប្រកបដោយចីរភាព ។ ក្នុងបរិការណ៍នៃការអភិវឌ្ឍឧស្សាហកម្ម ការបន្តអភិវឌ្ឍទីផ្សារមូលបត្រឱ្យរស់រវើក ជាការបំពេញបន្ថែម និង ផ្តល់ជម្រើសហិរញ្ញប្បទាន ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍវិស័យនេះ ។ ឧទាហរណ៍ ប្រសិនបើតំបន់សេដ្ឋកិច្ចពិសេសចុះបញ្ជីក្នុងទីផ្សារមូលបត្រ, តំបន់ទាំងនោះអាចងាយស្រួលនឹងជំរុញការអភិវឌ្ឍឱ្យបានឆាប់រហ័ស កាលបើម្ចាស់ដើមខ្វះទុនដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ឱ្យគ្រប់គ្រាន់ ឬ ពង្រឹងការគ្រប់គ្រងដើម្បីទាក់ទាញការវិនិយោគ ។ ក្នុងន័យនេះ ទីផ្សារមូលបត្រអាចដើរតួជាយន្តការកៀរគរហិរញ្ញប្បទានវិនិយោគរយៈពេលវែង ។

ដើម្បីជំរុញការផ្តល់ហិរញ្ញប្បទាន ជម្រើសមួយទៀតគឺពិនិត្យលទ្ធភាពបោះមូលបត្ររដ្ឋ ពិសេស នៅពេលកម្ពុជាលែងមានលទ្ធភាពទទួលហិរញ្ញប្បទានអនុគ្រោះ ព្រមគ្នានឹងការពង្រឹងការប្រមូលចំណូលជាតិ និង យន្តការប្រមូលប្រាក់សន្សំក្នុងស្រុក ។ មួយវិញទៀត ការប្រើប្រាស់យន្តការវិនិយោគសាធារណៈ ក៏អាចជាជម្រើសមួយបន្ថែមទៀត ដើម្បីជាឃ្នាស់ទាក់ទាញការវិនិយោគឯកជន ពិសេសក្រោមក្របខណ្ឌភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ក៏ដូចជាការពង្រីកក្របខណ្ឌភាពជាដៃគូរវាងរដ្ឋ, ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន ក្នុងវិស័យអាទិភាពជាក់ស្តែង ។

*ង)- បញ្ហាទីផ្សារការងារ និង ទំនាក់ទំនងឧស្សាហកម្ម*

ទំនាក់ទំនងឧស្សាហកម្មនៅតែជាបញ្ហាប្រឈមចម្បង សម្រាប់ការអភិវឌ្ឍវិស័យឧស្សហកម្មនៅកម្ពុជា ហើយបញ្ហានេះកើតឡើងសឹងនៅគ្រប់ប្រទេស ក្នុងដំណាក់កាលនៃការផ្លាស់ប្តូរជីវភាពពីកសិកម្ម/ជនបទ មកឧស្សាហកម្ម/ទីក្រុង ។ ការគ្រប់គ្រងអន្តរកាលបែបនេះ ជាមូលដ្ឋានយ៉ាងសំខាន់នៃការទាក់ទាញវិនិយោគក្នុងពេលអនាគត ពិសេសក្នុងក្របខណ្ឌនៃការធានាឱ្យបាននូវលក្ខខណ្ឌការងារល្អប្រសើរ, ធានាផលិតភាពខ្ពស់ និង កម្រិតប្រាក់ឈ្នួលសមរម្យ ។ បញ្ហានេះទាមទារឱ្យមានការដោះស្រាយប្រកបដោយការយកចិត្តទុកដាក់ និង មានលក្ខណៈជាប្រព័ន្ធ ដោយផ្អែកលើក្របខណ្ឌច្បាប់ជាធរមាន ពិសេសការពង្រឹងវិនិយោគផ្នែកសង្គម ដើម្បីបន្ធូរសម្ពាធលើការដំឡើងថ្លៃប្រាក់ឈ្នួល ដើម្បីជាមូលដ្ឋានរក្សានូវភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ។

ប្រការនេះរឹតតែមានសារៈសំខាន់ នៅពេលដែលកម្ពុជាបោះជំហានចូលក្នុងក្របខណ្ឌនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ពីព្រោះការគ្រប់គ្រងលំហូរពលកម្មបានល្អ អាចធានានូវភាពប្រកួតប្រជែងរបស់កម្ពុជាជាទីតាំងនៃការធ្វើវិនិយោគ ។ ក្នុងន័យនេះ ការរៀបចំក្របខណ្ឌនិយ័តកម្មឱ្យបានគ្រប់គ្រាន់ និង ការដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព គឺជាការងារដ៏ចាំបាច់ ។ ប្រព័ន្ធនិយ័តកម្ម និង ការគ្រប់គ្រងទីផ្សារការងារ មានសារៈសំខាន់ណាស់ ហើយចាំបាច់ត្រូវអនុវត្តឱ្យកាន់តែទូលំទូលាយថែមទៀត ។ ការតម្រង់ទិសពលករមុនពេលទទួលបានការងារ, ការស្វែងយល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់និយោជិក/និយោជក, ការតវ៉ាសមហេតុផល និង ដាក់ចេញនូវលក្ខខណ្ឌការងារច្បាស់លាស់ សុទ្ធតែជាយន្តការនិយ័តកម្មដែលត្រូវអនុវត្ត ដើម្បីធានាស្ថិរភាព និង ប្រសិទ្ធភាពនៃទីផ្សារការងារ ។

## ៣)- ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែ និង ធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែចង្វាក់តម្លៃសកល, សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និង ការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡាទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និង ការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក, ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង ។ ការសម្រេចនូវចក្ខុវិស័យ

នេះ នឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ, ការទ្រទ្រង់ និង លើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន, ការបង្កើតការងារជូនពលករកម្ពុជា, ការបង្កើនតម្លៃបន្ថែមសម្រាប់សេដ្ឋកិច្ចជាតិ និងការបង្កើនប្រាក់ចំណូលសមស្របជូនប្រជាជនកម្ពុជា ។

តាមចក្ខុវិស័យខាងលើ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងដំណាក់កាលបីសំខាន់ គឺៈ ការបន្តជំរុញសក្តានុពល និង ពិពិធកម្មឧស្សាហកម្មអតិពលកម្ម រួមមាន ឧស្សាហកម្មកម្មន្តសាល និងកសិឧស្សាហកម្ម ក្នុងដំណាក់កាលដំបូង, ការជំរុញការផ្លាស់ប្តូរស៊ីជម្រៅនៃរចនាសម្ព័ន្ធឧស្សាហកម្មទូទៅតាមរយៈពិពិធកម្មផលិតកម្ម ក្នុងដំណាក់កាលបន្ទាប់ និង ការបន្តផ្លាស់ប្តូរតាមរយៈការជំរុញឯកទេសកម្មដែលផ្អែកលើការអភិវឌ្ឍវិទ្យាសាស្ត្រ, បច្ចេកវិទ្យា និង នវានុវត្តន៍ ក្នុងដំណាក់កាលជឿនលឿន ។ ក្នុងដំណាក់កាលនីមួយៗ រាជរដ្ឋាភិបាលនឹងផ្តោតលើការបង្កើតនូវមូលដ្ឋានឧស្សាហកម្មថ្មីៗ តាមរយៈការទាក់ទាញវិនិយោគទាំងក្នុង និងក្រៅស្រុក គួបផ្សំនឹងការជួយជ្រោមជ្រែងពីស្ថាប័នរដ្ឋពាក់ព័ន្ធ, ការបន្តពង្រីកមូលដ្ឋានផលិតកម្ម និង ការបន្តជំរុញការនាំចេញ តាមរយៈទំនើបកម្មសហគ្រាសឧស្សាហកម្ម និង ការបង្កើនផលិតភាព, ព្រមទាំងការធ្វើវិចារណកម្ម និង ឯកទេសកម្មឧស្សាហកម្មនៅកម្ពុជា តាមរយៈការអនុវត្តនូវក្របខណ្ឌគោលនយោបាយ និង និយ័តកម្ម ដែលមានលក្ខណៈបុរេសកម្ម និង ឈរលើមូលដ្ឋាននៃឧត្តមានុវត្តន៍ ។

## ៤) - គោលបំណង និងគោលដៅ

***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់នូវចក្ខុវិស័យ, ក្របខណ្ឌគោលនយោបាយ, ក្របខណ្ឌសម្របសម្រួលការអនុវត្ត និង ការរៀបចំយន្តការស្ថាប័ន សម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដើម្បីសម្រេចនូវចក្ខុវិស័យខាងលើ ។ កម្មវត្ថុសំខាន់នៃគោលនយោបាយនេះ គឺការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ និង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មចាំបាច់ទាំងផ្នែករូបវ័ន្ត និងផ្នែកទន់ ឱ្យសមស្របតាមសក្តានុពល ឧត្តមភាពប្រកួតប្រជែង និង សភាពការណ៍វិវត្តន៍នៃឧស្សាហកម្មកម្ពុជា ។ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ក៏មានគោលបំណងដាក់ចេញនូវវិធានការប្រទាក់ក្រឡាគ្នា ទាំងក្នុងកម្រិតម៉ាក្រូ, កម្រិតវិស័យនីមួយៗ និង អន្តរាគមន៍ជាក់លាក់ តាមតម្រូវការជាក់ស្តែង ហើយមានវិសាលភាពគ្របដណ្តប់សម្រាប់ឆ្នាំ ២០១៥-២០២៥ និង ត្រូវធ្វើបច្ចុប្បន្នកម្មរយៈពេល ៥ ឆ្នាំម្តង ។

ដើម្បីសម្រេចចក្ខុវិស័យ និង គោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់យកគោលដៅចម្បងបី រួមមាន ការកែប្រែ និង ពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ, ការបង្កើន និង ពិពិធកម្មមុខទំនិញនាំចេញ និង ការពង្រឹងយន្តការគ្រប់គ្រង និង ជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ។ គោលដៅទាំងនេះ <u>ឆ្លុះបញ្ចាំងតាមរយៈការប្រែប្រួលរចនាសម្ព័ន្ធ និង សូចនាករសមិទ្ធកម្មសំខាន់ៗ</u> ដូចខាងក្រោម ÷

***ទី១-*** ការកែប្រែ និង ពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ ***ដោយបង្កើនអនុបាតវិស័យឧស្សាហកម្មក្នុង ផសស ឱ្យបាន ៣០% នៅឆ្នាំ ២០២៥ ពី ២៤,១% នៃ ផសស នៅឆ្នាំ ២០១៣*** ក្នុងនោះ ***វិស័យ***

***កម្មន្តសាលត្រូវកើនឡើងពី ១៥,៥% នៃ ផសស នៅឆ្នាំ ២០១៣ ទៅដល់ ២០% នៅឆ្នាំ ២០២៥*** (សូមមើលតារាង ទី២)។

**តារាងទី២ : ការបែងចែក ផសស តាមវិស័យ**

| **វិស័យ** | **១៩៦២** | **១៩៩៨** | **២០០៨** | **២០១៣** | **២០១៥** | **២០២០** | **២០២៥** |
|---|---|---|---|---|---|---|---|
| កសិកម្ម | ៤៩% | ៤៤,៥% | ៣២,៨% | ៣១,៦% | ២៩,០ % | ២៥ % | ២៣% |
| ឧស្សាហកម្ម | ១៩% | ១៦,៧% | ២២,៤% | ២៤,១% | ២៦,២ % | ២៨ % | ៣០% |
| *- កម្មន្តសាល* | - | *១២,៧ %* | *១៥,៣%* | *១៥,៥%* | *១៦,០%* | *១៨%* | *២០%* |
| សេវាកម្ម | ៣២% | ៣៤,៨% | ៣៨,៨% | ៣៨,៥% | ៣៩,៤% | ៤០% | ៤០% |
| ឧបត្ថម្ភធននិងពន្ធ | ០% | ៤% | ៦% | ៥,៨% | ៥,៤% | ៧% | ៧% |

***ទី២-*** ការបង្កើន និង ពិពិធកម្មមុខទំនិញនាំចេញ ***ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនជាវាយនភ័ណ្ឌ) ឱ្យបាន ១៥% នៃបរិមាណនាំចេញសរុប នៅឆ្នាំ ២០២៥*** ទន្ទឹមនឹង ***ជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន ១២% នៃបរិមាណនាំចេញសរុប នៅឆ្នាំ ២០២៥*** ក៏ដូចជា *ការនាំចេញបន្ថែមនូវផលិតផលថ្មីៗ* ជាប្រចាំ (សូមមើលតារាង ទី៣) ។

**តារាងទី៣ : ចំណែកនៃមុខទំនិញនាំចេញ**

| **វិស័យ** | **១៩៩៨** | **២០០៨** | **២០១៣** | **២០១៥** | **២០២០** | **២០២៥** |
|---|---|---|---|---|---|---|
| ការនាំចេញកសិផលកែច្នៃ | ១០ % | ១០ % | ៧,៩ % | ៨ % | ១០ % | ១២ % |
| កម្មន្តសាល | | | | | | |
| *- សម្លៀកបំពាក់ និងស្បែកជើង* | ៨០ % | ៧០ % | ៧៧ % | ៦០ % | ៥៥ % | ៥០ % |
| *- មិនមែន សម្លៀកបំពាក់ និងស្បែកជើង* | ០,១ % | ០,៥ % | ១ % | ៥ % | ១០ % | ១៥ % |

***ទី៣-*** ការពង្រឹងយន្តការគ្រប់គ្រង និង ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដោយជំរុញការចុះបញ្ជីផ្លូវការនៃសហគ្រាសទាំងនោះ រួមទាំងសហគ្រាសធុនធំផងដែរ និង លើកកម្ពស់អភិបាលកិច្ចសាជីវកម្ម តាមរយៈការកាន់បញ្ជីកាគណនេយ្យ និងតារាងតុល្យការ ។ ***ជាគោលដៅនៅឆ្នាំ ២០២៥ សហគ្រាសធុនតូច និងមធ្យម ៨០% និង ៩៥% រៀងៗខ្លួន នឹងត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូច និងមធ្យម ៥០% និង ៧០% រៀងៗខ្លួន នឹងមានបញ្ជីកាគណនេយ្យ និង តារាងតុល្យការត្រឹមត្រូវ*** ។ តាមពិត គោលដៅនេះហាក់ដូចជាសាមញ្ញ ប៉ុន្តែចំណុចសំខាន់នៃការចុះបញ្ជីកា គឺជាយន្តការអភិបាលកិច្ចមួយសម្រាប់ តាមដានអំពីស្ថានភាពអាជីវកម្ម និងកិច្ចដំណើរការរបស់សហគ្រាស ដែលធានានូវការទទួលខុសត្រូវចំពោះម្ចាស់ភាគហ៊ុន ព្រមទាំងផ្តល់នូវឧបករណ៍

ធានាសម្រាប់ទទួលហិរញ្ញប្បទាន និង ជាមូលដ្ឋានវាយតម្លៃសម្រាប់ទទួលបានការគាំទ្រ និង ការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ដូចជា ការបណ្ដុះបណ្ដាល និង ជំនួយបច្ចេកទេស ជាដើម (សូមមើលតារាង ទី៤) ។

**តារាងទី៤ : អត្រាក្រុមហ៊ុនផ្លូវការបានចុះបញ្ជី និងមានតារាងតុល្យការ**

| **ទំហំ/ប្រភេទ សហគ្រាស** | **បានចុះបញ្ជីផ្លូវការ** | | | **មានតារាងតុល្យការ** | | |
|---|---|---|---|---|---|---|
| | **២០១០** | **២០២០** | **២០២៥** | **២០១០** | **២០២០** | **២០២៥** |
| សហគ្រាសធុនតូច | ៣៧% | ៧០% | ៨០% | ៤% | ៣០% | ៥០% |
| សហគ្រាសធុនមធ្យម | ៧២% | ៨០% | ៩៥% | ២៤% | ៥០% | ៧០% |
| សហគ្រាសធុនធំ | ៩៣% | ១០០% | ១០០% | ៦៦% | ១០០% | ១០០% |

## ៥)- ក្របខណ្ឌយុទ្ធសាស្ត្រ

### *៥-១)- យុទ្ធសាស្ត្រគន្លឹះនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម*

យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និង គោលដៅខាងលើ ផ្ដោតជាសំខាន់លើការរៀបចំ និង អនុវត្តនូវក្របខណ្ឌគោលនយោបាយមួយច្បាស់លាស់ ដែលមានការសម្រប-សម្រួលប្រទាក់ក្រឡាគ្នា និង បំពេញគ្នាទៅវិញទៅមក ដោយចាប់ផ្ដើមពីការកែទម្រង់ និង ការកែសម្រួលយន្តការស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ។ ក្របខណ្ឌគោលនយោបាយនេះ រួមមានសរសរស្តម្ភបួន ÷ ***ទី១-***ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និង ការកៀរគរវិនិយោគឯកជន ក្នុងស្រុកសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្ម, ការអភិវឌ្ឍនិងពង្រីកទីផ្សារនាំចេញ និង ការជំរុញការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យា ***ទី២-***ការអភិវឌ្ឍនិងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ដើម្បីពង្រីក និងពង្រឹងមូលដ្ឋានឧស្សាហកម្មកម្មន្តសាល, ការធ្វើទំនើបកម្មនិងចុះបញ្ជីសហគ្រាសជាផ្លូវការ, ការជំរុញការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យា និង ការពង្រឹងការតភ្ជាប់ឧស្សាហកម្មរវាងសហគ្រាសក្នុងស្រុកជាមួយនឹងសហគ្រាសបរទេស ពិសេស នៅក្នុងវិស័យកសិឧស្សាហកម្ម ***ទី៣-***ការកែលម្អបរិស្ថាននិយ័តកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែង តាមរយៈការលើកកម្ពស់បរិយាកាសវិនិយោគ និង កិច្ចសម្រួលពាណិជ្ជកម្ម, ការផ្ដល់ព័ត៌មានអំពីទីផ្សារ និង ការកាត់បន្ថយចំណាយចម្លងការអាជីវកម្ម និង ***ទី៤-***ការសម្របសម្រួលគោលនយោបាយគាំទ្រ រួមមាន ការអភិវឌ្ឍធនធានមនុស្ស ការបណ្ដុះបណ្ដាលជំនាញ និង ការកែលម្អទំនងទំនងឧស្សាហកម្ម, ការអនុវត្តផែនការរៀបចំដែនដី នគរូបនីយកម្ម និងផែនការប្រើប្រាស់ដី ស្របតាម ***«គោលនយោបាយដីធ្លី»*** និង ***«គោលនយោបាយជាតិស្ដីពីការរៀបចំដែនដី»*** ព្រមទាំង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមាន ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូន-ឡូជីស្ទីក និងការតភ្ជាប់ឌីជីថល, ការផ្គត់ផ្គង់អគ្គិសនី និង ទឹកស្អាត ព្រមទាំងសេវាគាំទ្រផ្សេងទៀត ដូចជា សេវាសាធារណៈ, សេវាសង្គមកិច្ច និង សេវាហិរញ្ញវត្ថុ ។

ក្របខណ្ឌយុទ្ធសាស្ត្រខាងលើ មានមុខព្រួញសំខាន់ពីរដែលបំពេញគ្នាទៅវិញទៅមក ក្នុងនោះ សរសរស្តម្ភទីមួយ មានគោលបំណងកៀរគរទុនវិនិយោគដើម្បីបង្កើតឧស្សាហកម្មថ្មីៗ ទ្រង់ទ្រាយធំ ដែលមានចរិតជាឧស្សាហកម្មនាំមុខ និង បម្រើឱ្យគោលដៅជ្រៀតចូលទីផ្សារតំបន់ និងអន្តរជាតិ ក៏ដូចជា ការតភ្ជាប់ជាមួយខ្សែចង្វាក់តម្លៃសកល ។ សរសរស្តម្ភទីពីរ សំដៅពង្រឹង និងកសាងមូលដ្ឋានឧស្សាហកម្មក្នុងស្រុកមានស្រាប់ ដោយផ្តោតលើសហគ្រាសធុនតូច និងមធ្យម ដើម្បីអភិវឌ្ឍឧស្សាហកម្មគាំទ្រ និងចង្កោមឧស្សាហកម្មក្នុងខ្សែចង្វាក់ផលិតកម្ម និងខ្សែចង្វាក់តម្លៃសំខាន់ៗ ដែលអាចផ្សារភ្ជាប់ និងចូលរួមសកម្មភាពផលិតកម្មជាមួយនឹងឧស្សាហកម្មប្រភេទទីមួយ ។ ដោយឡែក សរសរស្តម្ភពីរផ្សេងទៀត មានតួនាទីគាំទ្រ និង រួមចំណែកដល់ការសម្រេចគោលដៅលើការដ្ឋានពីរខាងដើម ពោលគឺការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ទាក់ទាញការវិនិយោគក្នុងវិស័យឧស្សាហកម្ម ក៏ដូចជាការសម្រួលសកម្មភាពអាជីវកម្មនិងឧស្សាហកម្មនៅកម្ពុជា ដែលពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់និងនិយ័តកម្ម, ធនធានមនុស្ស និងជំនាញ, ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម ក៏ដូចជាការផ្គត់ផ្គង់ធាតុចូលសម្រាប់ឧស្សាហកម្ម ដូចជា វត្ថុធាតុដើម អគ្គិសនី ទឹកស្អាត ជាដើម ។

### *៥-២)- វិសាលភាព និង វិស័យអាទិភាព*

វិសាលភាព និង វិស័យអាទិភាព ដែលជាកម្មវត្ថុនៃ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ផ្តោតជាសំខាន់លើប្រភេទឧស្សាហកម្មដែលចាត់ទុកជាអាទិភាព, សារៈសំខាន់សម្រាប់ការតភ្ជាប់ជាមួយខ្សែចង្វាក់តម្លៃសកល និង បណ្តាញផលិតកម្មតំបន់, ការជ្រើសរើសទីតាំងដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រសម្រាប់ការវិនិយោគ, ព្រមទាំងក្របខណ្ឌច្បាប់, គោលនយោបាយ និង យន្តការផ្តល់ការលើកទឹកចិត្ត ដែលត្រូវរៀបចំលម្អិតបន្ថែមទៀតនៅក្នុងផែនការអនុវត្តជាក់ស្តែង ។

<u>*ក- វិសាលភាព*</u>

***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** នឹងត្រូវអនុវត្តក្នុងវិសាលភាព ដូចខាងក្រោម៖

*ទី១-* ការជំរុញការអភិវឌ្ឍវិស័យកម្មន្តសាល និង ឧស្សាហកម្មកែច្នៃកសិផល តាមរយៈការលើកទឹកចិត្តការវិនិយោគផ្ទាល់ពីបរទេស និង ក្នុងស្រុក ព្រមទាំងការលើកកម្ពស់សមត្ថភាពសហគ្រាសធុនតូច និង មធ្យម ទាំងក្នុងស្រុក និង បរទេស សំដៅជំរុញផលិតកម្មលើមុខទំនិញបម្រើការនាំចេញ និង ជំនួសការនាំចូល ។

*ទី២-* សមាហរណកម្មទៅនឹងបណ្តាញផលិតកម្មតំបន់ និង ពិភពលោក ដើម្បីទាញផលពីវិមាត្រសេដ្ឋកិច្ចតាមរយៈការទាក់ទាញវិនិយោគបរទេសធំៗ ក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន, ការអភិវឌ្ឍរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និង ការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗក្នុងប្រទេស ដូចជា រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ ខេត្តកោះកុង និង តំបន់ជាប់ព្រំដែនប្រទេសជិតខាង ពិសេស ការតភ្ជាប់មជ្ឈមណ្ឌលឧស្សាហកម្មទីក្រុងបាងកក និង ទីក្រុងហូជីមិញ ។

*ទី៣-* ការតម្រង់ទិសការអភិវឌ្ឍតំបន់ឧស្សាហកម្ម ដើម្បីធានាបាននូវភាពប្រមូលផ្តុំ ការតភ្ជាប់សេដ្ឋកិច្ច និង ប្រសិទ្ធភាពសេវាដឹកជញ្ជូន, ឡូជីស្ទីក និង ការផ្គត់ផ្គង់អគ្គិសនី ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត ។ រាជរដ្ឋាភិបាលកំណត់យករាជធានីភ្នំពេញ ព្រមទាំងតំបន់ជាប់ព្រំដែនថៃ និង វៀតណាម ជាតំបន់សក្តានុពលសម្រាប់ផលិតមុខទំនិញកម្មន្តសាល និង ការតភ្ជាប់ខ្សែចង្វាក់ផលិតកម្មតំបន់, របៀងឧស្សាហកម្មពីខេត្តព្រះសីហនុមកដល់ភ្នំពេញជាតំបន់អភិវឌ្ឍន៍កម្មន្តសាលសម្រាប់ជំរុញការនាំចេញ, របៀងឧស្សាហកម្មពីខេត្តកំពង់ចាមរហូតដល់ភាគពាយព្យប្រទេសជាតំបន់កែច្នៃកសិកម្ម និង តំបន់សៀមរាបជាតំបន់ផលិតកម្មសិប្បកម្មសម្រាប់គាំទ្រវិស័យទេសចរណ៍ ។

*ទី៤-* ការលើកទឹកចិត្តដល់ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ក៏ដូចជាការអភិវឌ្ឍរបៀងសេដ្ឋកិច្ច និង សួនឧស្សាហកម្ម រួមទាំង កន្សោមឧស្សាហកម្ម ពិសេសការតភ្ជាប់ខ្សែចង្វាក់ផលិតកម្មឆ្លងដែនក្នុងតំបន់, កន្សោមឧស្សាហកម្មបច្ចេកវិទ្យា, កន្សោមកសិឧស្សាហកម្ម, កន្សោមកម្មន្តសាល/សិប្បកម្មបម្រើទីផ្សារក្នុង និងក្រៅប្រទេស ជាឧស្សាហកម្មគាំទ្រ និង ឧស្សាហកម្មវត្ថុអនុស្សាវរីយ៍សម្រាប់ទេសចរណ៍ ជាដើម ។

*ទី៥-* ការយកចិត្តទុកដាក់ និង ជ្រោមជ្រែងចំពោះឧស្សាហកម្មជួយដោះស្រាយបញ្ហាសង្គម (Social Enterprises) ដូចជាការលើកកម្ពស់អាហារូបត្ថម្ភកុមារ[1], ការអភិវឌ្ឍចំណេះដឹង, ការលើកកម្ពស់អត្តសញ្ញាណជាតិ[2], ការអភិវឌ្ឍមរតកវប្បធម៌, ការជួយដល់ក្មេងកំព្រា ជនពិការ និង ចាស់ជរា, សម្ភារៈកីឡា ជាដើម ។

*ទី៦-* ការយកចិត្តទុកដាក់ និង ជ្រោមជ្រែងចំពោះឧស្សាហកម្មដែលប្រើប្រាស់ចំណេះដឹង/បច្ចេកទេសទំនើប និង មានប្រភពក្នុងប្រទេស ដែលជាមូលដ្ឋានសម្រាប់ពង្រឹងកម្មសិទ្ធិជាតិ និង បង្កើតជាថ្នាលសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាក្នុងស្រុកជារួម ។

*<u>ខ-វិស័យអាទិភាព</u>*

ទោះបីវិស័យឯកជនជាអ្នកសម្រេចចិត្តលើអាទិភាពក្នុងការវិនិយោគក្តី រាជរដ្ឋាភិបាលមានតួនាទីសម្របសម្រួល និង តម្រង់ទិស ដោយផ្អែកលើឧត្តមភាពប្រកួតប្រជែងរបស់ប្រទេស និង ជំរុញការប្រើប្រាស់ធនធានទំនេរឱ្យអស់សក្តានុពល ព្រមទាំងការគិតគូរច្បាស់លាស់អំពីដែនសមត្ថកិច្ច និងហានិភ័យឱ្យបានគ្រប់ជ្រុងជ្រោយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកំណត់ប្រភេទឧស្សាហកម្មអាទិភាព ដូចខាងក្រោម ÷

***ទី១-***ឧស្សាហកម្ម ឬ កម្មន្តសាលថ្មីៗ មានចរិតជាការបើកច្រកចូលទីផ្សារ, ផ្តល់តម្លៃបន្ថែមខ្ពស់, មានភាពច្នៃប្រឌិត និង ភាពប្រកួតប្រជែងខ្ពស់ ដែលផ្តោតលើទាំងផលិតផលប្រើប្រាស់ និង សម្ភារៈបរិក្ខារផលិតកម្ម

---

[1] *ឧទាហរណ៍ ការផលិតចំណីអាហារសម្រាប់ទារកក្នុងតម្លៃថោក និងងាយរកទិញបាន ដែលបម្រើឱ្យគោលដៅពាណិជ្ជកម្មផង និងគោលដៅលើកកម្ពស់សុខមាលភាពទារកផង ឬ ការកែច្នៃចំណីអាហារសម្រាប់កុមារដែលមានជីវជាតិគ្រប់គ្រាន់ ដែលលក់ក្នុងតម្លៃថោក អាចទុកបានយូរ និង មានការផ្គត់ផ្គង់ទូលំទូលាយ ដែលនឹងរួមចំណែកដល់ការលើកកម្ពស់អាហារូបត្ថម្ភកុមារ ពិសេសនៅតាមតំបន់ជនបទ ។*

[2] *ឧទាហរណ៍ ការផលិតកម្មវិធីកុំព្យូទ័រ ឬ កម្មវិធីទូរស័ព្ទ និងsoftware ផ្សេងៗ ជាភាសាជាតិ ។*

ដូចជា ការផ្គុំដំឡើងគ្រឿងចក្រ, ការផ្គុំដំឡើងសម្ភារៈបរិក្ខារមេកានិក អេឡិចត្រូនិច និង អគ្គិសនី, ការផ្គុំដំឡើងមធ្យោបាយដឹកជញ្ជូន និង ការកែច្នៃធនធានធម្មជាតិ ជាដើម ។

***ទី២-*** សហគ្រាសធុនតូចនិងមធ្យមក្នុងគ្រប់វិស័យ ដែលពាក់ព័ន្ធនឹងផលិតកម្មឱសថ និង បរិក្ខារពេទ្យ, ឧស្សាហកម្ម ឬ សិប្បកម្មសម្ភារៈសំណង់, ផលិតកម្មសម្ភារៈបម្រើការវេចខ្ចប់នាំចេញ, ផលិតកម្មគ្រឿងសង្ហារឹម និង សម្ភារៈបម្រើឱ្យឧស្សាហកម្ម ជាដើម ។

***ទី៣-*** ផលិតកម្មកសិឧស្សាហកម្ម ដែលបម្រើឱ្យការនាំចេញ និង ទីផ្សារក្នុងស្រុក ។

***ទី៤-*** ប្រភេទឧស្សាហកម្មគាំទ្រ ពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ និង កាត់ដេរ ព្រមទាំង ឧស្សាហកម្មបម្រើឱ្យខ្សែចង្វាក់ផលិតកម្មតំបន់ ដែលជាឧស្សាហកម្មតភ្ជាប់ទៅទីផ្សារ ឬ ខ្សែចង្វាក់តម្លៃសកល (ឧស្សាហកម្មអនុគមន៍-Forward Linkages) និង ឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់វត្ថុធាតុដើម (ឧស្សាហកម្មប្រតិគមន៍-Backward Linkages) ពិសេសសម្រាប់វិស័យកាត់ដេរ, ឧស្សាហកម្មផលិត គ្រឿងបន្លាស់ និង ឧស្សាហកម្មផ្គុំដំឡើង រួមទាំង ការផលិតផលិតផលពាក់កណ្តាលសម្រេចផ្សេងៗ ។

***ទី៥-*** ប្រភេទឧស្សាហកម្មបម្រើឱ្យខ្សែចង្វាក់ផលិតកម្មតំបន់ និង មានចរិតយុទ្ធសាស្ត្រសម្រាប់អនាគត ដូចជា ឧស្សាហកម្មព័ត៌មានវិទ្យា និង ទូរគមនាគមន៍ (ICT), ឧស្សាហកម្មថាមពល, ឧស្សាហកម្មធុនធ្ងន់, សិប្បកម្មលក្ខណៈវប្បធម៌ ប្រវត្តិសាស្ត្រ និងប្រពៃណី, និង ឧស្សាហកម្មពាក់ព័ន្ធនឹងបច្ចេកវិទ្យាបៃតង ។

### ៥-៣)-អភិក្រមនៃការអនុវត្ត

រាជរដ្ឋាភិបាលមានតួនាទីបុរេសកម្ម និង ជាកាតាលីករ ជាយុទ្ធសាស្ត្រវិទូ ជាអ្នកគ្រប់គ្រង និង ជាអ្នកសម្រួលដល់កិច្ចដំណើរការអភិវឌ្ឍន៍ ឯផ្នែកឯកជន ជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ច ។ ក្នុងក្របខណ្ឌនៃ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** រាជរដ្ឋាភិបាលមានតួនាទីធានានូវបរិយាកាសនិយ័តកម្មដែលមានលក្ខណៈអំណោយផល ផ្តល់នូវការគាំទ្រនិងការលើកទឹកចិត្តសមស្របសម្រាប់វិស័យអាទិភាព រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់បម្រើឱ្យសកម្មភាពឧស្សាហកម្ម ។ ម៉្យាងទៀត រាជរដ្ឋាភិបាលអាចនឹងចូលរួមវិនិយោគផ្ទាល់ក្នុងការអភិវឌ្ឍឧស្សាហកម្មមានលក្ខណៈជាយុទ្ធសាស្ត្រ ពិសេស តាមរយៈសហគ្រាសរដ្ឋ (SOEs) ឬ ភាពជាដៃគូជាមួយឯកជន ព្រមទាំងពិចារណាលើលទ្ធភាពធានាស្វែងរកទីផ្សារ សម្រាប់ឧស្សាហកម្មបែបនេះ តាមរយៈគម្រោងលទ្ធកម្មសាធារណៈ និង ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដូចជា ការធានាការផ្តល់កម្ចីមានលក្ខណៈសម្បទានសម្រាប់ដំណើរការផលិតកម្ម, ការជួល ឬ ទិញបរិក្ខារគ្រឿងចក្រ, សេវាប្រឹក្សាយោបល់ និង អចលនវត្ថុ ជាដើម។

ក្នុងដំណើរការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលនឹងតម្រង់ទិសលើការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់ៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេសពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញ និង ការអប់រំបច្ចេកទេស, ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, ការជំរុញនវានុវត្តន៍បច្ចេកវិទ្យា និង ការផ្គត់ផ្គង់វត្ថុធាតុដើម ជាដើម ។ ការបណ្តុះ-បណ្តាលជំនាញ និង បច្ចេកទេស មានសារៈសំខាន់ណាស់ក្នុងលើកកម្ពស់សមត្ថភាពផលិតកម្ម ដែលលក្ខខណ្ឌ

ទីផ្សារសុទ្ធសាធពុំអាចផ្តល់បាន ខណៈដែលការវិនិយោគឯកជនលើការអប់រំនៅមានកម្រិតទាបនៅឡើយ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងផ្តល់ការលើកទឹកចិត្តនិងរៀបចំយន្តការដើម្បីជំរុញការវិនិយោគលើការអប់រំ និង បណ្តុះបណ្តាល ដែលធានាបានការចូលរួមពីស្ថាប័នរដ្ឋ, សហគ្រាសឧស្សាហកម្ម និង ពលករផងដែរ សម្រាប់ការសិក្សាជំនាញ វិជ្ជាជីវៈ និង ការបណ្តុះបណ្តាលបច្ចេកទេសជាន់ខ្ពស់ ។ ម្យ៉ាងវិញទៀត ដោយសារបច្ចេកវិទ្យា និង នវានុវត្តន៍ មានសារៈសំខាន់សម្រាប់ពង្រឹងភាពប្រកួតប្រជែង រាជរដ្ឋាភិបាលនឹងរៀបចំយន្តការ និង កម្មវិធីជាក់លាក់សម្រាប់ ជំរុញការអភិវឌ្ឍវិស័យនេះ ពិសេសផ្តោតលើសហប្រតិបត្តិការ ឬ ការផ្សារភ្ជាប់រវាងសកលវិទ្យាល័យ និងស្ថាប័ន ស្រាវជ្រាវ រួមទាំងមជ្ឈមណ្ឌលបច្ចេកវិទ្យាផងដែរ ដើម្បីសិក្សា, វិភាគ និង ពិគ្រោះយោបល់អំពីការអភិវឌ្ឍ ផលិតផល, ការរៀបចំចង្វាក់ផលិតកម្ម និង ការជំរុញការប្រើប្រាស់ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ ។ ចំណែកឯ ប្រព័ន្ធផ្គត់ផ្គង់វត្ថុធាតុដើម ឬ ធាតុចូល ប្រកបដោយគុណភាព, ស្ថិរភាព និង ថ្លៃទាប មានសារៈសំខាន់ សម្រាប់ ផលិតកម្មឧស្សាហកម្ម ដែលចាំបាច់ត្រូវមានយុទ្ធសាស្ត្រ និង ផែនការច្បាស់លាស់ក្នុងការកាត់បន្ថយថ្លៃដើម តាមរយៈការវាយតម្លៃអំពីសេចក្តីត្រូវការ, ការផ្តល់ជំនួយបច្ចេកទេសដើម្បីលើកកម្ពស់សមត្ថភាពអ្នកផ្គត់ផ្គង់ និង ការកាត់បន្ថយថ្លៃនាំចូល តាមរយៈការសម្រួលនីតិវិធី និង ការបន្ថយអត្រាពន្ធគយ ។

ក្នុងបរិការណ៍នេះ រាល់ការគាំទ្របច្ចេកទេស, ហិរញ្ញវត្ថុ និង ការលើកទឹកចិត្តផ្សេងៗ ក្នុងក្របខណ្ឌនៃ គោលនយោបាយនេះ ត្រូវអនុវត្តដោយផ្អែកលើសមិទ្ធកម្ម កម្មវត្ថុគោលនយោបាយច្បាស់លាស់ និង សកម្មភាព អនុវត្តជាក់ស្តែង ដូចជា ការសម្រេចគោលដៅលើបរិមាណនាំចេញ ឬ លទ្ធផលជាក់ស្តែងពីដំណើរការបង្កើត រោងចក្រឧស្សាហកម្មថ្មី ជាដើម ដោយផ្សារភ្ជាប់ទៅនឹងការកែលម្អលក្ខខណ្ឌការងារ, ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញ ព្រមទាំងការផ្ទេរបច្ចេកវិទ្យា ។ លើសពីនេះ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើកិច្ចការពារ បរិស្ថាន ដើម្បីបញ្ចៀសការបំពុលបរិស្ថាន ដោយសារកាកសំណល់ឧស្សាហកម្ម និង សារធាតុគីមីផ្សេងៗ ។ រាជរដ្ឋាភិបាលជំរុញ និង លើកទឹកចិត្តចំពោះដំណើរការឧស្សាហូបនីយកម្មសម្រាប់ទាំងអស់គ្នា (Inclusive Industrialization) ដែលបម្រើឱ្យគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម ពិសេស ការលើកស្ទួយសុខមាលភាព របស់ពលករ ។

## ៦)- វិធានការគោលនយោបាយ និង ផែនការសកម្មភាព

នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រខាងលើនេះ រាជរដ្ឋាភិបាលដាក់ចេញ និងជំរុញអនុវត្តវិធានការគោលនយោ-បាយសំខាន់ៗ ដូចខាងក្រោម ÷

### *៦-១)- ការជំរុញការទាក់ទាញវិនិយោគ*

*<u>ក- បរិយាកាសវិនិយោគ</u>*

- ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ផ្អែកលើតម្រូវការជាក់ស្តែង ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមាន

ការទាក់ទាញការវិនិយោគ, ការផ្ទេរបច្ចេកវិទ្យា, ការបង្កើតការងារ និង បណ្តុះបណ្តាលជំនាញ និង ការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម;

- ពិនិត្យឡើងវិញ និង កែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេស សម្រាប់ទាក់ទាញ «គម្រោងវិនិយោគសក្តានុពល និង មានគុណភាព» ដែលផ្តល់ផលវិជ្ជមាន និង តម្លៃបន្ថែម សម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងទាក់ទាញឧស្សាហកម្មថ្មីៗ មកកម្ពុជា;
- បន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខណ្ឌគតិយុត្តិការធ្វើវិចារណកម្មការផ្តល់ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ, ការបន្តពង្រឹងក្របខណ្ឌអភិ-បាលកិច្ច និង ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ពិសេសការពង្រឹងយន្តការ ***«ច្រកចេញចូលតែមួយ»***នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យក្លាយជាយន្តការជាក់ស្តែងប្រកបដោយប្រសិទ្ធភាព សម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម;
- ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែម ចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្តុះ-បណ្តាលជំនាញ, ការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍;
- ពង្រឹងសមត្ថភាពស្ថាប័ន និង សមាហរណកម្មមុខងារគ្រប់គ្រង និង ទាក់ទាញវិនិយោគ ជាមួយមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរួមនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យម, ការកែទម្រង់ និងទំនើបកម្មស្ថាប័ន, និងការលើកកម្ពស់សមត្ថភាពមន្ត្រី ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងចក្ខុវិស័យ និង គោលដៅនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម;
- ពង្រឹង និង លើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ និង តាមដានការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការគោរពគោលការណ៍ និង លក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគ ព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន;
- ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការវិនិយោគ និង ដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិន ក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ;
- បន្តពង្រឹងប្រសិទ្ធភាពនៃ ***«វេទិការាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន»*** ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេស ការធានានូវផលប្រយោជន៍រួមនៃវិស័យឧស្សាហកម្ម ការប្រកួតប្រជែងស្មើភាព និង ការលើកកម្ពស់បរិយាកាសវិនិយោគ;

- រៀបចំ និង ដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និង វិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយ និង ទាក់ទាញការវិនិយោគ ដោយផ្តោតលើប្រទេសគោលដៅមួយចំនួន និង កំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់;
- ពិនិត្យឡើងវិញនូវយន្តការផ្តល់ព័ត៌មានវិនិយោគ ដោយយកចិត្តដាក់លើភាពងាយស្រួលក្នុងការទទួលព័ត៌មាន ពិសេស ការកែលម្អមាតិកាព័ត៌មានដែលផ្អែកលើប្រតិកម្មតបនៃអ្នកប្រើប្រាស់ ។

*ខ- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និង ការរៀបចំតំបន់ឧស្សាហកម្ម*

- ពិនិត្យឡើងវិញអំពីក្របខណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុន ដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ក្រុមហ៊ុនក្នុងស្រុក និង សហគ្រាសធុនតូច និង មធ្យម;
- ចាត់វិធានការ និង ជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅធានាឱ្យមានភាពទាក់ទាញ និង ការចាប់អារម្មណ៍ពីសំណាក់វិនិយោគិនដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ;
- ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត ***«ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស»*** សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រង មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ, ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និង ធាតុចូលផ្សេងៗ, កិច្ចសម្រួលការដឹកជញ្ជូន និង ពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និង វិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស;
- បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូច និង មធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាមរយៈការផ្តល់អាទិភាពលើការតភ្ជាប់បណ្តាញអគ្គិសនី និង ការផ្គត់ផ្គង់ទឹកស្អាត, ការតភ្ជាប់ផ្លូវដឹកជញ្ជូន និង ឡូជីស្ទីក ព្រមទាំងការសម្រួល និង ការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ;
- ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និង ខេត្តកោះកុង ព្រមទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជាការតភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាង នៅក្នុងក្របខណ្ឌនៃរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និង អាស៊ាន;
- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករសម្រួលសម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យ ក្នុងការផ្តល់ការលើកទឹកចិត្ត និង ជំរុញឧត្តមានុវត្តន៍;

- រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្តព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និង ក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់, ការគ្រប់គ្រងបរិស្ថានដែលធានាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី, ការអភិវឌ្ឍលំនៅដ្ឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមាន អគ្គិសនី, ផ្លូវថ្នល់, កំពង់ផែ, ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត, ប្រព័ន្ធការពារទឹកជំនន់, ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល, អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេលវែង;
- អភិវឌ្ឍតំបន់ជុំវិញទីក្រុងភ្នំពេញ ឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ដោយបែងចែករវាងតំបន់ឧស្សាហកម្ម និង តំបន់និវេសនដ្ឋាន ឬ ទីប្រជុំជន រួមទាំងផែនការរយៈពេលវែង សម្រាប់ប្រែក្លាយទីក្រុងភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល, ឧស្សាហកម្ម, វិទ្យាសាស្ត្រ និង នវានុវត្តន៍;
- សិក្សារៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និង មធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និង សហគ្រាសក្នុងស្រុក ពិសេស ការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និង ខ្សែចង្វាក់ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់;
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ ជាដើម សំដៅបម្រើឱ្យគោលដៅឧស្សាហកម្ម ពិសេស ការបោះទីតាំងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍប៉ូលឧស្សាហកម្ម និង ការប្រែក្លាយតំបន់ទីប្រជុំជន/ទីក្រុងជាមជ្ឈមណ្ឌលឧស្សាហកម្មជាតិ ស្របតាមផែនការរៀបចំដែនដី នគរូបនីយកម្ម និងផែនការប្រើប្រាស់ដី;
- កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និង គោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស និង តំបន់ឧស្សាហកម្មផ្សេងទៀត;
- បន្តពង្រឹង និង លើកកម្ពស់សមត្ថភាពរដ្ឋបាល និង ក្របខណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា ការកែច្នៃកសិផលសម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេសត្រូវចំណុះលើកត្តាសំខាន់ៗ ដូចជា ទីតាំងភូមិសាស្ត្រ ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋា-រចនាសម្ព័ន្ធ រួមទាំង អគ្គិសនី និងទឹកស្អាត និង ប្រព័ន្ធឡូជីស្ទីក ព្រមទាំងការលើកទឹកចិត្តផងដែរ);

- ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូររវាងរដ្ឋ និង វិស័យឯកជន ។

### ៦-២)- ការពង្រីក និង ទំនើបកម្មសហគ្រាសធុនតូច និងមធ្យម

*ក- ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត*

- ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ, ការអភិវឌ្ឍផលិតផលថ្មី, ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs), ការតភ្ជាប់ខ្សែចង្វាក់តម្លៃ និង ការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខណ្ឌសកម្មភាពចំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍សហគ្រាសទាំងនោះ;
- ពង្រឹងនូវក្របខណ្ឌ និង យន្តការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ជាពិសេសសំដៅរៀបចំការចុះបញ្ជី, ការគ្រប់គ្រង និង តាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាសកម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់ សម្រាប់រៀបចំគោលនយោបាយគាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានលទ្ធភាពទទួលបានព័ត៌មានពីឥណទាន និង ការពិគ្រោះយោបល់ផ្នែកធុរៈកិច្ច ដើម្បីពង្រីកសកម្មភាព និង ការវិនិយោគ;
- ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និង ការបណ្តុះបណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក;
- បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយរាជរដ្ឋាភិបាលផ្តល់នូវការវិភាជន៍ថវិកាសមស្រប យោងតាមតម្រូវការ និង លទ្ធភាពជាក់ស្តែងនៃថវិកាជាតិ;
- កសាងធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្ម ឱ្យមានភាពរឹងមាំ និង ជវភាព ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេស សម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យអាទិភាព ដោយបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលវិស្វករ និង អ្នកបច្ចេកទេស;
- ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម សម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬ បរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក, ការលើកកម្ពស់គុណភាពផលិតផល និង ទំនើបកម្មនៃខ្សែចង្វាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs);
- លើកស្ទួយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សាដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និង នវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ;

- បង្កើតពានរង្វាន់សម្រាប់ការប្រកួតប្រជែងបច្ចេកទេស នៅលើគ្រប់មុខសញ្ញាអាទិភាព;
- ជំរុញការបង្កើតសមាគមតាមអនុវិស័យវិស័យនិមួយៗ ដើម្បីចែករំលែកចំណេះដឹង, តស៊ូមតិ និង ការពារសិទ្ធប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែក បច្ចេកទេស និង ហិរញ្ញវត្ថុ;
- ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញយកផល ប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

*<u>ខ- ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ</u>*

- ធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈ គណនេយ្យ ដោយរៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម;
- ពង្រឹងយន្តការក្រោមដំបូលតែមួយ សម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ដោយប្រើប្រាស់ ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ សម្រាប់ជាមូលដ្ឋានវាយតម្លៃ និង ជាលក្ខខណ្ឌសម្រាប់ ការផ្តល់ការលើកទឹកចិត្ត និង ការគាំទ្រពីរាជរដ្ឋាភិបាល;
- លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូច និង មធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការ បង់ពន្ធតាមរបបពិត;
- ពង្រឹងអភិបាលកិច្ចសាជីវកម្ម សម្រាប់ពង្រឹង និង ពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃ គណនេយ្យភាពសង្គម និង លទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ, ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និង ការគ្រប់គ្រងបច្ចេកវិទ្យា សម្រាប់សហគ្រាសធុនតូច និងមធ្យម;
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួលក្នុងការចុះបញ្ជី និងអត្ថប្រយោជន៍នៃការចុះបញ្ជី;
- ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម ។

*<u>គ- ការជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម</u>*

- ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជា តំបន់កែច្នៃនិងផលិតសង្ហារឹម, តំបន់កែច្នៃផលិត សម្ភារៈអំពីកៅស៊ូ, តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ, តំបន់កែច្នៃចំណីអាហារ សម្រាប់គោលដៅ ប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេស ដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន;
- ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណា ដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ;
- បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល, បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ;

- រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាឡូជីស្ទីក, លុបបំបាត់កម្រៃក្រៅផ្លូវការ និង កែលម្អការសម្រួលពាណិជ្ជកម្ម;
- សិក្សាកំណត់នូវមុខទំនិញអាទិភាព ដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើខ្សែចង្វាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ ។

## ៦-៣)-ការកែលម្អបរិស្ថាននិយ័តកម្ម

<u>*ក-វិធានការសម្រួលពាណិជ្ជកម្ម និង ជំរុញការនាំចេញ*</u>

- ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវា ***«បញ្ជរតែមួយជាតិ»*** ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវា ***«បញ្ជរតែមួយអាស៊ាន»*** និង ការតភ្ជាប់ទៅនឹងបណ្តាញឡូជិស្ទីកអន្តរជាតិ;
- បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្តុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម, តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្តាញអ៊ីនធឺណែត;
- កែលម្អការធ្វើបែបបទបញ្ចេញទំនិញពីគយ(Custom Clearance) សម្រាប់ទំនិញដែលលើកលែងពន្ធ ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ, កាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស និង លុបបំបាត់ចំណាយក្រៅផ្លូវការ;
- កាត់បន្ថយ និងឈានទៅលុបបំបាត់នូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និង គ្មានតម្លាភាព;
- រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធឡូជិស្ទីក ដែលជាមូលដ្ឋានក្នុងការជួយសម្រួលពាណិជ្ជកម្ម និង ជាប្រព័ន្ធដែលមានប្រសិទ្ធភាព អាចទុកចិត្តបាន និង មានភាពប្រកួតប្រជែងខ្ពស់;
- ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងអនុតំបន់នានា ដូចជា អាស៊ាន និង កម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង ***«យន្តការបញ្ជរតែមួយ»*** ដែលត្រូវបានបង្កើតឡើង ក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធឡូជីស្ទីកអន្តរជាតិក្នុងតំបន់, ទន្ទឹមនឹងការរៀបចំបង្កើតក្របខណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធឡូជីស្ទីក, កិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលឱ្យកាន់តែទូលំទូលាយ ជាមួយអាជ្ញាធរដៃគូពាក់ព័ន្ធដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន, ការចល័តមនុស្ស និង ទំនិញ;
- ពង្រឹងសមត្ថភាពនាយកដ្ឋានជំរុញការនាំចេញនៃក្រសួងពាណិជ្ជកម្ម ឱ្យក្លាយជាភ្នាក់ងារជំរុញការនាំចេញ ដែលមានជំនាញខ្ពស់ក្នុងការវិភាគទីផ្សារនាំចេញ, កំណត់មុខសញ្ញានាំចេញ និងរៀបចំបណ្តាញធុរកិច្ច ដែលជាមូលដ្ឋានក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម, ផ្តល់ព័ត៌មានអំពី

ទីផ្សារក្រៅប្រទេស និង ជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំង ការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬការតាំងពិព័រណ៍;

- ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយ ដែលមានកាតព្វកិច្ចផ្តល់កម្ចីទៅឱ្យអ្នកនាំចេញណាដែលផលិតទំនិញនាំចេញក្នុងឧស្សាហកម្មអាទិភាព និង ផ្តល់នូវសេវាធានារ៉ាប់រងការនាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ;
- ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី, ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន, ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន;
- ពិចារណាបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និងនាំចេញបានចំនួនច្រើនជាងគេ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តពិសេស និងរង្វាន់នានា ចំពោះក្រុមហ៊ុនដែលបាននាំទំនិញដល់ចំនួនដែលបានកំណត់ តាមរយៈការវាយតម្លៃប្រកបដោយតម្លាភាព ដោយផ្សារភ្ជាប់នឹងគោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម;
- ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជា ពង្រឹងទំនាក់-ទំនងជាមួយនឹងរាជរដ្ឋាភិបាល ។

*<u>ខ- ការពង្រឹងបទដ្ឋានឧស្សាហកម្ម និង កម្មសិទ្ធិឧស្សាហកម្ម</u>*

- បន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្រ្ត និងស្តង់ដារ ដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និង ខិតខំប្រឹងប្រែងបន្តរៀបចំក្របខណ្ឌគតិយុត្តិ និង ការទទួលស្គាល់ជាអន្តរជាតិ នូវស្ថាប័នជាតិសំខាន់ៗ រួមមាន មជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិ និង វិទ្យាស្ថានស្តង់ដារកម្ពុជា;
- កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការផ្តល់សិទ្ធចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម;
- ពង្រឹងការប្រើប្រាស់ស្តង់ដារូបនីយកម្ម និង ការវាយតម្លៃការទទួលស្គាល់អនុលោមភាព ដោយផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ;
- បង្កើតការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃស្តង់ដារ, មាត្រាសាស្រ្ត និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទទួលទូលាយពីសំណាក់សហគ្រិន;
- ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចមាត្រាសាស្រ្ត និង ស្តង់ដារ ក្នុងការធានានូវបរិមាណគុណភាព, សុវត្ថិភាព, សេវាកម្ម, បរិស្ថាន និង គ្រប់គ្រង;

- ចាត់វិធានការជាក់ស្តែងក្នុងពង្រឹងការអនុវត្តស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខណ្ឌទាំងនេះឱ្យក្លាយឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង;
- ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ ***«មជ្ឈមណ្ឌលផលិតភាពកម្ពុជា»*** សំដៅលើកកម្ពស់ផលិតភាព និង គុណភាព ដល់សហគ្រាសធុនតូច និងមធ្យម;
- ពង្រឹងសមត្ថភាព ***«វិទ្យាស្ថានស្តង់ដារកម្ពុជា»*** ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដារជាតិសម្រាប់ផលិតផល, សេវាកម្ម, ផលិតកម្ម និង បច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និង អន្តរជាតិ;
- ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ក្នុងការសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់, ព្យាសកម្ម, តេស្តវិភាគ អនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលបំរើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម ។

*<u>គ- ការសម្រួលការបំពេញកាតព្វកិច្ចពន្ធ និង អាករ</u>*

- សិក្សាឡើងវិញពីប្រព័ន្ធពន្ធដារ និង ពន្ធគយ ដោយប្រែក្លាយឱ្យទៅជាឧបករណ៍ប្រមូលចំណូលផង និង ជាឧបករណ៍ជំរុញការអភិវឌ្ឍឧស្សាហកម្មផង;
- ធ្វើវិចារណកម្មយន្តការប្រមូលចំណូល និងកែលម្អសេវាអ្នកជាប់ពន្ធ សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ;
- បង្កើនការផ្តល់សេវាដើម្បីឱ្យអ្នកជាប់ពន្ធងាយស្រួលទទួលព័ត៌មានពីការបង់ពន្ធ និងការលើកលែងពន្ធ;
- ជំរុញការបង្វិលសងឱ្យបានឆាប់ ឬ ប្រើប្រាស់ជាឥណទានយោង (Tax Credit) ស្របតាមបទប្បញ្ញត្តិពន្ធដារជាធរមាន;
- ពិនិត្យ និង សម្រួលឡើងវិញនូវក្របខណ្ឌនៃការអនុវត្ត ដោយសម្រួល ឬ ដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្វាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និង ការលើកលែងពន្ធ ។

*<u>ឃ- ការរៀបចំទីផ្សារពលកម្ម និង ទំនាក់ទំនងវិជ្ជាជីវៈ</u>*

- បន្តពង្រឹងយន្តការទំនាក់ទំនងត្រីភាគី រួមមាន រាជរដ្ឋាភិបាល និយោជក និង និយោជិត តាមរយៈ ***«គណៈកម្មាធិការប្រឹក្សាការងារ»*** ដើម្បីបង្កើនការយោគយល់គ្នា, ទន្ទឹមនឹងការខិតខំរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដែលស៊ីចង្វាក់ទៅនឹងផលិតភាពការងារ, សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច- សង្គម និង ធានាបាននូវការអភិវឌ្ឍឧស្សាហកម្មជារួម;
- ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនងរវាងបុគ្គលិកនិយោជិក និង និយោជក ដើម្បីកំណត់ពីបទពិសោធន៍ល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយ ដែលអាចបង្កើនផលិតផល

សរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករ ស្របទៅតាមច្បាប់ការងារ និង បទប្បញ្ញត្តិជាធរមាន;

- រៀបចំច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីតុលាការការងារ;
- ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការពង្រីកកម្មវិធីរោងចក្រល្អប្រសើរ ឬពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមការងារចម្រុះធ្វើអធិការកិច្ចជាប្រចាំ និង មានកម្មវិធីច្បាស់លាស់ដើម្បីកាត់បន្ថយចំនួនត្រួតពិនិត្យផង និងធានាបានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យផង ។ ក្រុមការងារចម្រុះនេះ ត្រូវរាយការណ៍ជាទៀតទាត់ជូនរាជរដ្ឋាភិបាល;
- ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម, ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការ-បណ្តុះបណ្តាលកម្មករ ឱ្យយល់ពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន ជាពិសេសកាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ;
- លើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការជំរុញឱ្យមានគោលនយោបាយលំនៅដ្ឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី;
- ពិនិត្យឡើងវិញពីច្បាប់ស្តីពីការងារ, ច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងការអនុវត្តកន្លងមក ដើម្បីស្វែងរកចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ហើយធ្វើការគូសបញ្ជាក់ឡើងវិញពីតួនាទីរបស់និយោជក និង សហជីព ក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបាននូវតុល្យភាពនៃការអភិវឌ្ឍ និង សុខមាលភាពកម្មករ;
- ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេស ត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហ-រណកម្មអាស៊ាន;
- រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និង ការងារ ។

### ៦-៤)- ការសម្របសម្រួលគោលនយោបាយគាំទ្រ

*ក- ការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស*

- បង្កើតឱកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈ ការបង្កើតប្រព័ន្ធសម-មូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ;
- ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និង មធ្យមសិក្សា ដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន ផ្នែកគណិតវិទ្យា, វិទ្យាសាស្ត្រ, អក្សរសាស្ត្រ និង បច្ចេកវិទ្យា;

- ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ប្រាំបួនឆ្នាំ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា;
- កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (Soft Skills) រួមមាន ជំនាញទំនាក់ទំនងសង្គម ក្នុងការដោះស្រាយបញ្ហា, ការគោរពវិន័យនៅកន្លែងធ្វើការ និង ជំនាញជាច្រើនទៀត ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម;
- ពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីព និងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្តដើម្បីអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់;
- បង្កើនការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនដងជាងមុន តាមលទ្ធភាពលើជំនាញបច្ចេកទេស ជាពិសេស នៅក្នុងផ្នែកអគ្គិសនី, អេឡិចត្រូនិក, មេកានិក, ស្តង់ដារ, មាត្រាសាស្ត្រ (ត្រួតពិនិត្យផ្ទៀងផ្ទាត់, ព្យាសកម្ម, តេស្ត និងជំនាញប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ) និង គីមីសាស្ត្រ ទាំងក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស និង ឧត្តមសិក្សា;
- ផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន (ទាំងក្នុងប្រព័ន្ធអប់រំទូទៅ និង ក្រៅប្រព័ន្ធ) ដោយផ្តោតលើផ្នែកសំខាន់ៗ ដូចជា អគ្គិសនី, អេឡិចត្រូនិច, ព័ត៌មានវិទ្យា, កុំព្យូទ័រ, ម៉ាស៊ីន, ការជួសជុល និងការដំឡើងរថយន្ត និងម៉ូតូ, ការកែច្នៃកសិផល និងសិប្បកម្ម;
- រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម ដោយរួមមានផែនការវិនិយោគច្បាស់លាស់ និងក្នុងទស្សនវិស័យរយៈពេលវែង;
- ជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់ក្រុមហ៊ុននិងសហគ្រាស ដែលទទួលអនុវត្តតាមប្រព័ន្ធកម្មសិក្សានេះ;
- ពង្រឹងការបណ្តុះបណ្តាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជនទាំងវិន័យ កម្រិតជំនាញ និង សមត្ថភាព តាមរយៈការធ្វើសហប្រតិបត្តិការជាមួយនឹងវិនិយោគិនបរទេសគោលដៅ មានដូចជាការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញជប៉ុន, កូរ៉េ, សិង្ហបុរី ។ល។;
- ជំរុញការបណ្តុះបណ្តាលត្រីភាគី «រដ្ឋ- ស្ថាប័នបណ្តុះបណ្តាល- ក្រុមហ៊ុន/ រោងចក្រ» ដើម្បីបំពាក់ជំនាញ និង បង្កើនផលិតភាព ជាពិសេសការដាក់បញ្ចូលក្នុងកម្មវិធីអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និង សមាគមឧស្សាហកម្ម;
- ពង្រីកការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈនៅនឹងកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឱ្យពលករទាំងនោះទទួលបានការអប់រំបណ្តុះបណ្តាល និង ផ្តល់ក្តីសង្ឃឹមក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេស ក្នុងពេលអនាគត;

- ពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម, វិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗផ្សេងទៀត និងវិស្វកម្ម ដោយពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

*ខ- ការជំរុញវិទ្យាសាស្ត្រ, បច្ចេកវិទ្យា និង នវានុវត្តន៍*

- ជំរុញការរៀបចំនូវក្របខណ្ឌគោលនយោបាយ និង យន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ, បច្ចេកវិទ្យា និងនវានុវត្តន៍;
- ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម;
- ពង្រឹងការគ្រប់គ្រងមណ្ឌលច្នៃប្រឌិតនិងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម និងការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម;
- ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម;
- សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ, បច្ចេកវិទ្យា និងនវានុវត្តន៍;
- សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និង តំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម;
- បង្កើតយន្តការប្រលងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា, អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច និង វិស្វករដែលមានទេព្យកោសល្យ ដើម្បីចម្រាញ់ឧស្សាហករដែលមានទេព្យកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសនៅក្នុងចំណោមវិស្វករ និង សហគ្រិនវ័យក្មេង;
- ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាពិសេសពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើសអ្នកវិទ្យាសាស្ត្រ និង វិស្វករមានសមត្ថភាព ជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប;
- ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ, បច្ចេកទេស, វិស្វកម្ម និង គណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា ជាពិសេសផ្តោតលើសិស្សក្មេងៗ ជាមួយនឹងការកែទម្រង់កម្មវិធីសិក្សាដោយការធ្វើស្តង់ដាររូបនីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ;
- ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់ ។

*គ- ការកសាង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម*

- បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់, ផ្លូវរថភ្លើង, ផ្លូវអាកាស និង កំពុងផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់គោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម;
- ពិនិត្យតម្រង់ការផ្គត់ផ្គង់ថាមពល ទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់ចរន្តអគ្គិសនី ស្របតាមតម្រូវការ និងមានស្ថិរភាពបំផុត ដែលអនុញ្ញាតឱ្យរោងចក្រអាចគ្រោងផលិតកម្មខ្លួនប្រកបដោយប្រសិទ្ធភាព;
- អនុវត្តគម្រោងកសាងស្ថានីយ៍ផលិតអគ្គិសនីដែលបានគ្រោង និង កំពុងបន្តអនុវត្តឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនីនៅឆ្នាំ ២០២០ រួមទាំង ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និង គុណភាពនៃការបញ្ជូនថាមពល;
- ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍវិស័យថាមពល ធៀបនឹងចក្ខុវិស័យថ្មីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម រួមទាំងពិនិត្យឡើងវិញនូវជម្រើសក្នុងការផ្គត់ផ្គង់ថាមពល ដែលមានសមត្ថភាពគ្រប់គ្រាន់ ជាពិសេសសម្រាប់ផ្គត់ផ្គង់តំបន់ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ;
- បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង កែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន ដើម្បីសម្រួល និង ជួយគាំទ្រប្រតិបត្តិការអាជីវកម្ម;
- ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី, ទីប្រជុំជន, តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាពអង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និង អនុលោមតាមស្តង់ដារទឹកបរិភោគជាតិ;
- បន្តពង្រីក និង ថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេសផ្លូវជាតិច្រករបៀងសេដ្ឋកិច្ចខាងត្បូង ឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយ ដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និង វៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ-សៀមរាប និង ភ្នំពេញ-ក្រុងព្រះសីហនុ, ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាងផ្លូវហាយវេចំពោះផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធឡូជីស្ទីករវាងកម្ពុជា និង ប្រទេសដ៏ទៃទៀត ជាអាទិ៍ ប្រទេសថៃ និង វៀតណាម;
- ធ្វើឱ្យប្រសើរឡើង និង ថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមាន ប្រព័ន្ធផ្លូវថ្នល់ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេសនៅខេត្តស្វាយរៀង និង កោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និង ខេត្តព្រះសីហនុ ដែលមានកំពង់ផែសមុទ្រអន្តរជាតិ;

- បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុ បានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន;
- អភិវឌ្ឍបណ្ដាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្ដានុពលក្នុងការកាត់បន្ថយចំណាយឡូជីស្ទីក ជាពិសេសសម្រាប់ការដឹកជញ្ជូនកសិផល ដោយកសាងកំពង់ផែតូចៗ ដែលអាចឱ្យនាវាដឹកជញ្ជូន ចូលផ្ទុក និង ផ្ទេរទំនិញនៅតាមដងទន្លេមេគង្គ ស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និង ខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវា ក្នុងបរិមាណកាន់តែច្រើន;
- ដោះស្រាយបញ្ហាកកស្ទះចរាចរនៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយឡូជីស្ទីកកើនឡើងជាប្រចាំ ពិសេសការកសាងផ្លូវក្រវ៉ាត់ក្រុង ឬ ផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យបានចរាចរប្រព្រឹត្តទៅដោយរលូន តាមផ្លូវច្រករបៀងសេដ្ឋកិច្ចខាងត្បូង;
- ពិនិត្យលទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និង វិស័យឯកជន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលអាចបន្ធូរបន្ទុកវិនិយោគសាធារណជន ។

*ឃ-វិធានការផ្នែកហិរញ្ញប្បទាន*

- បន្តអនុវត្ត ***«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០»*** ដែលជាក្របខណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា;
- សិក្សា និង រៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេស ការផ្ដល់កម្ចីដល់សហគ្រាសធុនតូច និង មធ្យម ព្រមទាំងជំរុញការផ្ដល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព;
- កែលម្អប្រសិទ្ធភាព និង អភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជន៍ និងការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម;
- ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភពហិរញ្ញវត្ថុ និង ប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្ររតនាគារ ក្នុងរយៈពេលមធ្យមទៅវែង ដើម្បីធ្វើហិរញ្ញប្បទាន គម្រោងអភិវឌ្ឍន៍ ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម;
- ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និង ការកែទម្រង់មូលនិធិសោធន និង វិស័យធានារ៉ាប់រង ដែលមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ;
- ផ្ដល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោង និង កម្មវិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កន្សោមឧស្សាហកម្ម ឬ របៀងឧស្សាហកម្ម ។

## ទិធានការដាក់ស្តែងគន្លឹះបួន ដើម្បីជំរុញការអនុវត្ត
## «គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»

បន្ថែមលើការដាក់ចេញនូវវិធានការគោលនយោបាយ និង ផែនការសកម្មភាពខាងលើ រាជរដ្ឋាភិបាលនឹងអនុវត្តនូវ **វិធានការដាក់ស្តែងគន្លឹះបួនយ៉ាង** ឱ្យសម្រេចបាននៅមុនដំណាច់ឆ្នាំ ២០១៨ ដែលជាបង្គោលចរដ៏សំខាន់សម្រាប់វាស់វែងកិច្ចខិតខំប្រឹងប្រែង និង វឌ្ឍនភាពនៃការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ព្រមទាំងជាមូលដ្ឋាន និង បុរេលក្ខខណ្ឌមិនអាចខ្វះបាន ដែលនឹងកំណត់នូវជោគជ័យក្នុងការអនុវត្តនូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃគោលនយោបាយនេះ ដោយ ÷

**ទី១)** - រៀបចំ និង អនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និង ការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី:

- *បញ្ចុះថ្លៃទិញពីអនុស្ថានីយផ្ទាល់មកត្រឹម* ***១២,៦០ សេនអាមេរិក*** *ក្នុង ១គីឡូវ៉ាត់ម៉ោង;*
- *បញ្ចុះថ្លៃទិញពីប្រព័ន្ធភ្នំពេញ កណ្តាល និងកំពង់ស្ពឺ របស់អគ្គិសនីកម្ពុជាមកត្រឹម* ***១៦,៥០សេនអាមេរិក*** *ក្នុង ១គីឡូវ៉ាត់ម៉ោង;*
- *បញ្ចុះថ្លៃទិញពីខ្សែបញ្ជូនរងនានា ដែលចេញពីអនុស្ថានីយ (ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់សេវាកររងកជន) មកត្រឹមឯកតាថ្លៃរួមមួយ* ***១៦,៨០សេនអាមេរិក*** *ក្នុង ១គីឡូវ៉ាត់ម៉ោង;*
- *អនុម័តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃ- យប់ សម្រាប់ឧស្សាហកម្ម;*
- *ពង្រីកវិសាលភាពគ្រប់ដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីឱ្យដល់គ្រប់តំបន់ឧស្សាហកម្មគោលដៅ;*
- *ធានាស្ថិរភាព និង ភាពទុកចិត្តបាននៃការផ្គត់ផ្គង់អគ្គិសនី ដោយកាត់បន្ថយអត្រាដាច់ចរន្តមិនឱ្យលើសពី ១២ដង ឬ ២៤ម៉ោង/ឆ្នាំ ។*

រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការបន្ថយអត្រា និង គម្លាតថ្លៃអគ្គិសនីសម្រាប់ឧស្សាហកម្ម និង ពាណិជ្ជកម្មធំៗ រហូតដល់ឆ្នាំ ២០២០ ដូចមានភ្ជាប់ក្នុង **ឧបសម្ព័ន្ធ«ខ»** ។

**ទី២)** - រៀបចំ និង អនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និង ឡូជីស្ទីក ក្នុងគោលដៅបង្កើតនូវប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងប្រព័ន្ធឡូជីស្ទីកដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ពិសេសផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និង ការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ***ភ្នំពេញ- ខេត្តព្រះសីហនុ, ភ្នំពេញ- បាវិត*** និង ***ភ្នំពេញ- ប៉ោយប៉ែត*** ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវហាយវេស្តង់ដារអន្តរជាតិ និង ការបង្កើតប្រព័ន្ធឡូជីស្ទីកប្រកបដោយប្រសិទ្ធភាព ។

**ទី៣)-** ពង្រឹង និង បន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និង ការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម, លើកកម្ពស់ផលិតភាព និង កែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បរមា និង ការពង្រឹងសុខដុមភាពនៃទំនាក់ទំនងឧស្សាហកម្ម ដោយឈរលើគោលការណ៍ត្រីយាបថវិជ្ជមានរបស់សហជីព និង ព្រហ្មវិហារធម៌របស់និយោជកចំពោះនិយោជិត តាមរយៈយន្តការមានស្រាប់បច្ចុប្បន្ន រួមមានជាអាទិ៍ យន្តការ ***«គណៈកម្មាធិការប្រឹក្សាការងារ»*** និង ***«គណៈកម្មាធិការផលិតភាពកម្ពុជា»*** ។

**ទី៤)-** អភិវឌ្ឍ និង ប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍ, ក្របខណ្ឌច្បាប់ និង និយ័តកម្ម ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដែលនឹងផ្តល់សិទ្ធអំណាចនិងយុត្តាធិការពេញលេញ សម្រាប់ការកៀរគរ, ទាក់ទាញ និង ប្រមូលផ្តុំនូវប្រភពធនធាន, បញ្ញាញាណ, សកម្មភាពធុរកិច្ច និង ការវិនិយោគ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និង ជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និង ទេសចរណ៍ ស្របតាមទស្សនទាននៃការអភិវឌ្ឍប្រកបដោយចីរភាព និង មានតុល្យភាពបរិស្ថាន ព្រមទាំងប្រែក្លាយជា **ទីក្រុងឧស្សាហកម្មបៃតងអាស៊ាន** នាពេលអនាគត ។

## ៧)-យន្តការដឹកនាំ, សម្របសម្រួល និង អនុវត្តគោលនយោបាយ

ការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ទាមទារនូវមគ្គុទេសក៍ដឹកនាំប្រកបដោយឆន្ទៈក្លៀវក្លា ការសម្របសម្រួលដែលមានប្រសិទ្ធភាពខ្ពស់ និង ការចូលរួមយ៉ាងសកម្មពីសំណាក់គ្រប់ដៃគូពាក់ព័ន្ធ ដើម្បីសម្រេចនូវចក្ខុវិស័យ និង គោលដៅរួមនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលប្តេជ្ញាមោះមុតដើម្បីបំពេញតួនាទីជាយុទ្ធសាស្ត្រវិទូ, ជាអ្នកសម្របសម្រួល, គាំទ្រ និង ជាអ្នកផ្តួចផ្តើមគំនិត ប្រកបដោយសុច្ចរិតភាព និង ការទទួលខុសត្រូវខ្ពស់ នៅក្នុងយុទ្ធនាការជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និង ការអភិវឌ្ឍវិស័យឧស្សាហកម្មជាប្រវត្តិសាស្ត្រនេះ ដោយរៀបចំឱ្យមានយន្តការសម្របសម្រួលនិងស្ថាប័នអនុវត្ត ដែលមានសិទ្ធិអំណាចពេញលេញ មានសមត្ថភាពវិជ្ជាជីវៈខ្ពស់ និង ធនធានគ្រប់គ្រាន់ ដើម្បីជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព និងសក្តិសិទ្ធភាពនូវគម្រោង, កម្មវិធី និង គំនិតផ្តួចផ្តើមនានា ដែលស្ថិតក្រោមក្របខណ្ឌនៃគោលនយោបាយនេះ។

ក្នុងគោលដៅខាងលើ រាជរដ្ឋាភិបាលនឹងដាក់ចេញវិធានការកែទម្រង់ស្ថាប័នស៊ីជម្រៅ ដោយផ្តល់សិទ្ធិអំណាចពេញលេញ និង បំពាក់មុខងារចាំបាច់សំខាន់ៗជូន ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ក្នុងការសម្រេចចិត្តផ្នែកគោលនយោបាយ, ការរៀបចំ និង អនុវត្តផែនការ ក៏ដូចជា ការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យឧស្សាហកម្ម ដើម្បីឱ្យស្ថាប័ននេះក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ដឹកនាំ, សម្របសម្រួល និង ជំរុញការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ។ ជាគោលការណ៍រួម រាជរដ្ឋាភិបាលនឹងរៀបចំកែសម្រួលឡើង

វិញនូវរចនាសម្ព័ន្ធអភិបាលកិច្ចនៃ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ដូចមាននៅក្នុងឧបសម្ព័ន្ធ «ក» ដោយផ្ដោតលើៈ *ទី១-* ការពង្រឹងតួនាទីដឹកនាំនយោបាយរបស់ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ក្នុងការចង្អុលទិស អនុម័ត និង តាមដានសមិទ្ធកម្មនៃការអនុវត្តផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដោយសម្របសម្រួលជាមួយ«គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» និង «គណៈកម្មាធិការដឹកនាំការអភិវឌ្ឍវិស័យឯកជន» ព្រមទាំងស្ថាប័នជំនាញពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល, *ទី២-* ការកែសម្រួលមុខងារ និង ពង្រឹងសមត្ថភាព ***«គណៈកម្មាធិការវិនិយោគកម្ពុជា»*** ដោយបំពាក់បន្ថែមនូវមុខងារសម្របសម្រួល និង ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម រួមទាំងការរៀបចំ និងអនុវត្តផែនការសម្រាប់អភិវឌ្ឍវិស័យនេះ ដោយសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម, *ទី៣-* ការតម្រង់ទិសមុខងារគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហ-កម្ម ក្នុងក្របខណ្ឌនៃការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និង ផែនការវិនិយោគសាធារណៈសម្រាប់វិស័យឧស្សាហកម្ម, *ទី៤-* ការពង្រឹង និង តម្រង់ទិសយន្តការ ***«វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន»*** ដើម្បីផ្សព្វ-ផ្សាយ និង លើកទឹកចិត្ត ការចូលរួមពីវិស័យឯកជន និង *ទី៥-* ការរៀបចំយន្តការតាមដាន និង ត្រួតពិនិត្យ ។

### *៧-១) - ការពង្រឹងតួនាទីនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

ការពង្រឹងតួនាទីរបស់ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ក្នុងការសម្រេចចិត្តផ្នែកគោលនយោបាយ ឱ្យទទួលភារកិច្ចជាក្រុមប្រឹក្សាភិបាលសម្រាប់ដឹកនាំការអភិវឌ្ឍវិស័យឧស្សាហកម្ម និង ការវិនិយោគនៅកម្ពុជា ព្រមទាំងមានសិទ្ធិអំណាចពេញលេញ ក្នុងការដឹកនាំ និង សម្របសម្រួលការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ÷

- ពិនិត្យ និង កែសម្រួលលក្ខន្តិកៈ, ការរៀបចំ និង ការប្រព្រឹត្តទៅ ក៏ដូចជាសមាសភាពនៃ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ក្នុងក្របខណ្ឌនៃការធ្វើវិសោធនកម្មលើច្បាប់វិនិយោគ រួមទាំង ការធ្វើបច្ចុប្បន្នកម្ម និងសមាហរណកម្មមុខងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា, គណៈកម្មាធិការវិនិយោគកម្ពុជា និង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា;
- ប្រើប្រាស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន និង អនុគណៈកម្មាធិការពាក់ព័ន្ធតាមវិស័យនីមួយៗ ជាយន្តការពិគ្រោះយោបល់ផ្នែកគោលនយោបាយ ដែលមានវិសាលភាពពេញលេញសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្ម និង សកម្មភាពកំណែទម្រង់រចនាសម្ព័ន្ធពាក់ព័ន្ធ ។ យន្តការនេះ មានមុខងារជាសេនាធិការឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដោះស្រាយបញ្ហាប្រឈមជាគោលនយោបាយ ដែលមានចរិតនយោបាយផង និងមានបដិវាទស្ថាប័នផង ព្រមទាំងតម្រូវឱ្យមានការសម្របសម្រួលស្ថាប័នក្នុងកម្រិតខ្ពស់ ។ យន្តការនេះ មានភារកិច្ចស្នើឡើង និងដាក់ចេញនូវវិធានការបន្ទាន់ចាំបាច់ចំពោះមុខ, កែសម្រួល និង ធ្វើបច្ចុប្បន្នកម្មគោលនយោបាយដើម្បីឱ្យ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យ***

***ឧស្សាហកម្ម»*** ក្លាយជាឯកសាររស់ និងជាឧបករណ៍ស័ក្តិសិទ្ធិ ដើម្បីសម្រេចចក្ខុវិស័យនៃការប្រែក្លាយឧស្សាហកម្មកម្ពុជាឱ្យក្លាយជាឧស្សាហកម្មផ្អែកលើជំនាញ ត្រឹមឆ្នាំ ២០២៥;

- ពង្រឹង ***«អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ទាំងសមត្ថភាពវិជ្ជាជីវៈ និង ធនធានហិរញ្ញវត្ថុ សម្រាប់ផ្តល់ការគាំទ្រដល់សកម្មភាពការងារប្រចាំថ្ងៃ និងការសម្រេចចិត្តរបស់ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»***;
- បង្កើតក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា (Cambodia Industrial Development Advisory Board) ដែលមានសមាសភាពជាឥស្សរជនពីរាជរដ្ឋាភិបាល, មជ្ឈដ្ឋានសិក្សាស្រាវជ្រាវ និង វិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស ដែលមានចំណេះដឹង និងបទពិសោធន៍ស៊ីជម្រៅអំពីធុរកិច្ចអន្តរជាតិ, ដែលមានឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ច ជាប្រធាន, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាអនុប្រធាន, និងមានរដ្ឋមន្ត្រី និងប្រធាននៃក្រសួង/ស្ថាប័នពាក់ព័ន្ធផ្សេងទៀត រួមទាំង អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, អគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងអគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា ជាអនុប្រធាន និង ជាសមាជិក តាមការចាំបាច់ ។ ក្រុមប្រឹក្សាផ្តល់យោបល់នេះ មានភារកិច្ចផ្តល់អនុសាសន៍ជាចក្ខុវិស័យអំពីយុទ្ធសាស្ត្រ និង ការកំណត់ទិសដៅអាទិភាព ក៏ដូចជាការណែនាំអំពីវិធីសាស្ត្រអនុវត្តជាក់ស្តែងជូនគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និង គណៈកម្មាធិការវិនិយោគកម្ពុជា ដែលជាស្ថាប័នអនុវត្តផ្ទាល់សម្រាប់រៀបចំ និងអនុវត្តផែនការសកម្មភាពតាមភារកិច្ចរៀងៗខ្លួន ។

### ***៧-២)- ការកែសម្រួលមុខងារ និងពង្រឹងសមត្ថភាពគណៈកម្មាធិការវិនិយោគកម្ពុជា***

រាជរដ្ឋាភិបាលនឹងកែសម្រួលមុខងារ និង ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឱ្យមានតួនាទីជាសេនាធិការប្រតិបត្តិនៃ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ដើម្បីដឹកនាំ, សម្របសម្រួល និង អនុវត្តផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និង ការវិនិយោគ រួមទាំង កិច្ចសម្រួលពាណិជ្ជកម្ម និង បរិយាកាសវិនិយោគ ÷

- កែសម្រួលមុខងារស្ថាប័នរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ដោយធ្វើសមាហរណកម្មមុខងារនៃការគ្រប់គ្រងការវិនិយោគ, ការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ជាមួយការងារអភិវឌ្ឍឧស្សាហកម្មកម្មន្តសាល និង សហគ្រាសធុនតូចនិងមធ្យម;
- រៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រង និង អនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័នរបស់គណៈកម្មាធិការវិនិយោគកម្ពុជា រួមមាន ប្រព័ន្ធអភិបាលកិច្ច និង ការគ្រប់គ្រង, ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ, បរិស្ថានការងារ, ក្រមសីលធម៌វិជ្ជាជីវៈ និង ការលើកទឹកចិត្ត ព្រមទាំងផែនការការងារការបែងចែកច្បាស់លាស់អំពីភារកិច្ច, មុខងារ និង ការទទួលខុសត្រូវដល់មន្ត្រីទទួលបន្ទុក;

- ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងការវិនិយោគ និង ការអភិវឌ្ឍវិស័យឧស្សាហកម្ម, កែលម្អ និង ពង្រឹងយន្តការអនុម័ត និង សម្របសម្រួលការអនុវត្តគម្រោងវិនិយោគ, ជំរុញការផ្សព្វផ្សាយទាក់ទាញវិនិយោគ, និងសម្របសម្រួលគម្រោង ឬ កម្មវិធីវិនិយោគសាធារណៈសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម;
- ពិចារណាបង្កើតនូវទីភ្នាក់ងារប្រតិបត្តិពិសេសមួយចំនួន នៅក្នុង ***«គណៈកម្មាធិការវិនិយោគកម្ពុជា»*** ជាសេនាធិការ សម្រាប់អនុវត្តផែនការសកម្មភាព ឬ គំនិតផ្តួចផ្តើមជំរុញការអភិវឌ្ឍវិស័យកម្មន្តសាល និង សហគ្រាសធុនតូចនិងមធ្យម ពាក់ព័ន្ធនឹងការវិនិយោគផ្ទាល់ពីបរទេស សម្រាប់សម្របសម្រួលប្រភពហិរញ្ញប្បទាន, បណ្តុះបណ្តាលជំនាញ, អភិវឌ្ឍបច្ចេកទេស និង បច្ចេកវិទ្យា ក៏ដូចជាអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស (ឧបសម្ព័ន្ធ «ខ»);
- លើកកម្ពស់ប្រសិទ្ធភាពការងារសម្របសម្រួល, កិច្ចសម្រួលពាណិជ្ជកម្ម និង បរិយកាសវិនិយោគ/ធុរកិច្ច តាមរយៈ ការពង្រឹង ***«យន្តការច្រកចេញចូលតែមួយ»*** ព្រមទាំងប្រើប្រាស់យន្តការនេះសម្រាប់ជំរុញការអនុវត្តគោលនយោបាយតាមវិស័យដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដោយផ្តោតជាសំខាន់លើការកែលម្អក្របខណ្ឌច្បាប់ និង និយ័តកម្ម ក៏ដូចជានីតិវិធីអនុវត្តផ្សេងៗ ដែលរួមចំណែកដល់ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ, ការកៀរគរ និង ការវិភាជន៍ធនធានបម្រើឱ្យវិស័យឧស្សាហកម្ម, ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីក, ការអភិវឌ្ឍធនធានមនុស្ស និង ការតម្រង់ទិសជំនាញ, ការអភិវឌ្ឍស្តង់ដារបច្ចេកវិទ្យា និង នវានុវត្តន៍, ការគ្រប់គ្រងបរិស្ថាន ព្រមទាំងការសម្របសម្រួលធាតុចូល ឬ ការផ្គត់ផ្គង់ វត្ថុធាតុដើម ដូចជា អគ្គិសនី កសិផល រ៉ែ ដីធ្លី;
- ពង្រឹងការងារសិក្សា និងរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីផ្សារភ្ជាប់ការវិនិយោគឯកជន ជាមួយកម្មវិធីវិនិយោគសាធារណៈ ក្នុងគោលដៅបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម រួមមាន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ កម្មវិធីស្រាវជ្រាវ និង អភិវឌ្ឍន៍ផលិតផលថ្មីៗ, ការបណ្តុះបណ្តាលជំនាញ និង បច្ចេកទេស ក៏ដូចជាការអភិវឌ្ឍឧស្សាហកម្មថ្មី និង យុទ្ធសាស្ត្រ;
- បំពាក់មុខងារសម្របសម្រួល និង ផ្សព្វផ្សាយអំពីគោលនយោបាយ រួមទាំង ក្របខណ្ឌប្រតិបត្តិការទៅឱ្យដៃគូពាក់ព័ន្ធ ជាស្ថាប័នរដ្ឋ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាបានកិច្ចសហប្រតិបត្តិការពេញលេញសម្រាប់ការអនុវត្តគម្រោងវិនិយោគ ឱ្យប្រព្រឹត្តទៅដោយរលូន និង មានប្រសិទ្ធភាព ព្រមទាំងផ្តល់នូវការរំពឹងទុកអំពីទិសដៅអនុវត្ត និង ការចូលរួមសកម្មពីភាគីពាក់ព័ន្ធ នៅគ្រប់លំដាប់ថ្នាក់ ។

### ៧-៣)- ការតម្រង់ទិសមុខងារគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា

រាជរដ្ឋាភិបាលនឹងតម្រង់ទិសមុខងារ និង ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ឱ្យមានតួនាទីជាសេនាធិការប្រតិបត្តិនៃ ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ដើម្បីដឹកនាំ, សម្របសម្រួល និង អនុវត្តផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការវិនិយោគកម្ពុជា តាមរយៈ ÷

- កែសម្រួលមុខងារស្ថាប័នរបស់គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា ដើម្បីគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មកម្មន្តសាល និង សហគ្រាសធុនតូចនិងមធ្យម;
- ពង្រឹងភារកិច្ចសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ក្នុងក្របខណ្ឌនៃ ***«វេទិកាសហប្រតិបត្តិអភិវឌ្ឍន៍កម្ពុជា»*** និង ក្រុមការងារចម្រុះតាមវិស័យ ដើម្បីកៀរគរជំនួយបច្ចេកទេស, ការវិនិយោគ និង ហិរញ្ញប្បទាន សម្រាប់ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និង បរិយាកាសវិនិយោគ, ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ឡូជីស្ទីក និង ឌីជីថល, ការអភិវឌ្ឍធនធានមនុស្ស និង ជំនាញ, ការអភិវឌ្ឍបច្ចេកវិទ្យា និង នវានុវត្តន៍, ការគ្រប់គ្រងផលប៉ះពាល់បរិស្ថានដោយសារឧស្សាហកម្ម និង ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត និងវត្ថុធាតុដើមឧស្សាហកម្មផ្សេងទៀត;
- ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅរួមចំណែកដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម, កែលម្អ និង ពង្រឹងយន្តការអនុម័ត និង សម្របសម្រួល ការអនុវត្តគម្រោងវិនិយោគសាធារណៈ, ជំរុញការផ្សព្វផ្សាយ និង ទាក់ទាញការវិនិយោគពីដៃគូ អភិវឌ្ឍន៍, និង ពង្រឹងការសម្របសម្រួលគម្រោង ឬ កម្មវិធីវិនិយោគសាធារណៈសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម;
- កែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រង និង ស្ថាប័ន ដូចជា ប្រព័ន្ធអភិបាលកិច្ច និង គ្រប់គ្រង, ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និង ហិរញ្ញវត្ថុ, បរិស្ថានការងារ, ក្រមសីលធម៌វិជ្ជាជីវៈ និង ប្រព័ន្ធលើកទឹកចិត្ត ព្រមទាំងការរៀបចំផែនការការងារ និង ការបែងចែកច្បាស់លាស់នូវតួនាទី, ភារកិច្ចមុខងារ និង ការទទួលខុសត្រូវ ដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ ។

### ៧-៤)- ការពង្រឹងយន្តការពិគ្រោះយោបល់ជាមួយវិស័យឯកជន

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការពិគ្រោះយោបល់ជាមួយវិស័យឯកជន តាមរយៈ***«វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន»*** ដោយប្រើប្រាស់វេទិកានេះជាយន្តការផ្សព្វផ្សាយ និង តម្រង់ទិសការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ។ ***«គណៈកម្មាធិការវិនិយោគកម្ពុជា»*** មានតួនាទីសម្របសម្រួលកិច្ចដំណើរការនៃវេទិកានេះ ដែលទាមទារនូវការរៀបចំផែនការច្បាស់លាស់ និង សមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស រួមមាន លេខាធិការដ្ឋានប្រកបដោយវិជ្ជាជីវៈ ដែលមានសមត្ថភាពស្មើឡើងនូវរបៀបវារៈ

សម្រាប់ការពិគ្រោះយោបល់, សមត្ថភាពវិភាគស្រាវជ្រាវ និង ប្រមូលព័ត៌មាន ជាមូលដ្ឋានសម្រាប់ការពិភាក្សា និង សមត្ថភាពសម្របសម្រួលជាមួយបណ្តាញធុរកិច្ច និង ស្ថាប័នទំនាក់ទំនងអន្តរវិជ្ជាជីវៈ ។

ជាទិសដៅ រាជរដ្ឋាភិបាលនឹងជំរុញ ***«វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន»*** ឱ្យក្លាយជាយន្តការដែលមានប្រសិទ្ធភាព សម្រាប់ប្រមូលផ្តុំធាតុចូល, គំនិត, បញ្ញាញាណ និង មតិយោបល់ ដើម្បីកែលម្អគោលនយោបាយ និង ការអនុវត្ត ដើម្បីឱ្យរាជរដ្ឋាភិបាលអាចដាក់ចេញនូវវិធានការទាន់ពេលវេលា ដែលនឹងធានានូវផលប្រយោជន៍របស់គ្រប់ភាគីពាក់ព័ន្ធ, ធានាការប្រកួតប្រជែងស្មើភាព និង បរិយាកាសវិនិយោគអំណោយផល ។ ក្នុងក្របខណ្ឌនេះ រាជរដ្ឋាភិបាលនឹងជំរុញការពិគ្រោះយោបល់ឱ្យកាន់តែស៊ីជម្រៅ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើមុខសញ្ញាវិនិយោគិន ដែលមានសក្តានុពលសំខាន់ៗ ពិសេស វិនិយោគិនពីប្រទេសចិន, ជប៉ុន, កូរ៉េ, ថៃ និង វៀតណាម ព្រមទាំងអ្នកវិនិយោគពីប្រទេសដៃគូសំខាន់ៗផ្សេងទៀត ក៏ដូចជាវិនិយោគិនក្នុងស្រុកផងដែរ ។

### ***៧-៥ ) - ការតាមដាន - ត្រួតពិនិត្យការអនុវត្តគោលនយោបាយ***

ដើម្បីធានាវឌ្ឍនភាពជាប្រចាំ, ប្រសិទ្ធភាព និង សង្គតិភាពនៃការអនុវត្តគោលនយោបាយ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន ***«ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា»*** ឱ្យរៀបចំ និងសម្របសម្រួលអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រព័ន្ធតាមដាន និង ត្រួតពិនិត្យមួយ ដែលរួមមាន៖

- ប្រព័ន្ធរាយការណ៍ប្រចាំត្រីមាស និង ប្រចាំឆ្នាំ ពិសេស របាយការណ៍ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីរៀងរាល់ ៣ ខែម្តង ដើម្បីត្រួតពិនិត្យលើវឌ្ឍនភាព និង បញ្ហាប្រឈម ដោយផ្អែកលើគោលដៅ និង សូចនាករដែលបានកំណត់ខាងលើ និង ធ្វើការសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ ដែលកើតមានឡើងក្នុងពេលអនុវត្ត ។
- យន្តការដោះស្រាយបញ្ហា និង វិវាទឧស្សាហកម្ម (Trouble Shooting Mechanism) ។
- ការត្រួតពិនិត្យវាយតម្លៃអំពីវឌ្ឍនភាព និង ការសម្រេចនូវវិធានការជាក់ស្តែងគន្លឹះបួនយ៉ាងនៃ ***«គោល-នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា»*** ត្រឹមដំណាច់ឆ្នាំ ២០១៨ និង ការត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិក្នុងទ្រង់ទ្រាយធំ និង ទូលំទូលាយលើគោលនយោបាយនេះនៅឆ្នាំ ២០២០ ដើម្បីជាមូលដ្ឋានកែតម្រូវ និង តម្រង់ទិសដល់ការអនុវត្តបន្ត ។

## ៨) - ការគ្រប់គ្រងហានិភ័យសំខាន់ៗ

ក្រៅពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដូចបានគិតគូរខាងលើ ជោគជ័យនៃការអនុវត្ត ***«គោល-នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ក៏នឹងចំណុះផងដែរលើការប្រែប្រួលនៃសភាពការណ៍តំបន់ និងពិភព-លោក ក៏ដូចជាសភាពការណ៍ក្នុងស្រុក ដែលនឹងជះឥទ្ធិពលដោយប្រយោល ឬ ដោយផ្ទាល់ចំពោះដំណើរការពិពិធកម្ម ភាពប្រកួតប្រជែង និង ផលិតភាពនៃឧស្សាហកម្មកម្ពុជា តាមរយៈការប្រែប្រួលនៃប៉ារ៉ាម៉ែត្រម៉ាក្រូ-សេដ្ឋកិច្ច, របបពាណិជ្ជកម្ម និង វិនិយោគ ក៏ដូចជាភាពរអាក់រអួល ឬ ភាពរំខានផ្សេងទៀតដែលបណ្តាលមកពី

អស្ថិរភាព និងវិបត្តិភូមិសាស្ត្រនយោបាយ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលប្រមើលឃើញនូវហានិភ័យចម្បងៗមួយចំនួនដូច ខាងក្រោម ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និង ត្រៀមលក្ខណៈដោះស្រាយ ÷

*ទី១) ហានិភ័យពាក់ព័ន្ធនឹងការប្រែប្រួលបរិការណ៍តំបន់ និង ពិភពលោក:*

ទោះបីបរិការណ៍តំបន់ និង ពិភពលោកបច្ចុប្បន្នអំណោយផលដល់សមាហរណកម្មខ្សែចង្វាក់តម្លៃ និង ផលិតកម្មក្តី ប៉ុន្តែ កម្ពុជាអាចនឹងប្រឈមចំពោះហានិភ័យមួយចំនួននាពេលអនាគត ពិសេស ដោយសារវិបត្តិហិរញ្ញវត្ថុសកល, ការប្រែប្រួលរបបពាណិជ្ជកម្មដែលបណ្តាលពីនិន្នាការគាំពារនិយម, ការហូរត្រឡប់ទៅវិញនៃវិនិយោគផ្ទាល់ពីបរទេស, បញ្ហាសន្តិសុខថាមពល និង ភាពរអាក់រអួលនៃខ្សែចង្វាក់ផលិតកម្ម និង ការផ្គត់ផ្គង់វត្ថុធាតុដើម ដែលបណ្តាលមកពីអស្ថិរភាព និង ជម្លោះក្នុងតំបន់ ។

*ទី២) ហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច:*

កំណើនប្រាក់ឈ្នួលពលកម្ម គឺជាបាតុភូតដែលមិនអាចចៀសផុត នៅក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលធម្មតាត្រូវបានកំណត់ដោយកំណើននៃអតិផរណា និង កំណើននៃផលិតភាពការងារ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងធានារក្សានូវអតិផរណាឱ្យស្ថិតក្នុងកម្រិតដែលទាប និង អាចគ្រប់គ្រងបាន ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់លើការបង្កើនផលិតភាពការងារ តាមរយៈការវិនិយោគក្នុងកំណែទម្រង់វិស័យអប់រំ, បណ្តុះ-បណ្តាលជំនាញ និង ការពង្រឹងយន្តការកែលម្អទំនាក់ទំនងឧស្សាហកម្ម ដែលជាកត្តាសំខាន់បំផុតក្នុងការអនុញ្ញាតឱ្យប្រាក់ឈ្នួលកើនឡើង ដោយមិនប៉ះពាល់ជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជា ។ ម្យ៉ាងវិញទៀត ឱនភាពថវិកាដែលកើតឡើងដោយវិបត្តិសេដ្ឋកិច្ច, វិបត្តិហិរញ្ញវត្ថុ ឬ ក៏ភាពយឺតយ៉ាវនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងកាត់បន្ថយលំហរសារពើពន្ធ និង លទ្ធភាពនៃការវិនិយោគសាធារណៈចាំបាច់សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ។

*ទី៣) ហានិភ័យពាក់ព័ន្ធនឹងអស្ថិរភាពនយោបាយ:*

ស្ថិរភាពនយោបាយ គឺជាបុរេលក្ខខណ្ឌចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ។ អស្ថិរភាពនយោបាយនឹងនាំឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្មស្ថិតក្នុងស្ថានភាពជាប់គាំងគ្មានការរីកចម្រើន ។ ម្យ៉ាងវិញទៀត គោលនយោបាយប្រជាភិថុត គឺជាហានិភ័យផ្ទាល់ចំពោះការអភិវឌ្ឍវិស័យនេះ ដោយសារធនធានជាតិនឹងត្រូវបង្វែរទៅសកម្មភាព, ទិសដៅ និង អាទិភាពផ្សេងទៀត ដែលមិនបម្រើឱ្យគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែង ។

*ទី៤) ហានិភ័យពាក់ព័ន្ធនឹងប្រព័ន្ធអភិបាលកិច្ច, ស្ថាប័ន និង ការសម្របសម្រួល:*

ការអនុវត្ត ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»*** ពាក់ព័ន្ធនឹងអន្តរាគមន៍ និង ការលើកទឹកចិត្តពីរដ្ឋ ហើយក៏អាចពាក់ព័ន្ធនឹងការអនុវត្តគំរោងធំៗ ដែលមានចរិតផ្តាច់មុខធម្មជាតិ (Natural Monopoly) ដែលតម្រូវឱ្យមានប្រព័ន្ធអភិបាលកិច្ច និង ការគ្រប់គ្រងច្បាស់លាស់ រួមទាំង សមត្ថភាពបច្ចេកទេស, ការប្តេជ្ញាចិត្ត

និង ឆន្ទៈនយោបាយខ្ពស់ ។ ដូច្នេះ គោលនយោបាយអាចនឹងបង្កើតនូវហានិភ័យសំខាន់មួយ គឺ ការកេងប្រវ័ញ្ច ឬ ឆ្លៀតយកចំណេញពីចន្លោះប្រហោង ឬ ភាពទន់ខ្សោយនៃប្រព័ន្ធអភិបាលកិច្ច រួមទាំង ក្របខណ្ឌច្បាប់, ប្រព័ន្ធនិយ័តកម្ម និង ប្រព័ន្ធគ្រប់គ្រង ។

ជាមួយការប្រមើលឃើញអំពីហានិភ័យចម្បងទាំងនោះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ និងវិធានការទាំងឡាយ ដែលត្រូវបានដាក់ចេញមកដើម្បីគោលដៅនៃការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ។ ផ្អែកលើការតាមដាន និងត្រួតពិនិត្យការអនុវត្តជាប្រចាំ រាជរដ្ឋាភិបាលខិតខំគ្រប់គ្រង និងដោះស្រាយហានិភ័យ និងបញ្ហាប្រឈមទាំងឡាយឱ្យបានប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាពខ្ពស់បំផុត តាមរយៈអភិក្រមបុរេសកម្ម និងការប្រកាន់ខ្ជាប់នូវអប្បមាទខ្ពស់ ។

## ៩) - សេចក្តីសន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងដំណាក់កាលប្រែប្រួលសំខាន់មួយ ក្រោយពីសម្រេចបានកំណើនខ្ពស់ក្នុងរយៈពេលជាងមួយទសវត្សមកនេះ ពោលគឺការឈានឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យម ដែលតម្រូវឱ្យមានការកែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ សំដៅពង្រឹងពិពិធកម្មសេដ្ឋកិច្ច និង ភាពប្រកួតប្រជែង ដែលធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង មានការបែងចែកផ្លែផ្កាប្រកបដោយសមធម៌ ។ ប្រការនេះ ទាមទារការគិតគូរអំពីអភិក្រមអភិវឌ្ឍន៍ថ្មី ពាក់ព័ន្ធនឹងការពង្រីកកាលានុវត្តអភិវឌ្ឍន៍ និង ការវិនិយោគក្នុងវិស័យកំណើនថ្មី ពិសេសតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមចាំបាច់, ការផ្គត់ផ្គង់ថាមពលអគ្គិសនី, ការពង្រីកហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និង ការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ចំណេះដឹងផ្នែកបច្ចេកទេស និង វិទ្យាសាស្ត្រ និង ការពង្រឹងយន្តការស្ថាប័នប្រកបដោយសមត្ថភាព និង មានប្រសិទ្ធភាព ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សំដៅផ្តល់នូវក្របខណ្ឌគោលនយោបាយ និង យន្តការជាក់លាក់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា និងបង្កើតការងារដោយផ្តោតលើការអភិវឌ្ឍវិស័យកម្មន្តសាល, កសិឧស្សាហកម្ម និង សហគ្រាសធុនតូច និង មធ្យម ។ តាមរយៈគោលនយោបាយនេះ កម្ពុជានឹងសម្រេចបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចមួយជ្រាលជ្រៅ ដោយឈានពីរចនាសម្ព័ន្ធ ដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅបង្កើតសេដ្ឋកិច្ចដែលពឹងផ្អែកសំខាន់លើកម្មន្តសាល និង កសិឧស្សាហកម្ម ហើយឈានទៅដល់ការលើកកម្ពស់ និង ពិពិធកម្មឧស្សាហកម្ម ក្នុងវិស័យផ្សេងៗទៀត ពិសេសឧស្សាហកម្មប្រើប្រាស់បច្ចេកវិទ្យា និង នវានុវត្តន៍ ក្នុងដំណាក់កាលចុងក្រោយ ។

# ឧបសម្ព័ន្ធ «ក» : គំនូសបំព្រួញនៃប្រព័ន្ធតួអង្គអនុវត្តនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម



## ឧបសម្ព័ន្ធ «ខ» : គំនូសបំព្រួញនៃតួនាទីគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និង គណៈកម្មាធិការវិនិយោគកម្ពុជា



## <u>ឧបសម្ព័ន្ធ «គ» :</u> ម៉ាទ្រីសអំពីវិធានការជាក់ស្តែងគន្លឹះបួន ដើម្បីជំរុញ«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»

| | **វិធានការជាក់ស្តែងបួន** | **សូចនាករ** | **ឆ្នាំគោលដៅ** | **ស្ថាប័នទទួលខុសត្រូវសម្របសម្រួល** |
|---|---|---|---|---|
| **ទី១** | រៀបចំ និង អនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម រួមទាំង ការពង្រឹងភាពទុកចិត្ត និង ការពង្រីកវិសាលភាពគ្រប់ដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី ។ | *- បញ្ចុះថ្លៃទិញពីអនុស្ថានីយផ្ទាល់ មកត្រឹម **១២,៦០ សេនអាមេរិក** ក្នុង ១គីឡូវ៉ាត់ម៉ោង;*<br>*- បញ្ចុះថ្លៃទិញពីប្រព័ន្ធភ្នំពេញ កណ្តាល និងកំពង់ស្ពឺរបស់អគ្គិសនីកម្ពុជា មកត្រឹម **១៦,៥០សេនអាមេរិក** ក្នុង ១គីឡូវ៉ាត់ម៉ោង;*<br>*- បញ្ចុះថ្លៃទិញពីខ្សែបញ្ជូនរងនានា ដែលចេញពីអនុស្ថានីយ (ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់សេវាករឯកជន) មកត្រឹមឯកតាថ្លៃរួមមួយ **១៦,៤០ សេនអាមេរិក** ក្នុង ១គីឡូវ៉ាត់ម៉ោង;*<br>*- អនុម័តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃ-យប់ សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម;*<br>*- ពង្រីកវិសាលភាពគ្រប់ដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីឱ្យដល់គ្រប់តំបន់ឧស្សាហកម្មគោលដៅ;*<br>*- ធានាស្ថិរភាព និងភាពទុកចិត្តនៃការផ្គត់ផ្គង់អគ្គិសនីដោយកាត់បន្ថយអត្រាដាច់ចរន្តមិនឱ្យលើសពី ១២ដង ឬ ២៤ម៉ោង/ឆ្នាំ ។* | **២០១៨** | - ក្រសួងរ៉ែ និង ថាមពល<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- ក្រុមហ៊ុនអគ្គិសនីកម្ពុជា |
| **ទី២** | រៀបចំ និង អនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និង ឡូជិស្ទិក ក្នុងគោលដៅ | *- ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនស្តង់ដារអន្តរជាតិ;* | **២០១៨** | - សម្របសម្រួលដោយគណៈកម្មា-ធិការគោលនយោបាយសេដ្ឋកិច្ច |

| | ទិសដៅការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល |
|---|---|---|---|---|
| | បង្កើតនូវប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និង ប្រព័ន្ធឡូជិស្ទិកដែលមានសមាហរណកម្ម និង ប្រសិទ្ធភាពខ្ពស់ ពិសេសផ្តោតលើការតភ្ជាប់ប៉ូល សេដ្ឋកិច្ចសំខាន់ៗ និង ការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ***ភ្នំពេញ- ខេត្តព្រះសីហនុ***, ***ភ្នំពេញ- បាវិត*** និង ***ភ្នំពេញ- ប៉ោយប៉ែត*** ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ច គន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវហាយវេ ស្តង់ដារអន្តរជាតិ និង ការបង្កើតប្រព័ន្ធឡូជិស្ទិក ប្រកបដោយប្រសិទ្ធភាព ។ | *- ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធឡូជិស្ទិក ប្រកបដោយសមាហរណកម្មនិងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់;*<br>*- ផែនការអភិវឌ្ឍន៍របៀងសេដ្ឋកិច្ច;*<br>*- ផែនការ កម្មវិធី និងគម្រោងវិនិយោគ;*<br>*- យន្តការគ្រប់គ្រង និងអនុវត្ត ។* | | និងហិរញ្ញវត្ថុ<br><u>ក្រសួងស្ថាប័នចូលរួម:</u><br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **ទី៣** | ពង្រឹង និង បន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារ ពលកម្ម និង ការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សា ស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម, លើកកម្ពស់ ផលិតភាព និង កែលម្អកម្រឹតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្ស អប្បរមា និង ការពង្រឹងសុខដុមភាពនៃទំនាក់- ទំនងឧស្សាហកម្ម ឈរលើគោលការណ៍សិរិយាបថ វិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់ និយោជកចំពោះនិយោជិត ដោយប្រើប្រាស់ យន្តការមានស្រាប់រួមមានជាអាទិ៍ យន្តការ | *- ថ្លៃឈ្នួលអប្បបរមា ដែលធានាបាននូវកម្រិតជីវភាពរស់នៅសមស្រប ភាពប្រកួតប្រជែង និង ពិពិធកម្មនៃសេដ្ឋកិច្ច- ឧស្សាហកម្មកម្ពុជា;*<br>*- កែលម្អស្ថិរភាពទីផ្សារពលកម្ម និងកាត់បន្ថយ ចំនួនវិវាទការងារ;*<br>*- លក្ខខណ្ឌការងារ និងជីវភាពកម្មករប្រសើរឡើង*<br>*- ផែនការមេសម្រាប់ការពង្រីក និង ទំនើបកម្មប្រព័ន្ធ បណ្តុះបណ្តាលបច្ចេកទេស និងជំនាញ;*<br>*- កម្មវិធី និងគម្រោងវិនិយោគសម្រាប់ការបណ្តុះ បណ្តាលបច្ចេកទេស និងជំនាញ ដែលមានការ សម្របសម្រួលលក្ខណៈជាប្រព័ន្ធឆ្លើយតបនឹង* | **២០១៨** | - ក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- គណៈកម្មាធិការប្រឹក្សាការងារ<br>- គណៈកម្មាធិការផលិតភាពកម្ពុជា |

| | ទិសដៅការដាក់ស្តែងចេញ | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល |
|---|---|---|---|---|
| | ***«គណៈកម្មាធិការប្រឹក្សាការងារ»*** និង ***«គណៈ-កម្មាធិការផលិតភាពកម្ពុជា»*** ។ | *តម្រូវការឧស្សាហកម្ម;* | | |
| **ទី៤** | អភិវឌ្ឍ និង ប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍ, ក្របខណ្ឌច្បាប់ និង និយ័តកម្ម ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដែលនឹងផ្តល់សិទ្ធិអំណាច និងយុត្តាធិការពេញលេញ សម្រាប់ការកៀរគរ, ទាក់-ទាញ និងប្រមូលផ្តុំនូវប្រភពធនធាន, បញ្ញាញាណ, សកម្មភាពធុរកិច្ច និង វិនិយោគ ដើម្បីអភិវឌ្ឍខេត្តនេះទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និង ជា មជ្ឈ-មណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និង ទេសចរណ៍ ស្របតាមទស្សនទាននៃការអភិវឌ្ឍ ប្រកបដោយចីរភាព និងមានតុល្យភាពបរិស្ថាន ព្រមទាំងប្រែ-ក្លាយជា **ទីក្រុងឧស្សាហកម្មបៃតងអាស៊ាន** នាពេលអនាគត ។ | *- ផែនការមេសម្រាប់ការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង;*<br>*- ក្របខណ្ឌច្បាប់ និងនិយ័តកម្ម;*<br>*- យន្តការរដ្ឋបាល និងការគ្រប់គ្រង;*<br>*- ផែនការប្រតិបត្តិ និងវិនិយោគ ។* | **២០១៨** | - សម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br><u>ក្រសួង/ស្ថាប័នចូលរួម :</u><br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>- ទីស្តីការគណៈរដ្ឋមន្ត្រី<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>- ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត |

# ឧបសម្ព័ន្ធ «ឃ» : ម៉ាទ្រីសនៃវិធានការគោលនយោបាយ និង ផែនការសកម្មភាព

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
| --- | --- | --- |
| ***១)- ការជំរុញការទាក់ទាញវិនិយោគ*** | | |
| ***ក- បរិយាកាសវិនិយោគ*** | | |
| - ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ផ្អែកលើតម្រូវការជាក់ស្តែង ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមាន ការទាក់ទាញការវិនិយោគ, ការផ្ទេរបច្ចេកវិទ្យា, ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ និង ការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម; | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ពិនិត្យឡើងវិញ និង កែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេស សម្រាប់ទាក់ទាញ «គម្រោងវិនិយោគសក្តានុពល និង មានគុណភាព» ដែលផ្តល់ផលវិជ្ជមាននិងតម្លៃបន្ថែម សម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងទាក់ទាញឧស្សាហកម្មថ្មីៗ មកកម្ពុជា; | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| - បន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខណ្ឌគតិយុត្តិ ក្របខណ្ឌអភិបាលកិច្ច និង ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ពិសេសការពង្រឹងយន្តការ ***«ច្រកចេញចូលតែមួយ»*** នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការទាក់ទាញវិនិយោគ; | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| - ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែម ចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្តុះបណ្តាលជំនាញ, ការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍; | មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| | | - ក្រសួងស្ថាប័នពាក់ព័ន្ធ |
| - ពង្រឹងសមត្ថភាពស្ថាប័ន និង សមាហរណកម្មមុខងារគ្រប់គ្រង និង ទាក់ទាញវិនិយោគ ជាមួយមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរួមនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យម, ការកែទម្រង់ និងទំនើបកម្មស្ថាប័ន, និងការលើកកម្ពស់សមត្ថភាពមន្ត្រី ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងចក្ខុវិស័យ និង គោលដៅនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ពង្រឹង និង លើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ និង តាមដានការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការគោរពគោលការណ៍ និង លក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគ ព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការវិនិយោគ និង ដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិន ក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - បន្តពង្រឹងប្រសិទ្ធភាពនៃ ***«វេទិការាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន»*** ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - រៀបចំ និង ដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និង វិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយ និង ទាក់ទាញការវិនិយោគ ដោយផ្តោតលើប្រទេសគោលដៅមួយចំនួន និង កំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ពិនិត្យឡើងវិញនូវយន្តការផ្តល់ព័ត៌មានវិនិយោគ ដោយយកចិត្តដាក់លើភាពងាយស្រួលក្នុងការទទួលពតិមាន ពិសេសការកែលម្អមាតិកាព័ត៌មាន ដែលផ្អែកលើប្រតិកម្មតបនៃអ្នកប្រើ-ប្រាស់ ។ | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ***ខ- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និង ការរៀបចំតំបន់ឧស្សាហកម្ម*** | | |
| - ពិនិត្យឡើងវិញអំពីក្របខណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ក្រុមហ៊ុនក្នុងស្រុក និង សហគ្រាសធុនតូចនិងមធ្យម; | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ចាត់វិធានការ និង ជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅធានាឱ្យមានភាពទាក់ទាញ និង ការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ; | ២០១៥<br>មធ្យម<br>ទៅវែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត ***«ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស»*** សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រង មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ, ការផ្គត់ផ្គង់អគ្គិសនី ទឹក-ស្អាត វត្ថុធាតុដើម និង ធាតុចូលផ្សេងៗ, កិច្ចសម្រួលការដឹកជញ្ជូន និង ពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និង វិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស; | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូច និង មធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាម | មធ្យម<br>ទៅ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| រយៈការផ្តល់ អាទិភាពលើការតភ្ជាប់បណ្តាញអគ្គិសនី និង ការផ្គត់ផ្គង់ទឹកស្អាត, ការតភ្ជាប់ផ្លូវដឹកជញ្ជូន និង ឡូជីស្ទីក ព្រមទាំងការសម្រួល និង ការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ; | វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និង ខេត្តកោះកុង ព្រមទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជាតភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាង នៅក្នុងក្របខណ្ឌនៃរបៀងសេដ្ឋកិច្ចមហា-អនុតំបន់មេគង្គ និង អាស៊ាន; | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ |
| - លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករស្តូល សម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យ ក្នុងការផ្តល់ការលើកទឹកចិត្ត និង ជំរុញឧត្តមានុវត្តន៍; | ២០១៥ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្តព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និង ក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមានការកំណត់តំបន់ដីធ្លីផ្អែកលើ ផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់, ការគ្រប់គ្រងបរិស្ថានដែលធានាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី, ការអភិវឌ្ឍលំនៅដ្ឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលរួមមានអគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និង ទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល, អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេលវែង; | មធ្យម ទៅ វែង | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាក់ព័ន្ធផ្សេងទៀត |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - អភិវឌ្ឍតំបន់ជុំវិញទីក្រុងភ្នំពេញ ឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ដោយបែងចែករវាងតំបន់ឧស្សាហកម្ម និង តំបន់និវេសនដ្ឋាន ឬ ទីប្រជុំជន រួមទាំងផែនការរយៈពេលវែង សម្រាប់ប្រែក្លាយទីក្រុងភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល, ឧស្សាហកម្ម, វិទ្យាសាស្ត្រ និង នវានុវត្តន៍; | មធ្យម ទៅ វែង | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងមហាផ្ទៃ/ សាលារាជធានីភ្នំពេញ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាក់ព័ន្ធផ្សេងទៀត |
| - សិក្សារៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និង មធ្យម សំដៅជំរុញការតភ្ជាប់រវាង សហគ្រាសធំបរទេស និង សហគ្រាសក្នុងស្រុក ពិសេស ការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និង ខ្សែចង្វាក់ ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់; | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ |
| - កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និង គោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំង ក្នុងតំបន់សេដ្ឋកិច្ចពិសេស និង តំបន់ឧស្សាហកម្មផ្សេងទៀត; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងបរិស្ថាន |
| - បន្តពង្រឹង និង លើកកម្ពស់សមត្ថភាពរដ្ឋបាល និង ក្របខណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិ-បត្តិការនៃ តំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា ការកែច្នៃកសិផល សម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេស ត្រូវចំណុះលើកត្តាសំខាន់ៗ ដូចជា ទីតាំងភូមិសាស្ត្រ | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ រួមទាំង អគ្គិសនី និងទឹកស្អាត និង ប្រព័ន្ធ ឡូជិស្ទីក ព្រមទាំងការលើកទឹកចិត្តផងដែរ); | | |
| - ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ។ | មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ***២)- ការពង្រីក និង ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម*** | | |
| ***ក- ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត*** | | |
| - ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ, ការអភិវឌ្ឍផលិតផលថ្មី, ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs), ការតភ្ជាប់ខ្សែចង្វាក់តម្លៃ និង ការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខណ្ឌសកម្មភាពចំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍សហគ្រាសទាំងនោះ; | ២០១៥<br>ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងពាណិជ្ជកម្ម |
| - ពង្រឹងនូវក្របខណ្ឌ និង យន្តការអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី, ការគ្រប់គ្រង និង តាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាសកម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់-លាស់ សម្រាប់រៀបចំគោលនយោបាយគាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានលទ្ធភាពទទួលបានព័ត៌មានពីឥណទាន និង ការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាព និង ការវិនិយោគ; | ២០១៥<br>ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាណិជ្ជកម្ម<br>- ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត |
| - ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និង ការបណ្តុះបណ្តាលពីបណ្តាលប្រទេសនានា ជុំវិញពិភពលោក; | ២០១៥<br>មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| ទិសដៅគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវ ប្រកបដោយវិជ្ជាជីវៈ ដោយរដ្ឋាភិបាលផ្តល់នូវការវិភាជន៍ថវិកាសមស្រប យោងតាមតម្រូវការ និង លទ្ធភាពជាក់ស្តែងនៃថវិកាជាតិ; | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - កសាងធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្ម ឱ្យមានភាពរឹងមាំ និង ជវភាព ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេស សម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យអាទិភាព ដោយបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលវិស្វករ និងអ្នកបច្ចេកទេស; | មធ្យម ទៅវែង | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |
| - ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម សម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹក ចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក, ការលើកកម្ពស់ គុណភាពផលិត-ផល និង ទំនើបកម្មនៃខ្សែចង្វាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs); | មធ្យម ទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - លើកស្ទួយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សាដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និង នវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ; | មធ្យម ទៅវែង | - ក្រសួងអប់រំ យុវជន និងកីឡា |
| - បង្កើតពានរង្វាន់សម្រាប់ការប្រកួតប្រជែងបច្ចេកទេស នៅលើគ្រប់មុខសញ្ញាអាទិភាព; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ជំរុញការបង្កើតសមាគមតាមអនុវិស័យវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង, តស៊ូមតិ និង ការពារសិទ្ធប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ។ | មធ្យម ទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ***ខ- ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ*** | | |
| - ធ្វើវិសោធនកម្មកែលម្អ ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈ គណនេយ្យ ដោយរៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម; | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ដោយប្រើប្រាស់ ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ សម្រាប់ជាមូលដ្ឋានវាយតម្លៃ និង ជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្ត និង ការគាំទ្រពីរាជរដ្ឋាភិបាល; | ២០១៥ | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងពាក់ព័ន្ធ |
| - លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូច និងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត; | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ |
| - ពង្រឹងអភិបាលកិច្ចសារជីវកម្ម សម្រាប់ពង្រឹង និង ពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និង លទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ, ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យា សម្រាប់សហគ្រាសធុនតូច និងមធ្យម; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាណិជ្ជកម្ម |
| - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃការចុះបញ្ជី; | ២០១៥ | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម; | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| ***គ- ការជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម*** | | |
| - ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជា តំបន់កែច្នៃនិងផលិតសង្ហារឹម, តំបន់កែច្នៃផលិតសម្ភារៈអំពីកៅស៊ូ, តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ, តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូររវាងរដ្ឋ និង វិស័យឯកជន; | ២០១៥ ទៅមធ្យម | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណា ដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ; | ២០១៥ ទៅមធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល, បច្ចេកទេសកែច្នៃកសិផល និង អភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាឡូជីស្ទីក, លុបបំបាត់កម្រៃក្រៅផ្លូវការ និង កែលម្អការសម្រួលពាណិជ្ជកម្ម; | ២០១៥ ទៅមធ្យម | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - សិក្សាកំណត់នូវមុខទំនិញអាទិភាព ដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើខ្សែចង្វាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ ។ | មធ្យមទៅវែង | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| ***៣)- ការកែលម្អបរិស្ថាននិយ័តកម្ម*** | | |
| ***ក- វិធានការសម្រួលពាណិជ្ជកម្ម និង ជំរុញការនាំចេញ*** | | |
| - ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវា ***«បញ្ជរតែមួយជាតិ»*** ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវា ***«បញ្ជរតែមួយអាស៊ាន»*** និង ការតភ្ជាប់ទៅនឹងបណ្តាញឡូជិស្ទីកអន្តរជាតិ; | ២០១៥ ទៅមធ្យម | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| - បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្តុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្តាញអ៊ីនធឺណែត; | ២០១៥ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - កែលម្អការធ្វើបែបបទបញ្ចេញទំនិញ (Custom Clearance) សម្រាប់ទំនិញដែលលើកលែងពន្ធ ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ, កាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស និង លុបបំបាត់ចំណាយក្រៅផ្លូវការ; | ២០១៥ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និង គ្មានតម្លាភាព; | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង/ស្ថាប័នពាក់ព័ន្ធ |
| - រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធឡូជិស្ទីក ដែលជាមូលដ្ឋានក្នុងការជួយសម្រួលពាណិជ្ជកម្ម និង ជាប្រព័ន្ធដែលមានប្រសិទ្ធភាព អាចទុកចិត្តបាន និង មានភាពប្រកួតប្រជែងខ្ពស់; | ២០១៥ ទៅមធ្យម | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុ-តំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង***«យន្តការបញ្ជរតែមួយ»*** | ២០១៥ ទៅមធ្យម | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងពាណិជ្ជកម្ម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| ដែលត្រូវបានបង្កើតឡើង ក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធឡូជីស្ទីកអន្តរជាតិក្នុងតំបន់, ទន្ទឹមនឹងការរៀបចំបង្កើតក្របខណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមារណកម្មបញ្ចូលក្នុងប្រព័ន្ធឡូជីស្ទីក, កិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយអាជ្ញាធរដែលពាក់ព័ន្ធដែលមានកាតព្វកិច្ចក្នុង ការសម្រួលការដឹកជញ្ជូន, ការចល័តមនុស្ស និង ទំនិញ; | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ពង្រឹងសមត្ថភាពនាយកដ្ឋានជំរុញការនាំចេញនៃក្រសួងពាណិជ្ជកម្ម ឱ្យក្លាយជាភ្នាក់ងារជំរុញការនាំចេញ ដែលមានជំនាញខ្ពស់ក្នុងការវិភាគទីផ្សារនាំចេញ, កំណត់មុខសញ្ញានាំចេញ និង រៀបចំបណ្តាញធុរកិច្ច ដែលជាមូលដ្ឋានក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម, ផ្តល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និង ជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំងការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬ ការតាំងពិព័រណ៍; | ២០១៥ | - ក្រសួងពាណិជ្ជកម្ម |
| - ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយ ដែលមានកាតព្វកិច្ចផ្តល់កម្ចីទៅឱ្យអ្នកនាំចេញ ដែលផលិតទំនិញនាំចេញក្នុងឧស្សាហកម្មអាទិភាព និង ផ្តល់នូវសេវាធានារ៉ាប់រងការនាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ; | ២០១៥<br>ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម |
| - ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី, ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន, ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន; | ២០១៥<br>ទៅមធ្យម | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |
| - ពិចារណាបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និង នាំចេញបានចំនួនច្រើនជាងគេ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តពិសេស និងរង្វាន់នានា | ២០១៥ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| សម្រាប់ក្រុមហ៊ុនដែលបាននាំទំនិញដល់ចំនួនដែលបានកំណត់ តាមរយៈការវាយតម្លៃប្រកបដោយតម្លាភាព ដោយផ្សារភ្ជាប់នឹងគោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម; | | |
| - ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល ។ | ២០១៥ ទៅមធ្យម | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ***ខ- ការពង្រឹងបទដ្ឋានឧស្សាហកម្ម និង កម្មសិទ្ធិឧស្សាហកម្ម*** | | |
| - បន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារ ដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និង ខិតខំប្រឹងប្រែងបន្តរៀបចំក្របខណ្ឌគតិយុត្តិ និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមាន មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និង វិទ្យាស្ថានស្តង់ដារកម្ពុជា; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការ ផ្តល់សិទ្ធចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារ ដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធឧស្សាហកម្ម; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ពង្រឹងការប្រើប្រាស់ស្តង់ដារូបនីយកម្ម និង ការវាយតម្លៃការទទួលស្គាល់អនុលោមភាព ដោយផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃស្តង់ដារ, មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចមាត្រាសាស្ត្រ និង ស្តង់ដារ ក្នុងការធានានូវបរិមាណ, គុណភាព, សុវត្ថិភាព, សេវាកម្ម, បរិស្ថាន និង គ្រប់គ្រង; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ចាត់វិធានការជាក់ស្តែងក្នុងពង្រឹងការអនុវត្តស្តង់ដារ, មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខណ្ឌទាំងនេះឱ្យក្លាយឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ ***«មជ្ឈមណ្ឌលផលិតភាពកម្ពុជា»*** សំដៅលើកកម្ពស់ផលិតភាព និងគុណភាព ដល់សហគ្រាសធុនតូច និងមធ្យម; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ពង្រឹងសមត្ថភាព ***«វិទ្យាស្ថានស្តង់ដារកម្ពុជា»*** ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដារជាតិ សម្រាប់ផលិតផល, សេវាកម្ម, ផលិតកម្ម និង បច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និង អន្តរជាតិ; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ក្នុងការសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យ, ផ្ទៀងផ្ទាត់, ព្យាសកម្ម, តេស្តវិភាគ និង អនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលបំរើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ***គ- ការសម្រួលការបំពេញកាតព្វកិច្ចពន្ធ និងអាករ*** | | |
| - សិក្សាឡើងវិញពីប្រព័ន្ធពន្ធដារ និង ពន្ធគយ ដោយប្រែក្លាយឱ្យទៅជាឧបករណ៍ប្រមូលចំណូលផង និង ជាឧបករណ៍ជំរុញការអភិវឌ្ឍឧស្សាហកម្មផង; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ធ្វើទំនើបកម្មយន្តការប្រមូលចំណូល និងកែលម្អសេវាអ្នកជាប់ពន្ធ សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធ ក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ; | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - បង្កើនការផ្តល់សេវាដើម្បីឱ្យអ្នកជាប់ពន្ធងាយស្រួលទទួលព័ត៌មានពីការបង់ពន្ធ និង ការលើកលែងពន្ធ; | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ជំរុញការបង្វិលសងឱ្យបានឆាប់ ឬប្រើប្រាស់ជាឥណទានយោង (Tax Credit) ស្របតាមបទប្បញ្ញត្តិពន្ធដារជាធរមាន; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ពិនិត្យ និង សម្រួលឡើងវិញនូវក្របខណ្ឌនៃការអនុវត្ត ដោយសម្រួល ឬ ដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្វាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និង ការលើកលែងពន្ធ ។ | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ***ឃ- ការរៀបចំទីផ្សារពលកម្ម និង ទំនាក់ទំនងឧស្សាហកម្ម*** | | |
| - បន្តពង្រឹងយន្តការទំនាក់ទំនងត្រីភាគី រួមមានរដ្ឋាភិបាល និយោជក និង និយោជិត តាមរយៈ ***«គណៈកម្មាធិការប្រឹក្សាការងារ»*** ដើម្បីបង្កើនការយោគយល់គ្នា, ទន្ទឹមនឹងការខិតខំរៀបចំប្រព័ន្ធយន្តការមួយ ប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដែលស៊ីចង្វាក់ទៅនឹងផលិតភាពការងារ, សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច- សង្គម និង ធានាបាននូវការអភិវឌ្ឍឧស្សាហកម្មជារួម; | ២០១៥ ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| - ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនងរវាងបុគ្គលិកនិយោជិក និង និយោជកដើម្បី កំណត់ពីបទពិសោធន៍ល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយ ដែលអាចបង្កើនផលិតផលសរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករស្របទៅតាមច្បាប់ការងារ និង បទប្បញ្ញត្តិជាធរមាន; | ២០១៥ ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| - ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការពង្រីកកម្មវិធីរោងចក្រល្អប្រសើរ ឬ ពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមការងារចម្រុះធ្វើអធិការកិច្ចជាប្រចាំ និង មានកម្មវិធីច្បាស់លាស់ ដើម្បីកាត់បន្ថយចំនួនត្រួតពិនិត្យផង និងធានាបានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យផង ។ ក្រុមការងារចម្រុះនេះត្រូវរាយការណ៍ជាទៀតទាត់ជូនរាជរដ្ឋាភិបាល; | ២០១៥ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករ ឱ្យយល់ដឹងពីជីវភាព និង សិទ្ធិស្របច្បាប់របស់ខ្លួន ពិសេសកាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ; | ២០១៥ ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ទីភ្នាក់ងារជាតិមុខរបរ |
| - លើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការជំរុញអនុវត្តគោលនយោបាយលំនៅដ្ឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី; | មធ្យមទៅវែង | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| - ពិនិត្យឡើងវិញពីច្បាប់ការងារ និងការអនុវត្តកន្លងមក ដើម្បីស្វែងរកចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ហើយធ្វើការគូសបញ្ជាក់ឡើងវិញពីតួនាទីរបស់និយោជក និង សហជីព ក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបាននូវតុល្យភាពនៃការអភិវឌ្ឍ និង សុខមាលភាពកម្មករ; | មធ្យមទៅវែង | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| - ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន ។ | ២០១៥ ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ***៤) - ការសម្របសម្រួលគោលនយោបាយគាំទ្រ*** | | |
| ***ក- ការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស*** | | |
| - បង្កើតឱកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ; | ២០១៥ | - ក្រសួងអប់រំ យុវជន និងកីឡា |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និង មធ្យមសិក្សា ដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និង យុវជន លើផ្នែកគណិតវិទ្យា, វិទ្យាសាស្ត្រ, អក្សរសាស្ត្រ និង បច្ចេកវិទ្យា; | ២០១៥ មធ្យម វែង | - ក្រសួងអប់រំ យុវជន និងកីឡា |
| - ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ប្រាំបួនឆ្នាំ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា; | ២០១៥ មធ្យម វែង | - ក្រសួងអប់រំ យុវជន និងកីឡា |
| - កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (Soft Skills) រួមមាន ជំនាញទំនាក់ទំនងសង្គម, ក្នុងការដោះស្រាយបញ្ហា, ការគោរពវិន័យនៅកន្លែងធ្វើការ និង ជំនាញជាច្រើនទៀតដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម; | មធ្យមទៅវែង | - ក្រសួងអប់រំ យុវជន និងកីឡា |
| - ពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីព និងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្តដើម្បីអភិវឌ្ឍន៍ជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់; | ២០១៥ ទៅមធ្យម | - ក្រសួងអប់រំ យុវជន និងកីឡា |
| - បង្កើនការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនដងជាងមុន តាមលទ្ធភាពលើជំនាញបច្ចេក-ទេស ជាពិសេស នៅក្នុងផ្នែកអគ្គិសនី, អេឡិចត្រូនិក, មេកានិក, ស្ពង់ដារ, មាត្រាសាស្ត្រ (ត្រួតពិនិត្យ, ផ្ទៀងផ្ទាត់, ព្យាសកម្ម, តេស្ត និងជំនាញប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ) និង គីមីសាស្ត្រ ទាំងក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស និង ឧត្តមសិក្សា; | មធ្យមទៅវែង | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន (ទាំងក្នុងប្រព័ន្ធអប់រំទូទៅ និង ក្រៅប្រព័ន្ធ) ដោយផ្តោតលើផ្នែកសំខាន់ៗ ដូចជា អគ្គិសនី, អេឡិចត្រូនិច, ព័ត៌មានវិទ្យា, កុំព្យូទ័រ, ម៉ាស៊ីន, ការជួសជុល និងការដំឡើងរថយន្ត និងម៉ូតូ, ការកែច្នៃកសិផល និង សិប្បកម្ម; | មធ្យមទៅវែង | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម ដោយរួមមានផែនការវិនិយោគច្បាស់លាស់ និងក្នុងទស្សនវិស័យរយៈពេលវែង; | ២០១៥ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |
| - ជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់ក្រុមហ៊ុននិងសហគ្រាស ដែលទទួលអនុវត្តតាមប្រព័ន្ធកម្មសិក្សាបែបនេះ; | ២០១៥<br>ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| - ពង្រឹងការបណ្តុះបណ្តាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជនទាំងវិន័យ, កម្រិតជំនាញ និង សមត្ថភាព តាមរយៈការធ្វើសហប្រតិបត្តិការជាមួយនឹងវិនិយោគិនបរទេសគោល-ដៅ មានដូចជា ការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញជប៉ុន, កូរ៉េ, សឹង្ហបុរី ។ល។; | ២០១៥<br>ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |
| - ជំរុញការបណ្តុះបណ្តាលត្រីភាគី «រដ្ឋ- ស្ថាប័នបណ្តុះបណ្តាល- ក្រុមហ៊ុន/ រោងចក្រ» ដើម្បីបំពាក់ជំនាញ និង បង្កើនផលិតភាព ជាពិសេសការដាក់បញ្ចូលក្នុងកម្មវិធីអប់រំ និងការបណ្តុះ-បណ្តាលវិជ្ជាជីវៈដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងសមាគមឧស្សាហកម្ម; | ២០១៥<br>ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |
| - ពង្រីកការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឱ្យពលករទាំងនោះទទួលបានការអប់រំបណ្តុះបណ្តាល និង ផ្តល់ក្តីសង្ឃឹម ក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេស ក្នុងពេលអនាគត; | ២០១៥<br>ទៅមធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |
| - ពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗផ្សេងទៀត និងវិស្វកម្ម ដោយពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍ ។ | មធ្យមទៅវែង | - ក្រសួងអប់រំ យុវជន និងកីឡា |

| ទិសដៅការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| ***ខ- ការជំរុញវិទ្យាសាស្ត្រ, បច្ចេកវិទ្យា និង នវានុវត្តន៍*** | | |
| - ជំរុញការរៀបចំនូវក្របខណ្ឌគោលនយោបាយ និង យន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ, បច្ចេកវិទ្យា និង នវានុវត្តន៍; | មធ្យមទៅវែង | - ក្រសួងផែនការ<br>- ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាក់ព័ន្ធ |
| - ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម; | មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ពង្រឹងការគ្រប់គ្រងមណ្ឌលច្នៃប្រឌិតនិងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម និង ការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម; | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម; | មធ្យមទៅវែង | - ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| - សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍; | មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ភ្ជាប់នឹងសួនឧស្សាហកម្ម និង តំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម; | មធ្យមទៅវែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច, វិស្វករ ដែលមានទេព្យកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេព្យកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និង សហគ្រិនវ័យក្មេង; | ២០១៥ | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្ដោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេសពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើសអ្នកវិទ្យាសាស្ត្រ និង វិស្វករមានសមត្ថភាព ជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ, បច្ចេកទេស, វិស្វកម្ម និង គណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា ពិសេសផ្ដោតលើសិស្សក្មេងៗ ជាមួយនឹងការកែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដារូបនីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ; | ២០១៥ ទៅមធ្យម | - ក្រសួងអប់រំ យុវជន និង កីឡា |
| - ពិនិត្យឡើងវិញ និងប្រមូលផ្ដុំសក្ដានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់ ។ | មធ្យមទៅវែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ***គ- ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម*** | | |
| - បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់, ផ្លូវរថភ្លើង, ផ្លូវអាកាស និង កំពុងផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់គោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម; | ២០១៥ ទៅមធ្យម | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| - ពិនិត្យតម្រង់ការផ្គត់ផ្គង់ថាមពល ទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់-ផ្គង់ចរន្តអគ្គិសនីស្របតាមតម្រូវការ និងមានស្ថិរភាពបំផុត ដែលអនុញ្ញាតឱ្យរោងចក្រអាចគ្រោងផលិតកម្មខ្លួនប្រកបដោយប្រសិទ្ធភាព; | ២០១៥ ទៅមធ្យម | - ក្រសួងរ៉ែ និងថាមពល<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- ក្រុមហ៊ុនអគ្គិសនីកម្ពុជា |
| - អនុវត្តគម្រោងកសាងស្ថានីយ៍ផលិតអគ្គិសនីដែលបានគ្រោង និង កំពុងបន្តអនុវត្តឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនីនៅឆ្នាំ ២០២០ រួមទាំង ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និង គុណភាពនៃការបញ្ជូនថាមពល; | មធ្យមទៅវែង | - ក្រសួងរ៉ែ និងថាមពល<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- ក្រុមហ៊ុនអគ្គិសនីកម្ពុជា |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍវិស័យថាមពល ធៀបនឹងចក្ខុវិស័យថ្មីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម រួមទាំងពិនិត្យឡើងវិញនូវជម្រើសក្នុងការផ្គត់ផ្គង់ថាមពល ដែលមានសមត្ថភាពគ្រប់គ្រាន់ ជាពិសេសសម្រាប់ផ្គត់ផ្គង់តំបន់ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ; | ២០១៥ | - ក្រសួងរ៉ែ និងថាមពល<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- ក្រុមហ៊ុនអគ្គិសនីកម្ពុជា |
| - បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបវិន្ត និង កែលម្អសេវា និងមធ្យោបាយដឹកជញ្ជូនសម្រាប់សម្រួល និងជួយគាំទ្រប្រតិបត្តិការអាជីវកម្ម; | មធ្យមទៅវែង | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី, ទីប្រជុំជន, តំបន់ឧស្សាហកម្ម និង តំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាពអង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជនស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដារទឹកបរិភោគជាតិ; | ២០១៥ ទៅមធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - បន្តពង្រីក និង ថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិច្រករបៀងសេដ្ឋកិច្ចខាងត្បូង ឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និង វៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ- សៀមរាប និង ភ្នំពេញ- ក្រុងព្រះសីហនុ, ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាងផ្លូវហាយវេចំពោះផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធឡូជិស្ទិករវាងកម្ពុជា និង ប្រទេសដទៃទៀត ជាអាទិ៍ ប្រទេសថៃ និង វៀតណាម; | មធ្យមទៅវែង | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ធ្វើឱ្យប្រសើរឡើង និង ថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមាន ប្រព័ន្ធផ្លូវថ្នល់ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេសនៅខេត្ត | មធ្យមទៅវែង | - ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងសាធារណៈការ និងដឹកជញ្ជូន |

| ទិសដៅការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| ស្វាយរៀង និង កោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និង ខេត្តព្រះសីហនុ ដែលមានកំពង់ផែសមុទ្រអន្តរជាតិ; | | - រដ្ឋបាលថ្នាក់ក្រោមជាតិ |
| - បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ- ខេត្តព្រះសីហនុ បានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន; | មធ្យមទៅវែង | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| - អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្តានុពលក្នុងការកាត់បន្ថយចំណាយឡូជីស្ទីក ជាពិសេសសម្រាប់ការដឹកជញ្ជូនកសិផល ដោយកសាងកំពង់ផែតូចៗ ដែលអាចឱ្យនាវាដឹកជញ្ជូនចូលផ្ទុក និង ផ្ទេរទំនិញនៅតាមដងទន្លេមេគង្គ ស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និង ខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន; | មធ្យមទៅវែង | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| - ដោះស្រាយបញ្ហាកកស្ទះចរាចរនៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយឡូជីស្ទីកកើនឡើងជាប្រចាំ ពិសេសការកសាងផ្លូវក្រវ៉ាត់ក្រុង ឬ ផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យបានចរាចរប្រព្រឹត្តទៅដោយរលូន តាមផ្លូវច្រករបៀងសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ; | ២០១៥ ទៅមធ្យម | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- សាលាក្រុងភ្នំពេញ |
| - ពិនិត្យលទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និង វិស័យឯកជន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលអាចបន្ធូរបន្ទុកវិនិយោគសាធារណជន ។ | ២០១៥ មធ្យម វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ***ឃ- វិធានការផ្នែកហិរញ្ញប្បទាន*** | | |
| - បន្តអនុវត្ត ***«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១- ២០២០»*** ដែលជាក្របខណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|
| - សិក្សា និង រៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូច និង មធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព; | ២០១៥ ទៅមធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| - កែលម្អប្រសិទ្ធភាព និង អភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជន៍ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម; | ២០១៥ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ |
| - ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភពហិរញ្ញវត្ថុ និង ប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្ររតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និង ការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ; | មធ្យមទៅវែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងសង្គមកិច្ច យុវនីតិសម្បទា និងអតីតយុទ្ធជន<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| - ផ្តល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោង និង កម្មវិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កន្លោមឧស្សាហកម្ម ឬ របៀងឧស្សាហកម្ម ។ | មធ្យមទៅវែង | - ក្រសួងផែនការ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា |

# <u>ឧបសម្ព័ន្ធ «ខ» :</u>

## តារាងផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ

*ឯកតាថ្លៃ: ដុល្លារអាមេរិក/គីឡូវ៉ាត់ម៉ោង ($/kWh)*

| ប្រភពនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីទ្វារចរន្តអនុស្ថានីយ | ០,១២៩ | ០,១២៦ | ០,១២៦ | ០,១២៦ | ០,១២៦ | ០,១២៦ |
| ទិញពីខ្សែមេនៃប្រព័ន្ធភ្នំពេញ | ០,១៧៧ | ០,១៧២ | ០,១៦៧ | ០,១៦៥ | ០,១៦៣ | ០,១៦២ |
| ទិញពីខ្សែមេនៅតាមខេត្ត | ០,១៧២៥ | ០,១៦៧៥ | ០,១៦៥ | ០,១៦៤ | ០,១៦៣ | ០,១៦២ |